ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣





## បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនភាពនាពេលកន្លងមក។ ក្នុងអាណត្តិទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដើម្បីពង្រឹងនូវបុរេលក្ខខណ្ឌចាំបាច់នានា និងបរិស្ថានគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅរបស់កម្ពុជា ក្នុងទិសដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសសម្រេចចក្ខុវិស័យប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្កើនផលិតភាព និងការប្រកួតប្រជែង ហើយផ្តល់នូវការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅក្នុងសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់។

វិស័យកសិកម្មនៅតែជាវិស័យនាំមុខមួយក្នុងចំណោមវិស័យដទៃទៀត ដែលបានរួមវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ហើយក៏បានរួមចំណែកក្នុងកំណើនផលទុនជាតិ និងចំណូលពីការនាំចេញផលិតផលកសិកម្ម។ វិស័យនេះក៏បានជួយផ្តល់ការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទដែលមានជីវភាពរស់នៅពឹងអាស្រ័យលើការងារកសិកម្ម។

នៅក្នុងចតុកោណទី៤នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើ៖ ១) ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ២) ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព ៣) ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម ៤) ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ចតុកោណទី៤នេះ គឺជាក្របខ័ណ្ឌមូលដ្ឋានសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំអភិវឌ្ឍន៍ក្នុងវិស័យនេះសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។ លើសពីនេះទៅទៀត ដោយសារចរន្តនៃការរីកចម្រើនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃ “បដិវត្តន៍ឧស្សាហកម្មទី៤” ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំផែនការអនុវត្ត ដោយដាក់បញ្ចូលនូវបច្ចេកវិទ្យានេះជាគន្លឹះនាំមុខដ៏ចម្បងមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកសិកម្ម និងបង្កើតកាលានុវត្តភាពសម្រាប់វិស័យកសិកម្ម។ ការរីកចម្រើនផ្នែកយន្តូបនីយកម្មកសិកម្មបាន និងកំពុងជំរុញល្បឿនផលិតកម្មកសិកម្ម ហើយអាចបង្វែរកម្លាំងពលកម្មទៅផ្នែកសេវាកម្ម និងឧស្សាហកម្មផ្សេងៗទៀត។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ឱ្យមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព បង្កើនប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមអភិក្រមនិងវិសាលភាពថ្មី ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម ពោលគឺពឹងផ្អែកជាសំខាន់លើធនធានដែលមានស្រាប់ (ធនធានដី និងធនធានធម្មជាតិផ្សេងៗទៀត) ឈានទៅរកដំណាក់កាលថ្មីដែលផ្តោតលើប្រពលវប្បកម្ម ពោលគឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី កសិកម្មវៃឆ្លាត ការស្រាវជ្រាវ និងការអភិវឌ្ឍយន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងទីផ្សារ រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។

ក្នុងន័យនេះ ដើម្បីសម្រេចបាននូវទិសដៅអភិវឌ្ឍន៍វិស័យកសិកម្មក្នុងអាណត្តិទី៦នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់ទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រគឺ បន្តជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ បានរៀបចំឡើងដោយមានសង្គតិភាពទៅនឹងឯកសារយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងស្របជាមួយឯកសារគោលនយោបាយពាក់ព័ន្ធផ្សេងៗទៀតផងដែរ។ ដំណើរការរៀបចំយុទ្ធសាស្ត្រនេះគឺមានការពិគ្រោះយោបល់ជាមួយអង្គភាពជំនាញក្រោមឱវាទក្រសួង ក្រសួងស្ថាប័នពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងតំណាងវិស័យឯកជន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិច្ចការជាច្រើនដែលនឹងត្រូវអនុវត្តក្នុងផែនការយុទ្ធសាស្ត្រនេះ និងត្រូវសម្រេចឱ្យបានលទ្ធផលជាក់ស្តែងនាពេលខាងមុខ ជាពិសេសដើម្បីសម្រេចបាននូវទិសដៅគោលដៅគោលនយោបាយទាំងអស់ខាងលើ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងអនុវិស័យនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែខិតខំធ្វើយ៉ាងណាអនុវត្តការងារឱ្យបានសកម្ម និងខ្លាំងក្លានូវបណ្តាសកម្មភាពទាំងឡាយ ដូចដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដោយប្រែក្លាយផែនការសកម្មភាពដែលមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើន និងប្រើប្រាស់ធនធានក្នុងស្រុក ព្រមទាំងកៀរគរធនធានពីបណ្តាដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានា ក៏ដូចជាការធ្វើសមាហរណកម្មឱ្យតួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួងស្ថាប័នអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ពិតជានឹងចូលរួមសហការអនុវត្តសកម្មភាពការងារ ពិសេសសហគមន៍អន្តរជាតិនឹងបន្តផ្តល់ជំនួយទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកជួយទ្រទ្រង់ដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នេះ ឱ្យទទួលបានលទ្ធផលផ្លែផ្កាជាវិជ្ជមាន និងប្រកបដោយប្រសិទ្ធភាពតាមផែនការ និងការរំពឹងទុក។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ដល់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបានចូលរួមយ៉ាងយកចិត្តទុកដាក់ ក្នុងដំណើរការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នេះ និងប្តេជ្ញាចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគតប្រកបដោយជោគជ័យ។

ថ្ងៃសុក្រ ៦កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩
**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

វេង សាខុន

**មាតិកា** **ទំព័រ**


**បុព្វកថា** ១

**ជំពូកទី១ : សេចក្តីផ្តើម** ៥

១.១. សារបាន........................................................................ ៦

១.២. អាទិភាពសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មសម្រាប់រយៈពេល៥ឆ្នាំខាងមុខ............... ៧

១.៣. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មជាមួយផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ........................................................ ៩

១.៤. ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ១៤

១.៥. ទម្រង់របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣............. ១៥

**ជំពូកទី២ : ការវិភាគស្ថានភាព (សមិទ្ធផល និងបញ្ហាប្រឈម)** ១៦

២.១. ស្ថានភាពទូទៅរបស់វិស័យកសិកម្ម.................................................. ១៦

២.២. លទ្ធផលសម្រេចបាននៃ ផ.យ.អ.វ.ក (២០១៤ - ២០១៨)................................ ១៨

២.២.១. ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម.............................. ១៩

២.២.២. ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ.................................... ២៤

២.២.៣. ការគ្រប់គ្រងធនធានជលផល និងវារីវប្បកម្ម.................................. ២៧

២.២.៤. ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ.................................... ៣០

២.៣. ការពង្រឹងសមត្ថភាពស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស.................. ៣៣

២.៤. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ................................................ ៣៤

២.៥. បញ្ហាប្រឈមក្នុងវិស័យកសិកម្ម...................................................... ៣៥

២.៦. ការវាយតម្លៃ និងសេចក្តីសន្និដ្ឋាន................................................. ៣៦

**ជំពូកទី៣ : យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម** ៣៨

៣.១. ចក្ខុវិស័យ និងបេសកកម្ម........................................................... ៣៨

៣.២. គោលបំណង និងគោលដៅយុទ្ធសាស្ត្រ................................................ ៣៩

៣.៣. យុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម....................................... ៤០

៣.៣.១. កម្មវិធីទី១៖ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច... ៤៣

៣.៣.២. កម្មវិធីទី២៖ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ.................. ៤៧

៣.៣.៣. កម្មវិធីទី៣៖ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម......... ៤៩

៣.៣.៤. កម្មវិធីទី៤៖ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ.......... ៥២

៣.៣.៥. កម្មវិធីទី៥៖ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស... ៥៤

៣.៤. ក្របខ័ណ្ឌអាទិភាពអន្តរវិស័យ....................................................... ៥៥

**ជំពូកទី៤ : ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យកសិកម្ម ២០១៩-២០២៣** ៦៦

៤.១. ការសម្របសម្រួលអនុវត្តផែនការយុទ្ធសាស្ត្រ......................................... ៦៦

៤.២. ការរៀបចំកម្មវិធី និងថវិកា........................................................... ៦៨

**ជំពូកទី៥ : យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានសម្រាប់អនុវត្តផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣** ៦៩

**ជំពូកទី៦ : ការតាមដាន និងវាយតម្លៃ** ៦៩
**ជំពូកទី៧ : សេចក្តីសន្និដ្ឋាន** ៧១
**ឧបសម្ព័ន្ធភ្ជាប់:**
ឧបសម្ព័ន្ធ១៖ តារាងផែនការសកម្មភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣
ឧបសម្ព័ន្ធ២៖ គម្រោងតម្រូវការថវិកាសរុប ២០១៩-២០២៣
តារាងទី១៖ ផលិតកម្មដំណាំស្រូវពីឆ្នាំ២០១៤-២០១៨........................................ ២០
តារាងទី២៖ ផលិតកម្មដំណាំកៅស៊ូពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨............................... ២៤
តារាងទី៣៖ ស្ថិតិសត្វតាមបែបផែនផលិតកម្មពីឆ្នាំ២០១៤-២០១៨............................ ២៥
តារាងទី៤៖ ស្ថានភាពផលនេសាទពីឆ្នាំ២០១៤-២០១៨....................................... ៣០
តារាងទី៥៖ ការដាំឈើដោយរដ្ឋបាលព្រៃឈើ និងឯកជនឆ្នាំ២០១៤-២០១៨................ ៣៣
តារាងទី៦៖ ការប៉ាន់ស្មានតម្រូវការធនធានហិរញ្ញវត្ថុឆ្នាំ២០១៤-២០១៨...................... ៦៩
ក្រាហ្វិកទី១៖ ការនាំចេញផលិតផលកសិកម្មពីឆ្នាំ២០១៤-២០១៨............................ ២១
ក្រាហ្វិកទី២៖ ផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម) ឆ្នាំ២០១៤-២០១៨ ២៥
ក្រាហ្វិកទី៣៖ ប្រព័ន្ធផែនការថវិកា ការតាមដាន និងវាយតម្លៃ ៧១

# ជំពូកទី១ : សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣**" ដែលនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ព្រះរាជាណាចក្រកម្ពុជាដែលពីមុនត្រូវបានចាត់ទុកថាអន់ថយផ្នែកសេដ្ឋកិច្ច គ្របដណ្តប់ទៅដោយភាពក្រីក្រ និងអសន្តិសុខស្បៀង បច្ចុប្បន្ននេះបានក្លាយទៅជាប្រទេសដែលជាប់ឯកគ្គទកម្មលើពិភពលោក ដែលបានសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ និងឋិតនៅក្នុងលំដាប់ចំណោមប្រទេសមានកំណើននៃការនាំចេញស្បៀង និងផលិតផលកសិកម្មទៅកាន់ទីផ្សារពិភពលោក។ លើសពីនោះទៅទៀត ព្រះរាជាណាចក្រកម្ពុជាក៏បានសម្រេចនូវវឌ្ឍនភាពដ៏ប្រសើរក្នុងការកាត់បន្ថយភាពក្រីក្រ ហើយបានឆ្លងកាត់ដោយជោគជ័យ ពីចំណាត់ថ្នាក់ប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

ជាក់ស្តែង រាជរដ្ឋាភិបាលសម្រេចបានសូចនាករសំខាន់ៗនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដោយបានសម្រេចកំណើនសេដ្ឋកិច្ចក្នុងរង្វង់ជាង៧% ក្នុងមួយឆ្នាំ រក្សាបាននូវអតិផរណាទាបក្នុងរង្វង់៣% ហើយក្នុងឆ្នាំ២០១៨នេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថានៅតែរឹងមាំ ពោលគឺមានកំណើនរហូតដល់៧,៥%។ សមិទ្ធផលទាំងអស់នេះសម្រេចទៅបានក្នុងបរិបទមួយនៃស្ថិរភាពនយោបាយ និងសុខសន្តិភាព ដែលសុទ្ធតែជាចំណុចគន្លឹះសម្រាប់កម្ពុជាបោះជំហានឆ្ពោះទៅមុខក្នុងការលើកកម្ពស់កម្រិតជីវភាព ដើម្បីសម្រេចបាននូវកិច្ចអភិវឌ្ឍមួយប្រកបដោយចីរភាព។ ពិតណាស់ថា ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំធ្វើយ៉ាងណាប្រមូលផ្តុំប្រើប្រាស់ធនធាន និងសក្តានុពលដែលមានសំដៅលើកកម្ពស់ផលិតភាពកសិកម្ម ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដើម្បីបង្កើនការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ បង្កើនការនាំចេញផលិតផលកសិកម្ម សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាកសិកររស់នៅតំបន់ជនបទ និងកាត់បន្ថយភាពក្រីក្រជាចម្បង។

ក្នុងន័យនេះ ការធ្វើទំនើបកម្មក្នុងវិស័យកសិកម្ម ត្រូវបាននិងកំពុងជំរុញអនុវត្តដោយផ្តោតទៅលើការធ្វើពិពិធកម្មដំណាំ សត្វ វារីវប្បកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រផលិតកម្មកសិកម្មនៅក្នុងប្រព័ន្ធខ្សែច្រវាក់ផលិតកម្មប្រកបដោយភាពប្រកួតប្រជែង ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ការពង្រឹងសមត្ថភាពនៃសេវាកម្មការផ្ទេរបច្ចេកទេសកសិកម្ម និងការអភិវឌ្ឍយន្តូបនីយកម្ម លើកកម្ពស់ការអភិវឌ្ឍ និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដើម្បីធានានូវស្ថិរភាពនៃការផ្គត់ផ្គង់ផលិតផលកសិកម្មទៅកាន់ទីផ្សារ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងគោលដៅបង្កើនសហគ្រិនភាព និងមានលក្ខណៈជាអាជីពក្នុងអាជីវកម្មកសិកម្ម។ ជាមួយគ្នានេះ ការលើកកម្ពស់អភិវឌ្ឍន៍បច្ចេកវិទ្យា ការជំរុញកសិកម្មវៃឆ្លាត ការស្រាវជ្រាវ ព្រមទាំងបច្ចេកទេសប្រតិបត្តិនៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្មកសិកម្ម ដែលឆ្លើយតបចំពោះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុត្រូវបាន និងកំពុងជំរុញឱ្យអនុវត្តយ៉ាងល្អប្រសើរ។

## ១.១. សារបាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ផ.យ.អ.វ.ក) ដែលគ្របដណ្តប់រយៈពេលមធ្យម៥ឆ្នាំ (២០១៩-២០២៣) ហើយផែនការយុទ្ធសាស្ត្រនេះ គឺជាការបន្តការអនុវត្តនៃ ផ.យ.អ.វ.ក ២០១៤-២០១៨។ ដោយអនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលអាណត្តិទី៦នៃរដ្ឋសភា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធកម្ម និងកសិ-ពាណិកម្ម ដោយបានជំរុញការអនុវត្តនូវវិធានការចាំបាច់មួយចំនួនរួមមាន ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្ម សំដៅបង្កើនទិន្នផលដំណាំ និងបន្សាំការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រង និងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ការគ្រប់គ្រង និងអភិវឌ្ឍន៍ដំណាំកៅស៊ូ ព្រមទាំងការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព មានការប្រកួតប្រជែងខ្ពស់ បរិយាប័ន្ន និងនិរន្តរភាព។

ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្រប ក្នុងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើតការងារ បង្កើនប្រាក់ចំណូលជូនប្រជាកសិករ និងបន្តជំរុញការធ្វើកសិ-ពាណិជ្ជកម្ម។

ការកំណត់ទិសដៅយុទ្ធសាស្ត្ររួមរបស់ក្រសួង សម្រាប់អនុវត្តរយៈពេល៥ឆ្នាំកន្លងទៅ (ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨) គឺ៖ "ជំរុញកំណើនកសិកម្មប្រចាំឆ្នាំឱ្យបានក្នុងរង្វង់៥% តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព"។ ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តកម្មវិធីជាយុទ្ធសាស្ត្រចំនួន៥ ដូចខាងក្រោម៖

***កម្មវិធីទី១៖ បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម***

គោលដៅនៃកម្មវិធីនេះគឺត្រូវជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព។

***កម្មវិធីទី២៖ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ***

គោលដៅនៃកម្មវិធីនេះគឺត្រូវជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវនិងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វផលិតផលសត្វប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ។

***កម្មវិធីទី៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព***

គោលដៅនៃកម្មវិធីនេះគឺត្រូវបង្កើនការការពារ និងអភិរក្សធនធានជលផល ដោយលុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រង១០០សហគមន៍នេសាទ និងជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន

១៥% រៀងរាល់ឆ្នាំ ដើម្បីធានាឱ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផលផលិតផលជលផលសម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។

*កម្មវិធីទី៤៖ ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព*

គោលដៅនៃកម្មវិធីនេះគឺត្រូវបង្កើនការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើឱ្យបាន ២០ សហគមន៍ក្នុងមួយឆ្នាំ។

*កម្មវិធីទី៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស*

គោលដៅនៃកម្មវិធីនេះគឺត្រូវបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយនិរន្តរភាព។

សម្រាប់រយៈពេល៥ឆ្នាំខាងមុខ (២០១៩-២០២៣) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំរចនាសម្ព័ន្ធកម្មវិធីជាអាទិភាពចំនួន៥ដដែល ដោយសម្រួចគោលដៅឱ្យស្របនឹងគោលនយោបាយដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។

## ១.២. អាទិភាពសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មសម្រាប់រយៈពេល៥ឆ្នាំខាងមុខ

វិស័យកសិកម្មនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការអភិវឌ្ឍជនបទ ជាពិសេសបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ដោយសារការវិវឌ្ឍសេដ្ឋកិច្ច និងកំណើននៃផលិតកម្ម គោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន០២ត្រូវបានកំណត់ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មគឺ៖

*(ទី១) បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម*

គោលដៅនេះគឺតម្រង់ឆ្ពោះទៅលើការជំរុញផលិតកម្មកសិកម្មតាមលក្ខណៈទំនើប និងយន្តូបនីយកម្មជំនួសឱ្យការថយចុះនៃកម្លាំងពលកម្មកសិកម្ម មានលក្ខណៈសន្សំសំចៃ ធ្វើឱ្យថ្លៃដើមផលិតទាប ធ្វើពិពិធកម្មទៅរកមុខដំណាំដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ផ្តល់ប្រាក់ចំណេញច្រើនសម្រាប់កសិករ សហគមន៍កសិកម្ម ដែលនឹងនាំដល់ការប្រកួតប្រជែងទីផ្សារខ្ពស់ ព្រមទាំងដំណើរការកសិ-ធុរកិច្ចមានលក្ខណៈបរិយាប័ន្ន ប្រសិទ្ធភាពសេដ្ឋ-កិច្ច និងនិរន្តរភាព។

*(ទី២) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផល ប្រកបដោយនិរន្តរភាព*

គោលដៅនេះគឺតម្រង់ឆ្ពោះទៅលើការអភិរក្ស និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។ ក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ សមត្ថភាពបច្ចេកទេសក្នុងការគ្រប់គ្រងនឹងត្រូវបានបង្កើនឡើងជាចាំបាច់ ដើម្បីធានាតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សស្របតាមគោលការណ៍កំណត់ជាធរមាន។

ដើម្បីសម្រេចបាននូវគោលដៅគោលនយោបាយអាទិភាពខាងលើ យុទ្ធសាស្ត្រចំនួន៥នឹងត្រូវបានដាក់ចេញឱ្យអនុវត្តក្នុងរយៈពេល៥ឆ្នាំខាងមុខនេះគឺ៖

*(១) បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិ-ធុរកិច្ច*

*(២) លើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម*

*(៣) ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព*

*(៤) ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព*

*(៥) បង្កើនប្រសិទ្ធភាពនៃការពង្រឹងការគ្រប់គ្រងស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស*

**ចក្ខុវិស័យ**

កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។

**បេសកកម្ម**

ផ្តល់សេវាគាំទ្រមានគុណភាពខ្ពស់ មានលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បទដ្ឋានគតិយុត្ត និងគោលនយោបាយច្បាស់លាស់សម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

**គោលបំណងយុទ្ធសាស្ត្រ**

ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។

**គោលដៅយុទ្ធសាស្ត្រ**

(ទី១) បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម

(ទី២) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។

| យុទ្ធសាស្ត្រទី១ | យុទ្ធសាស្ត្រទី២ | យុទ្ធសាស្ត្រទី៣ | យុទ្ធសាស្ត្រទី៤ | យុទ្ធសាស្ត្រទី៥ |
| --- | --- | --- | --- | --- |
| បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និង ពង្រីកកសិ-ធុរកិច្ច | លើកកម្ពស់សុខភាពសត្វ និង ផលិតកម្មសត្វជាលក្ខណៈ ពាណិជ្ជកម្ម | ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល ប្រកបដោយនិរន្តរភាព | ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព | បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស |

**កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរបស់កម្មវិធីទាំង៥**

យុទ្ធសាស្ត្រទាំង៥ខាងលើនេះនឹងត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ដោយមានកម្មវិធីទាំង៥របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាតួអង្គសំខាន់សម្រាប់ប្រតិបត្តិ និងគ្រប់គ្រងដោយអង្គភាពថវិការបស់ក្រសួង។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តជំរុញការបង្កើនផលិតភាព គុណភាព និងពិពិធកម្មកសិកម្ម តាមរយៈការបង្កើនការវិនិយោគប្រកបដោយប្រសិទ្ធភាព លើការស្រាវជ្រាវ និងការអភិវឌ្ឍពូជដំណាំ ពូជសត្វ បង្កើនការចញ្ចឹមត្រីដែលផ្តល់តម្លៃបន្ថែមខ្ពស់ ជាមួយនឹងបច្ចេកវិទ្យាវៃឆ្លាត ឌីជីថល និងទាន់សម័យ ជំរុញការផ្សព្វផ្សាយកសិករនៅទីជនបទដែលខ្វះជំនាញបច្ចេកទេស ការតភ្ជាប់រវាងសហព័ន្ធឬសហគមន៍កសិកម្ម និងវិស័យឯកជន តាមរយៈយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា លើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពលើការប្រើប្រាស់ទឹក ព្រមជាមួយនឹងការពង្រីកផ្ទៃដីស្រោចស្រព ការបន្តជំរុញ និងសម្របសម្រួលក្នុងការផ្តល់ប័ណ្ណកាន់កាប់

កម្មសិទ្ធិដីដល់កសិករ ការរៀបចំយុទ្ធសាស្ត្រទ្រទ្រង់ដល់ការផ្តល់សេវាធានារ៉ាប់រងផលិតកម្មកសិកម្ម ការពង្រឹងយន្តការនៃការអនុវត្តកសិកម្មល្អ និងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនៃផលិតផលកសិកម្ម។

បន្ថែមលើសពីនេះ ក្រសួងនឹងជំរុញនិងលើកកម្ពស់កសិ-ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម តាមរយៈការពង្រីកឱ្យមានការវិនិយោគឯកជនលើផលិតកម្មកសិកម្មដែលមានសក្តានុពលដូចជា ស្រូវ ពោត ដំឡូងមី ពពួកសណ្តែក បន្លែ ស្វាយ ស្វាយចន្ទី ម្រេច ចេក កៅស៊ូ សត្វ និងផលិតផលសត្វ ផលិតផលជលផលជាដើម ដោយបន្តផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ ការកាត់បន្ថយថ្លៃអគ្គិសនី អត្រាការប្រាក់ និងចំណាយឡជីស្ទីក ពិសេសជំរុញគម្រោងសាងសង់ឃ្លាំងស្តុក និងឡសម្ងួតបន្ថែមពីគម្រោងអន្តរាគមន៍របស់រាជរដ្ឋាភិបាល តាមរយៈយន្តការនៃការវិនិយោគរួមគ្នារវាងវិស័យសាធារណៈ និងវិស័យឯកជន ឬហិរញ្ញប្បទានពីបរទេស ព្រមទាំងបង្កើនការបណ្តុះបណ្តាលធនធានមនុស្សលើផ្នែកកែច្នៃផលិតផលកសិ-ឧស្សាហកម្ម។

ម្យ៉ាងវិញទៀត ក្រសួងនឹងបន្តការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល ព្រៃឈើ និងសត្វព្រៃឱ្យមាននិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ ជំរុញវារីវប្បកម្ម ការដាំដុះឈើឡើងវិញ ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ ព្រមទាំងពង្រឹងសមត្ថភាពសហគមន៍ឱ្យមានជីវភាពកាន់តែប្រសើរឡើង។

## ១.៣. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ និងគោលនយោបាយដើម្បីជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ខាងក្រោមនេះគឺជាការសង្ខេបក្របខ័ណ្ឌយុទ្ធសាស្ត្រគន្លឹះសំខាន់ៗ ដែលពាក់ព័ន្ធជាមួយការអភិវឌ្ឍវិស័យកសិកម្ម។

### ១.៣.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៩-២០២៣) ត្រូវបានដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាលអាណត្តិទី៦នៃរដ្ឋសភា។ យុទ្ធសាស្ត្ររយៈពេលមធ្យមនេះ បានបង្ហាញនូវការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលលើការបង្កើតការងារ និងការគាំទ្រដល់ការងារកសិកម្ម ដែលជាផ្នែកនៃចំណុចកណ្តាលរបស់យុទ្ធសាស្ត្រ ដោយរក្សានូវគោលដៅនៃការលូតលាស់ ការបង្កើតការងារ សមធម៌ និងប្រសិទ្ធភាពការងារ ព្រមទាំងផ្តោតជាសំខាន់អំពីផលិតភាព ការប្រកួតប្រជែង និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន។

នៅក្នុងអាណត្តិទី៦នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលក្នុងចតុកោណទី៤ មានមុំបួន រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើ៖ ១) ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ២) ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព ៣) ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម ៤) ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ចតុកោណទី៤នេះគឺជាក្របខ័ណ្ឌមូលដ្ឋានដើម្បីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំអភិវឌ្ឍក្នុងវិស័យនេះសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។

លើសពីនេះទៅទៀត ដោយសារចរន្តនៃការរីកចម្រើនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃ "បដិវត្តន៍ឧស្សាហកម្មទី៤" ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំផែនការអនុវត្តដោយដាក់បញ្ចូលនូវបច្ចេកវិទ្យានេះជាគន្លឹះនាំមុខដ៏ចម្បងមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងបង្កើនកាលានុវត្តភាពសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម។ ការរីកចម្រើនផ្នែកយន្តូបនីយកម្មកសិកម្ម ជួយជំរុញល្បឿនផលិតកម្ម និងការកែច្នៃ ហើយអាចបង្វែរកម្លាំងពលកម្មទៅផ្នែកឧស្សាហកម្ម និងសេវាកម្មផ្សេងៗទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់យុទ្ធសាស្ត្រសម្រាប់ធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងពិពិធកម្មផលិតកម្មសត្វ និងបសុព្យាបាល អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់លើការកែទម្រង់ជលផល និងព្រៃឈើ ដើម្បីចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ ដើម្បីសម្រេចបាននូវគោលបំណងនេះ រាជ-រដ្ឋាភិបាល តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើនការប្រើប្រាស់ធនធានក្នុងស្រុក រួមផ្សំជាមួយធនធានថវិកា និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តកសិកម្មទំនើប ហើយដោះស្រាយបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជាផ្លូវថ្នល់ជនបទ ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ឥណទាន ទីផ្សារ និងការកែច្នៃកសិផលសម្រាប់នាំចេញ ដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញផលិតផលកសិកម្ម។

ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នេះ បានរក្សាទុកកម្មវិធីទាំង ៥ ប៉ុន្តែពង្រីកវិសាលភាពសម្រិតសម្រាំងបន្ថែម និងធ្វើអាទិភាវូបនីយកម្ម ព្រមទាំងកែលម្អកម្មវិធី និងយន្តការអនុវត្តឱ្យកាន់តែប្រសើរថែមទៀត។ ជាមួយគ្នានេះដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានបន្តយកចិត្តទុកដាក់លើវិស័យអាទិភាពដែលពាក់ព័ន្ធការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈ (១).ការបង្កើនតម្លៃបន្ថែមនៃការផលិត និងការនាំចេញផលិតផលកសិកម្ម (២).ការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្មដែលទីផ្សារត្រូវការ (៣).ការជំរុញលើកទឹកចិត្តដល់ការវិនិយោគក្នុងផ្នែកកសិ-ឧស្សាហកម្ម (៤).ការបង្កើនផលិតភាព ទំនើបកម្មកសិកម្ម និងការលើកកម្ពស់កសិ-ពាណិជ្ជកម្មឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

### ១.៣.២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

ក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដោយបានផ្តោតអាទិភាពលើបណ្តាចំណុចមួយចំនួនពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម៖

ទី១-ការជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តនូវ "ផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មឆ្ពោះទៅឆ្នាំ ២០៣០" និង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣"។

ទី២-ការបន្តជំរុញការរៀបចំ អនុម័ត និងការអនុវត្ត "ច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ" និង "ច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា"។

ទី៣-ការបង្កើនផលិតភាព គុណភាព និងពិពិធកម្ម តាមរយៈការបង្កើនការវិនិយោគលើការស្រាវជ្រាវ និងការអភិវឌ្ឍពូជដំណាំ ពូជសត្វ និងការចិញ្ចឹមត្រីដែលផ្តល់តម្លៃបន្ថែមខ្ពស់ ការជំរុញការអភិវឌ្ឍកសិដ្ឋានគំរូ ការជំរុញការផ្តល់សេវាបច្ចេកទេសកសិកម្មសមស្រប ការពង្រឹងការគ្រប់គ្រងសហគមន៍កសិកម្ម ការរៀបចំយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបន្តកាត់បន្ថយថ្លៃដើមផលិតកម្មនិងកែច្នៃ ការពង្រឹងគុណភាពនៃធាតុចូលកសិកម្ម ការសិក្សារៀបចំឱ្យមានសេវាធានារ៉ាប់រងផលិតកម្មកសិកម្ម និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឆ្លាត និងឌីជីថល។

ទី៤-ការលើកកម្ពស់ឧស្សាហកម្មកែច្នៃ តាមរយៈការជំរុញឱ្យមានការវិនិយោគឯកជនលើកសិផលដែលមានសក្តានុពល ដូចជាៈ ស្រូវ ដំឡូងមី ស្វាយ ស្វាយចន្ទី ចេក កៅស៊ូ ម្រេច បន្លែ ជាដើម តាមរយៈការរៀបចំយុទ្ធ-សាស្ត្រតាមមុខដំណាំនីមួយៗ។

ទី៥-ការបន្តជំរុញការដាំបន្លែគ្រប់ប្រភេទជំនួសឱ្យការនាំចូល និងការរៀបចំបង្កើតទីផ្សារបោះដុំ និងចែកចាយបន្លែដែលមានស្តង់ដា និងអនាម័យខ្ពស់។

ទី៦-ការជំរុញពាណិជ្ជូបនីយកម្មកសិកម្ម តាមរយៈការបន្តពង្រឹងប្រព័ន្ធអនាម័យ និងភូតគាមអនាម័យ (SPS) ការសម្រួលពាណិជ្ជកម្ម ការវិនិយោគបន្ថែមលើមន្ទីរពិសោធន៍គុណភាព សុវត្ថិភាព សម្រាប់ការនាំចេញ ព្រមទាំងការជំរុញការផលិត និងប្រើប្រាស់ផលិតផលកសិកម្មក្នុងស្រុក។

ទី៧-ការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម តាមរយៈការបន្តអនុវត្ត "ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ" "ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥" និង "ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០៣០"។

ទី៨-ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ការបន្តជំរុញការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការបន្តផ្តល់ដីសម្បទានសង្គមកិច្ច ជាពិសេសដល់គ្រួសារក្រីក្រសម្រាប់ការធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

ទី៩-ការធ្វើវិចារណកម្មក្នុងការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ដោយយកចិត្តទុកដាក់លើការបង្កើនការតភ្ជាប់ទៅនឹងផលិតកម្មកសិកម្ម ការថែទាំជាប្រព័ន្ធ និងការពង្រឹងការគ្រប់គ្រង។

ទី១០-ការបន្តជំរុញការអភិវឌ្ឍជនបទឱ្យរស់រវើក ដោយបន្តវិនិយោគលើផ្លូវជនបទ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ការពង្រីកការគ្របដណ្តប់ការប្រើប្រាស់អគ្គិសនី ការពង្រីកការទទួលបានទឹកស្អាត ការលើកកម្ពស់អនាម័យ ការរៀបចំភូមិ និងលំនៅឋាន ព្រមទាំងការលើកកម្ពស់ជីវភាពប្រជាជន តាមរយៈការបន្តអនុវត្ត "ចលនាភូមិមួយ-ផលិតផលមួយ" និង "ចលនាភូមិថ្មី"។

### ១.៣.៣. ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣)

រាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងការប្រប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣។ ផែនការយុទ្ធសាស្ត្រនេះបានដាក់ចេញនូវសកម្មភាពអាទិភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងការត្រៀមលក្ខណៈក្នុងការកាត់បន្ថយផលប៉ះពាល់មកលើការអភិវឌ្ឍរបស់វិស័យកសិកម្ម និងការចូលរួមចំណែកជាមួយសហគមន៍អន្តរជាតិដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានចាត់វិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដោយបានបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ផ.យ.អ.វ.ក) ២០១៩-២០២៣។ ផ.យ.អ.វ.ក បានបញ្ជ្រាបដល់អង្គភាពក្រោមឱវាទអំពីបញ្ហាប្រែប្រួលអាកាសធាតុ ហើយក្រសួងបានប្រើប្រាស់ជាគោលការណ៍ណែនាំ និងជាជំនួយស្មារតីសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានា ក៏ដូចជាវិស័យឯកជន ដើម្បីកំណត់នូវវិធានការសមស្រប និងសកម្មភាពជាក់ស្តែងពាក់ព័ន្ធនឹងការងារបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៅកម្តៅ ការរាំងស្ងួត និងទឹកជំនន់ជាដើម។

ការប្រែប្រួលអាកាសធាតុ ជាបញ្ហាចម្បងមួយដែលបានជះឥទ្ធិពលយ៉ាងខ្លាំងលើភពផែនដី និងបានទាញនូវការចាប់អារម្មណ៍ជាសាកលពីស្ថាប័នជាតិ និងអន្តរជាតិជាច្រើន ក្នុងការរៀបចំនូវយន្តការការងារដ៏មានប្រសិទ្ធភាព ដើម្បីបន្សាំទៅនឹងការវិវត្តនៃធម្មជាតិ និងកាត់បន្ថយនូវបណ្តាសកម្មភាពទាំងឡាយណា ដែលបានបង្កនូវឥទ្ធិពលអវិជ្ជមានលើបរិស្ថាន សំដៅរក្សាបាននូវនិរន្តរភាពនៃការអភិវឌ្ឍ។ យន្តការការងារត្រូវបានដាក់ចេញជាសាកលតំបន់ អនុតំបន់ និងថ្នាក់ជាតិ ដើម្បីស្វែងរកនូវដំណោះស្រាយរួមមួយ ក្នុងការថែរក្សានូវលំនឹងបរិស្ថានធម្មជាតិ ដែលរងនូវឥទ្ធិពលពីសកម្មភាពអភិវឌ្ឍន៍នានា។ បញ្ហាដែលប្រឈមក្នុងការអភិវឌ្ឍវិស័យកសិកម្ម ព្រៃឈើ និងជលផលគឺជាបាតុភូតធម្មជាតិដែលរួមមានការប្រែប្រួលសីតុណ្ហភាព សំណើម រដូវកាល របបទឹកភ្លៀង គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះជាដើម។

ជាមួយគ្នានេះដែរ សកម្មភាពមួយចំនួនដូចជាការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ការធ្វើកសិកម្មពនេចរ ការភ្ជួររាស់លើដីជម្រាល ប្រព័ន្ធកសិកម្មមិនសមស្រប ការប្រើប្រាស់ទឹកស្រោចស្រពមិនបានត្រឹមត្រូវ ការគ្រប់គ្រងកាកសំណល់សត្វមិនបានល្អ ការប្រើប្រាស់ថ្នាំ និងជីកសិកម្មដែលមិនអនុលោមទៅតាមបទដ្ឋានបច្ចេកទេស។ល។ ក៏បានរួមចំណែកធ្វើឱ្យមានការប្រែប្រួលអាកាសធាតុផងដែរ។

ក្នុងដំណាក់កាលដែលប្រទេសកម្ពុជា បាននិងកំពុងប្រឈមនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាអវិជ្ជមានទាំងនោះ ហើយក្នុងនាមជាភាគីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ កម្ពុជាក៏បានខិតខំអនុវត្តអនុសញ្ញា និងពិធីសារនេះផងដែរ។ ដើម្បីមានយន្តការអនុវត្តឱ្យបានពេញលេញ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុតាមអនុក្រឹត្យលេខ៩៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ដើម្បីរៀបចំ សម្របសម្រួល និងពិនិត្យលើការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ កម្មវិធីនានា សំដៅឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ រួមចំណែកការពារបរិស្ថាន ធនធានធម្មជាតិ និងសុខុមាលភាពប្រជាពលរដ្ឋ។

ដោយឡែក ក្នុងការបន្តអភិវឌ្ឍន៍វិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់នូវគោលនយោបាយតម្រង់ទិស ឆ្ពោះទៅរកការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងបានរៀបចំកសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ ក្នុងគោលបំណងជាសំខាន់គឺសំដៅធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីនិងគម្រោងនានាស្តីពីការប្រែប្រួលអាកាសធាតុ ដោយរួមបញ្ចូលទាំងផែនការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យកសិកម្ម។ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនេះ នឹងចូលរួមជាវិភាគទានដ៏សំខាន់មួយ ក្នុងដំណើរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងជំរុញការអនុវត្តផែនការសកម្មភាពនានា សំដៅបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ផែនការយុទ្ធសាស្ត្រនេះ មានគោលដៅសំខាន់គឺ "ចូលរួមចំណែកជួយកាត់បន្ថយផលប៉ះពាល់ និងឥទ្ធិពលអវិជ្ជមានទាំងឡាយលើវិស័យកសិកម្មដំណាំ ផលិតកម្មសត្វ ព្រៃឈើ និងជលផល ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ សំដៅស្តារនូវការខូចខាត និងការបាត់បង់ផលប្រយោជន៍នានា តាមរយៈការបង្កើនវិធានការបន្សាំ និងវិធានការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការឡើងកំដៅនៃភពផែនដី"។

### ១.៣.៤. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ បានចែងយ៉ាងច្បាស់អំពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃសកលសមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រីកភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើប ដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យានិងចំណេះដឹង។ ការសម្រេចបាននូវចក្ខុវិស័យនេះ នឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការទ្រទ្រង់ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន ការបង្កើតការងារជូនពលករកម្ពុជា ការបង្កើតតម្លៃបន្ថែមសម្រាប់សេដ្ឋកិច្ចជាតិ និងការបង្កើនប្រាក់ចំណូលសមស្របជូនប្រជាជនកម្ពុជា។ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ គឺផ្តល់នូវក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌសម្របសម្រួលការអនុវត្ត និងការរៀបចំយន្តការស្ថាប័ន សម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា។ កម្មវត្ថុសំខាន់នៃគោលនយោបាយនេះ គឺការ

ដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មឱ្យស្របតាមសក្ដានុពល ឧត្តមភាពប្រកួតប្រជែង និងសភាពការណ៍វិវត្តន៍នៃឧស្សាហកម្មកម្ពុជា។ គោលនយោបាយនេះត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ដើម្បីធ្វើយ៉ាងណាឱ្យវិស័យនេះស្របជាមួយនឹងការអភិវឌ្ឍកសិ-ឧស្សាហកម្មទំនើប និងបានដាក់បញ្ចូលកម្មវិធីសំខាន់ស្របតាមចរន្តនៃបដិវត្តន៍ឧស្សាហកម្មទី៤ ជាផ្នែកមួយដែលគាំទ្រដល់អ្នកផលិតឱ្យមានប្រសិទ្ធភាព និងផលិតភាពខ្ពស់ដោយប្រើប្រាស់នូវការវិវឌ្ឍបច្ចេកវិទ្យាឌីជីថល ព្រមជាមួយយន្តូបនីយកម្មទំនើប។

### ១.៣.៥. កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី (២០១៨-២០២៧)

កម្ពុជាកំពុងប្រឈមនឹងបញ្ហាធ្លាក់ចុះនៃគុណភាពដី។ ជាមួយគ្នានោះ ការប្រកួតប្រជែងរបស់វិស័យអភិវឌ្ឍន៍ផ្សេងទៀត បានធ្វើឱ្យរួមតូចនូវទំហំដីកសិកម្មដែលមានស្រាប់ ហើយការពង្រីកដីកសិកម្មថ្មីក៏កំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងព្រៃឈើផងដែរ។ បញ្ហាប្រឈមដ៏សំខាន់មួយទៀត គឺកំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាពលរដ្ឋ ដែលបង្កើនសម្ពាធយ៉ាងខ្លាំងដល់វិស័យកសិកម្ម និងធនធានធម្មជាតិ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឋានៈជាក្រសួងបង្គោលសម្រាប់អនុវត្តអនុសញ្ញាសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម បានរៀបចំចងក្រងកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ក្នុងគោលបំណងសំខាន់គឺរួមចំណែកទប់ស្កាត់ និងដោះស្រាយបញ្ហាធ្លាក់ចុះនៃគុណភាពដីសំដៅថែរក្សាធនធានធម្មជាតិ បង្កើនផលិតភាពដី កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងអភិវឌ្ឍប្រទេសជាតិ ព្រមទាំងចូលរួមអនុវត្តកាតព្វកិច្ចនៅក្នុងអនុសញ្ញាសហប្រជាជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម។

អនុសញ្ញានេះបានកំណត់ថា កម្មវិធីសកម្មភាពជាតិស្ថិតនៅជាស្នូលរបស់អនុសញ្ញា និងបង្កើតបានជាក្របខ័ណ្ឌទស្សនទាន និងក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តនៅកម្រិតជាតិនិងតំបន់។ គោលបំណងនៃកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី គឺកំណត់អំពីកត្តានានាដែលអាចឈានដល់ការកើតមានរហោស្ថានកម្ម និងវិធានការចាំបាច់ជាក់ស្តែងនានា ក្នុងការទប់ស្កាត់ ឬកាត់បន្ថយបញ្ហានេះ។ អនុសញ្ញានេះបានបញ្ជាក់ថា ប្រទេសរងគ្រោះគួរបញ្ជ្រាប និងអនុវត្តកម្មវិធីសកម្មភាពជាតិ ដោយមានការចូលរួមពេញលេញរបស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា។ ជាងនេះទៅទៀត កម្មវិធីសកម្មភាពជាតិគួរត្រូវបានបញ្ចូលគ្នាជាមួយនឹងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗទៀត។ ជាពិសេស សកម្មភាពនេះបានត្រូវយកមកធ្វើសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣។ កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី មានចក្ខុវិស័យ បេសកកម្ម និងគោលបំណងដូចខាងក្រោម៖

កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនិងការធ្លាក់ចុះនៃគុណភាពដី មានចក្ខុវិស័យធ្វើការគ្រប់គ្រងដីដោយប្រសិទ្ធភាព និងចីរភាព សំដៅរក្សា និងបង្កើនផលិតភាពដី ឆ្លើយតបនឹងតម្រូវការក្នុងការអភិវឌ្ឍវិស័យកសិកម្ម ផលិតកម្មស្បៀង ការកែលម្អស្ថានភាពនៃជីវិតរស់នៅរបស់ប្រជាជន ព្រមទាំងរួមចំណែកកាត់បន្ថយ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីធ្វើឱ្យសម្រេចនូវចក្ខុវិស័យនេះ កម្មវិធីសកម្មភាពជាតិនេះមានបេសកកម្មទប់ស្កាត់ការធ្លាក់ចុះនៃគុណភាពដី និងបង្កើនគុណភាពដី តាមរយៈការបង្កើតឱ្យមានក្របខ័ណ្ឌគោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការពង្រឹងសមត្ថភាពស្ថាប័ន ការកៀរគរធនធាន និងកិច្ចសហការជាមួយប្រទេសក្នុងតំបន់ និងពិភពលោកក្នុងក្របខ័ណ្ឌនៃការអនុវត្តអនុសញ្ញាសហប្រជាជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម ឬការធ្លាក់ចុះនៃគុណ

ភាពដី (UNCCD) អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងអនុសញ្ញាសហប្រជាជាតិស្តីពីជីវចម្រុះ (UNCBD)។

កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី មានគោលបំណងរួមចំណែកលុបបំបាត់ភាពក្រីក្រ និងអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយនិរន្តរភាព តាមរយៈការគ្រប់គ្រង ប្រើប្រាស់និងកែលម្អដី និងធនធានធម្មជាតិផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ព្រមទាំងកាត់បន្ថយ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែល្អប្រសើរឡើង។

ដើម្បីធ្វើឱ្យសម្រេចបាននូវគោលបំណងខាងលើ និងមានសង្គតិភាព ក៏ដូចជារួមចំណែកអនុវត្តយុទ្ធសាស្ត្រ១០ឆ្នាំ និងគោលដៅគ្មានកំណើនការធ្លាក់ចុះនៃគុណភាពដីរបស់អនុសញ្ញាសហប្រជាជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដីមានគោលដៅយុទ្ធសាស្ត្រចំនួន៥ដូចខាងក្រោម ៖

- ទី១. ធ្វើឱ្យមានភាពងាយស្រួលដល់ការពង្រីកការអនុវត្តបច្ចេកទេសគ្រប់គ្រងដីធ្លី ជាពិសេសដីកសិកម្មប្រកបដោយប្រសិទ្ធភាព និងមានចីរភាពស្របទៅតាមស្ថានភាពជាក់ស្តែងរបស់ទីតាំងមូលដ្ឋាននីមួយៗ។
- ទី២. បង្កើតភាពងាយស្រួលដល់អ្នកពាក់ព័ន្ធ ក្នុងការចូលរួមស្តារទីជម្រាល និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើ។
- ទី៣. ផ្តល់ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ពាក់ព័ន្ធ សម្រាប់ធានាដល់ការគ្រប់គ្រង និងប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព និងចីរភាព។
- ទី៤. ពង្រឹងសមត្ថភាពធនធានមនុស្សក្នុងការរៀបចំផែនការ និងការអនុវត្តជាក់ស្តែងលើការគ្រប់គ្រងដី និងទីជម្រាលប្រកបដោយចីរភាព។
- ទី៥. បង្កើតនិងអនុវត្តយុទ្ធសាស្ត្រកៀរគរធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពអាទិភាពនានា។

គោលដៅយុទ្ធសាស្ត្រទាំង៥ខាងលើនេះត្រូវបានយកមកអនុវត្ត ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ដែលមានទំនាក់ទំនងគ្នាជាប្រព័ន្ធក្នុងការធ្វើឱ្យសម្រេចនូវគោលដៅរួម។

## ១.៤. ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣

ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (**ផ.យ.អ.វ.ក**) ២០១៩-២០២៣ គឺដំណើរការប្រព្រឹត្តទៅតាមការចូលរួមពិភាក្សាជាមួយថ្នាក់ដឹកនាំ មន្ត្រីជំនាញក្រោមឱវាទក្រសួង និងអន្តរក្រសួង ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងផ្នែកពាក់ព័ន្ធផ្សេងៗ តាមការចូលរួមពិភាក្សាក្នុងអនុវិស័យទាំង៥របស់ក្រសួង ដោយវិភាគបញ្ហា ពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាង **ផ.យ.អ.វ.ក** ២០១៩-២០២៣។ ការចូលរួមដ៏សំខាន់បំផុតក្នុងការរៀបចំផែនការនេះ គឺការផ្តល់មតិយោបល់លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាច្រើនដំណាក់កាល។

ការរៀបចំផែនការយុទ្ធសាស្ត្រនេះក៏មានការសិក្សាស្រាវជ្រាវលើឯកសារ ព័ត៌មានថ្មីៗស្តីអំពីសេដ្ឋកិច្ចកសិកម្ម ធនធានធម្មជាតិ ការប្រែប្រួលអាកាសធាតុ យេនឌ័រ ព្រមទាំងការសិក្សាស្រាវជ្រាវឯកសារវិភាគទៅលើការប្រកួតប្រជែងទីផ្សារ ការវិនិយោគថ្មីៗលើវិស័យកសិកម្ម តម្រូវការរបស់កសិករក្នុងខ្សែច្រវាក់តម្លៃរបស់ផលិតផលកសិកម្ម។

### ១.៥. ទម្រង់របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនេះចែកចេញជា៧ជំពូក ដែលជំពូកទី១ អត្ថាធិប្បាយអំពីសារៈសំខាន់នៃការធ្វើផែនការយុទ្ធសាស្ត្រ អាទិភាពសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ទំនាក់ទំនងរវាងផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលបំណងយុទ្ធសាស្ត្ររបស់វិស័យកសិកម្ម ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងទម្រង់របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។

ជំពូកទី២ គឺជាការវិភាគស្ថានភាព សមិទ្ធផល និងបញ្ហាប្រឈម ដែលសិក្សានិងវិភាគអំពីស្ថានភាពទូទៅ សមត្ថភាពស្ថាប័នរបស់វិស័យកសិកម្ម និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ជំពូកទី៣ គឺជាទិសដៅយុទ្ធសាស្ត្រ ដែលនៅក្នុងជំពូកនេះបកស្រាយអំពីចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាទិភាពរបស់វិស័យកសិកម្ម បែងចែកតាមកម្មវិធី និងអនុកម្មវិធី និងក្របខ័ណ្ឌអាទិភាពអន្តរវិស័យ។

ជំពូកទី៤ អធិប្បាយអំពីការរៀបចំស្ថាប័នសម្រាប់អនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងនោះរួមមាន៖ ការរៀបចំសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម អន្តរវិស័យ និងការរៀបចំកម្មវិធី និងផែនការថវិកា។

ជំពូកទី៥ យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ក្នុងនោះរួមមានការប៉ាន់ស្មានហិរញ្ញប្បទានលើថវិកាជាតិ និងថវិកាពីដៃគូអភិវឌ្ឍន៍ គម្លាតធនធានដែលត្រូវការ និងយុទ្ធសាស្ត្រក្នុងការកៀរគរធនធានបំពេញគម្លាត ការប៉ាន់ស្មានចំណាយប្រចាំឆ្នាំ (ចំណាយមូលធន និងចំណាយចរន្ត) ទំនាក់ទំនងផែនការហិរញ្ញវត្ថុរបស់វិស័យកសិកម្ម ជាមួយចំណាយប៉ាន់ស្មានរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងក្របខ័ណ្ឌចំណាយមធ្យមរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ដែលទាក់ទងជាមួយសូចនាករ និងប្រភពធនធាន។

ជំពូកទី៦ បង្ហាញអំពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងជំពូកទី៧ គឺជាសេចក្តីសន្និដ្ឋាន។

# ជំពូកទី២ : ការវិភាគស្ថានភាព (សមិទ្ធផល និងបញ្ហាប្រឈម)

## ២.១. ស្ថានភាពទូទៅរបស់វិស័យកសិកម្ម

ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជានឹងឈានដល់ដំណាក់កាលប្រែប្រួលថ្មីមួយទៀត ដែលជាអន្តរកាលឆ្ពោះទៅរកការសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់សម្រាប់រយៈពេលមធ្យមខាងមុខ។ ដើម្បីសម្រេចបាននូវកិច្ចការនេះ ទាមទារឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកចិត្តទុកដាក់ពង្រឹងបន្ថែមទៀត នូវគោលនយោបាយ យន្តការនិងរចនាសម្ព័ន្ធអនុវត្ត សំណុំវិធានច្បាប់ ធនធានមនុស្ស មធ្យោបាយ និងធនធានហិរញ្ញវត្ថុ ដើម្បីដំណើរការអភិវឌ្ឍន៍កសិកម្មតាមបែបទំនើបភាវូបនីយកម្ម និងរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះតម្រូវការ ការរំពឹងទុករបស់រាជរដ្ឋាភិបាល អ្នកទទួលផលពីវិស័យកសិកម្ម និងប្រជាកសិករនៅជនបទ ដោយទាញយកផលប្រយោជន៍ជាអតិបរិមាពីការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម ជាពិសេសពីបរិការណ៍នៃបដិវត្តន៍ឧស្សាហកម្មទី៤។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រចនាសម្ព័ន្ធសេដ្ឋកិច្ចបានផ្លាស់ប្តូរទៅរកវិស័យដែលមានតម្លៃបន្ថែមខ្ពស់ដូចជាឧស្សាហកម្ម និងសេវាកម្ម ហើយកម្លាំងពលកម្មដែលចូលរួមក្នុងវិស័យកសិកម្មមានការថយចុះពី ៤៨,៧% ក្នុងឆ្នាំ២០១៣ មកត្រឹម ៤១,៥% ក្នុងឆ្នាំ២០១៥ និងប្រមាណ ៣៧% ក្នុងឆ្នាំ២០១៧។ ទោះបីជាយ៉ាងនេះក្តី វិស័យកសិកម្មក៏នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ការអភិវឌ្ឍជនបទ ជាពិសេសបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនក្នុងចន្លោះពី៣% ទៅ៤% ក្នុងមួយឆ្នាំៗ។ ជាមួយគ្នានោះ ការចូលរួមចំណែកនៃផលិតកម្មដំណាំមានប្រហែល ៥៨,១% នៃផលិតផលកសិកម្មសរុបក្នុងឆ្នាំ២០១៨។ មិនត្រឹមតែប៉ុណ្ណោះ កម្ពុជាបានប្រែក្លាយពីប្រទេសខ្វះស្បៀង ទៅជាប្រទេសដែលមានស្បៀងសល់សម្រាប់ការនាំចេញ ជាមួយនឹងការលើកកម្ពស់កេរ្តិ៍ឈ្មោះអង្ករកម្ពុជាលើឆាកអន្តរជាតិជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ។

ផលិតកម្មសត្វក៏មានការរីកចម្រើនគួរជាទីពេញចិត្ត ពិសេសការកើនឡើងនៃកសិដ្ឋានចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានប្រមាណ ១៩% ធៀបនឹងផលិតកម្មសត្វសរុបក្នុងឆ្នាំ២០១៧ និងអនុវិស័យនេះក៏បានចូលរួមលើកកម្ពស់សន្តិសុខស្បៀង ទ្រទ្រង់ជីវភាពរបស់កសិករក្រីក្រ និងជាប្រភពក្នុងការផ្តល់ប្រាក់ចំណូល អាហារូបត្ថម្ភ ប្រភពថាមពលកកើតឡើងវិញ និងជីសរីរាង្គ។ ចំពោះការកែទម្រង់លើវិស័យព្រៃឈើ និងជលផលក៏មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ផងដែរ។ ទន្ទឹមនឹងនោះ ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការពារ និងអភិរក្សបរិស្ថានធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ជីវចម្រុះ ព្រៃឈើ និងជម្រកសត្វ ព្រមទាំងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុក៏បានទទួលលទ្ធផលជោគជ័យ បើទោះបីជាមានបញ្ហាប្រឈមមួយចំនួនក្តី។

ក្នុងបរិបទនៃការលើកស្ទួយវិស័យកសិកម្ម រាជរដ្ឋាភិបាលបានផ្តោតលើគោលដៅនៃចតុកោណចំនួន៤ ដែលក្នុងនោះចតុកោណទី៤ ដែលមានមុំ៤ជាគោលដៅយុទ្ធសាស្ត្រសំខាន់រួមមាន៖ (១) ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ (២) ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព (៣) ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម (៤) ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ទោះជាយ៉ាងនេះក្តី វិស័យកសិកម្មកម្ពុជា នៅមានបញ្ហាប្រឈមមួយចំនួនដូចជា ភាពមានកម្រិតនៃផលិតភាព ការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសក្នុងការផលិត កែច្នៃ ការដឹកជញ្ជូន អគ្គិសនី ទុនបង្វិល ឥណទាន ឃ្លាំងស្តុកឡសម្ងួត និងកត្តានាំចេញ ព្រមទាំងខ្សែច្រវាក់ផ្គត់ផ្គង់មិនទាន់មានភាពប្រទាក់ក្រឡាគ្នា ដែលកត្តាទាំងអស់នេះបានធ្វើឱ្យផលិតផលកសិកម្ម ក៏ដូចជាការចិញ្ចឹមសត្វ និងការធ្វើវារីវប្បកម្មរបស់កម្ពុជាទទួលបានតម្លៃបន្ថែមទាប និងមានការពិបាកប្រកួតប្រជែងជាមួយនឹងបណ្តាប្រទេសនាំចេញដទៃទៀត។

ជាមួយនឹងការដោះស្រាយបញ្ហាប្រឈមខាងលើនេះ រាជរដ្ឋាភិបាលបានតម្រង់ទិសនៃការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាឱ្យក្លាយជាកសិកម្មទំនើប ផលិតផលមានគុណភាពខ្ពស់ មានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ មានតម្លៃបន្ថែមខ្ពស់ មានភាពប្រកួតប្រជែង មានភាពចំណេញ និងជាឃ្លាំងសន្តិសុខស្បៀងជាតិប្រកបដោយសុវត្ថិភាព ជាមួយនឹងការអភិវឌ្ឍជនបទគ្រប់ជ្រុងជ្រោយ បង្កើនចំណូលដល់កសិករ និងជាមូលដ្ឋានក្នុងការជំរុញពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ដើម្បីឈានទៅចូលរួមទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចជាតិ។

ផ្អែកលើមូលដ្ឋានជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ដែលបានបង្ហាញជូនក្នុងផ្នែកទី១នៃយុទ្ធសាស្ត្រនេះ ក៏ដូចជាតម្រូវការនៃការអភិវឌ្ឍវិស័យកសិកម្ម ដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់ចេញនូវគោលដៅជាយុទ្ធសាស្ត្រតាមអនុវិស័យនីមួយៗ និងមានវិធានការជាក់ស្តែងជាអាទិភាពសម្រាប់អនុវត្តចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដែលជាត្រីវិស័យតម្រង់ទិសសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបន្តបំពេញភារកិច្ចចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍជនបទ។

ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ មានតួនាទីជាផែនទីបង្ហាញផ្លូវ និងជាឧបករណ៍គោលនយោបាយច្បាស់លាស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា សំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន និងសំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅគោលដៅចក្ខុវិស័យកម្ពុជា ២០៣០ និង២០៥០។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ត្រូវបានរៀបចំឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនូវទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយត្រូវពង្រឹងបន្ថែមទៀតនូវសមិទ្ធផលសម្រេចបានកន្លងមក តាមរយៈការអនុវត្តអភិក្រម "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នឹងលើកកម្ពស់វិស័យកសិកម្មឱ្យក្លាយទៅជាផ្នែកនាំមុខមួយដែលផ្តល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។

ដើម្បីសម្រេចបាននូវគោលបំណងនេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើនការប្រើប្រាស់ធនធានក្នុងស្រុក រួមផ្សំជាមួយធនធានថវិកា និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តកសិកម្មទំនើប ហើយដោះស្រាយបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជាផ្លូវថ្នល់ ធារាសាស្ត្រ អគ្គិសនី ឥណទាន ទីផ្សារ និងការកែច្នៃកសិផល ជាពិសេសការកែច្នៃសម្រាប់ការនាំចេញ ដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញផលិតផលកសិកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នេះ បានរក្សាទុកកម្មវិធីទាំង៥ ប៉ុន្តែពង្រីកវិសាលភាព សម្រិតសម្រាំងបន្ថែម និងធ្វើអាទិភាវូបនីយកម្ម ព្រមទាំងកែលម្អកម្មវិធី និងយន្តការអនុវត្តឱ្យកាន់តែប្រសើរឡើងថែមទៀត។ ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលក៏បានបន្តយកចិត្តទុកដាក់លើវិស័យអាទិភាពដដែល ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈ (១) ការបង្កើនតម្លៃបន្ថែមនៃការផលិត និងការនាំចេញផលិតផលកសិកម្ម (២) ការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្មដែលទីផ្សារត្រូវការ (៣) ការជំរុញការលើកទឹកចិត្តដល់ការវិនិយោគឯកជនក្នុងផ្នែកកសិ-ឧស្សាហកម្ម និង (៤) ការបង្កើនផលិតភាពទំនើបកម្មកសិកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម។

ដោយឡែក ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នេះក៏បានរៀបចំធ្វើឱ្យមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រជាតិដែលពាក់ព័ន្ធដទៃទៀតផងដែរ។ ជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្ត្រនេះនឹងក្លាយជាមគ្គុទ្ទេសក៍ច្បាស់លាស់ សម្រាប់តម្រង់ទិសសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគ្រប់តួអង្គអនុវត្តពាក់ព័ន្ធទាំងអស់ឱ្យស្ថិតក្នុងប្រព័ន្ធតែមួយ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាព និងការគ្រប់គ្រងធនធានដោយធានាបាននូវប្រសិទ្ធភាព។ នៅក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រ

អភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ក៏ជាផ្នែកមួយនៃកម្មវិធីនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាផងដែរ។

## ២.២. លទ្ធផលសម្រេចបាននៃ ផ.យ.អ.វ.ក (២០១៤ - ២០១៨)

វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២៣,៥% (ថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៨។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី ១៩ ៤៧០ពាន់លានរៀល នៅឆ្នាំ២០១៤ ដល់ ២១ ៩១៣ ពាន់លានរៀល នៅឆ្នាំ២០១៨ (ប្រភពទិន្នន័យពីក្រសួងផែនការ ២០១៨)។

នៅឆ្នាំ២០១៨នេះ អត្រានៃការចូលរួមចំណែករបស់អនុវិស័យក្នុងផលិតផលក្នុងស្រុកសរុបនៃវិស័យកសិកម្ម រួមមាន៖ ផ្នែកដំណាំ៥៣,១% ផ្នែកផលិតកម្មសត្វ១១,១% ផ្នែកជលផល២៤% និងផ្នែកព្រៃឈើ៦,៧%។ ជាការកត់សម្គាល់ ផលិតកម្មដំណាំនិងជលផល គឺជាកម្លាំងចលករនាំមុខក្នុងផលិតកម្មកសិកម្ម។ តាមរយៈលទ្ធផលកំណើនជាវិជ្ជមាននេះ គឺបានបញ្ជាក់ឱ្យឃើញថា វិស័យកសិកម្មបានអភិវឌ្ឍចំគោលដៅដែលបានគ្រោងទុក បើទោះបីជាវិស័យនេះទទួលរងនូវផលប៉ះពាល់ដោយសារតម្លៃកសិផលទាបនៅក្នុងទីផ្សារអន្តរជាតិ ការថយចុះកម្លាំងពលកម្មនៅជនបទ និងភាពងាយរងគ្រោះដោយកត្តាបម្រែបម្រួលអាកាសធាតុ និងកត្តាធម្មជាតិផ្សេងៗក៏ដោយ។ ផលិតកម្មសត្វគឺជាមុខព្រួញសំខាន់មួយទៀត ក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញ ដែលផ្នែកនេះត្រូវជំរុញអភិវឌ្ឍន៍ឱ្យបានខ្លាំងក្លាថែមទៀតផងដែរ។

ក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចប្រទេសកម្ពុជា កម្លាំងពលកម្មត្រូវបានបែងចែកជាបីប្រភេទសំខាន់គឺ៖ (ទី១) ពលកម្មក្នុងវិស័យកសិកម្ម (ទី២)ពលកម្មក្នុងវិស័យឧស្សាហកម្ម និង(ទី៣)ពលកម្មក្នុងវិស័យសេវាកម្ម។ ជាការសង្កេត ពលកម្មក្នុងវិស័យកសិកម្មបាន និងកំពុងធ្លាក់ចុះគួរឱ្យកត់សម្គាល់។ កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ ២០១៣ មានចំនួន ៤៨,៧% និង៣៧% នៅឆ្នាំ២០១៧ (ប្រភពទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ)។ ចរន្តនៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង និងទៅក្រៅប្រទេសកំពុងមាននិន្នាការកើនឡើង។

សារសំខាន់របស់វិស័យកសិកម្ម ត្រូវបានស្តែងឱ្យឃើញតាមរយៈក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាច្រើន ដែលបានផ្តោតជាសំខាន់លើការជំរុញ និងលើកស្ទួយវិស័យកសិកម្ម ជាមួយនឹងរបត់ថ្មីដើម្បីឈានឆ្ពោះទៅរកការពន្លឿនកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស។ បន្ថែមលើសពីនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលមានគោលដៅសំខាន់ពាក់ព័ន្ធនឹងវិស័យកសិកម្ម គឺត្រូវជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន ១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។ ក្នុងន័យនេះ ការធ្វើឱ្យប្រាកដនូវរាល់គោលដៅក្នុងការងារអភិវឌ្ឍន៍វិស័យកសិកម្ម កម្ពុជាត្រូវចាប់ច្បាមនូវកាលានុវត្តភាពនេះឱ្យបាន ជាពិសេសត្រូវធ្វើឱ្យកម្ពុជាមានឧត្តមភាពប្រកួតប្រជែងទីផ្សារក្នុងស្រុក និងការនាំចេញផលិតផលកសិកម្ម ទាំងក្នុងតំបន់និងពិភពលោក និងកាត់បន្ថយការនាំចូល។

ក្រសួងក៏បានទទួលស្គាល់ផងដែរថា ប្រព័ន្ធកសិកម្មនៅកម្ពុជាភាគច្រើនជាកសិកម្មផ្គត់ផ្គង់ក្នុងក្រុមគ្រួសារខ្លួនឯង ហើយនៅមានកង្វះខាតចំណេះដឹងអំពីកសិកម្មផ្គត់ផ្គង់ជាលក្ខណៈពាណិជ្ជកម្ម ដែលតែងតែទទួលរងនូវផលប៉ះពាល់ពីបាតុភូតធម្មជាតិជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដោយសារការដាំដុះរបស់កសិករភាគច្រើននៅមានការពឹងពាក់លើទឹកភ្លៀង និងការសាងសង់ប្រព័ន្ធស្រោចស្រពពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ និងកង្វះខាតនូវទំនាក់ទំនងជាមួយនឹងការយល់ដឹងអំពីទីផ្សារ និងការធ្វើកសិ-ពាណិជ្ជកម្ម។ ទាំងអស់នេះ ជាមូលហេតុមួយដែលធ្វើឱ្យផលិតកម្មកសិកម្មមានការប្រែប្រួលជារៀងរាល់ឆ្នាំ។

ក្នុងគោលបំណងធ្វើឱ្យសម្រេចបាននូវការធ្វើទំនើបភាវូបនីយកម្មកសិកម្ម ដែលអាចចូលរួមជួយដោះស្រាយបញ្ហាប្រឈមរបស់កសិករ និងសហគមន៍កសិកម្ម រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការប្រទាក់ក្រឡា

ចាំបាច់មួយចំនួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពទៅលើការកសាង ក៏ដូចជាកែលម្អហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗទាក់ទងទៅនឹងខ្សែច្រវាក់ផលិតកម្មកសិកម្ម និងការបង្កើនឧត្តមភាពប្រកួតប្រជែងនៅលើទីផ្សារដូចជា ឃ្លាំងស្តុកកសិផល ផ្លូវថ្នល់ ការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹក ការចែកចាយថាមពលអគ្គិសនី ការផ្តល់សេវាបច្ចេកទេស ការកែលម្អធាតុចូលកសិកម្ម ការកែទម្រង់ការគ្រប់គ្រងដីធ្លី និងហិរញ្ញវត្ថុក្នុងការវិនិយោគ ការរៀបចំយន្តការនានាឆ្ពោះទៅដណ្តើមទីផ្សារ ការរៀបចំនិងអភិវឌ្ឍសហគមន៍កសិកម្ម និងពង្រឹងយន្តការសម្របសម្រួលស្ថាប័ន។

## ២.២.១. ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម

នាពេលកន្លងទៅនេះ ក្រសួងបានប្រកាសដាក់ឱ្យប្រើប្រាស់នូវឯកសារ “គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា” ដើម្បីឱ្យកសិករនិងសហគមន៍កសិកម្មទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើរ។ បន្ថែមលើនេះ ក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពី "ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ" បរិមាណអង្ករនាំចេញទៅកាន់ទីផ្សារអន្តរជាតិ បានកើនឡើងប្រមាណ ៦២% ក្នុងរយៈពេល៥ឆ្នាំ ចាប់ពី២០១៤ដល់២០១៨ និងអង្ករពូជស្រូវផ្ការំដួលត្រូវបានចាត់ទុកថាមានគុណភាពល្អជាងគេក្នុងពិភពលោក។

ការបង្វែរទិសពីការអភិវឌ្ឍតាមបែបទូលាយ ឬតាមបែបវិបុលកម្ម ទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ ឬតាមបែបប្រពលវប្បកម្ម បានក្លាយជារបៀបវារៈអាទិភាពមួយដ៏សំខាន់។ ជាកត្តាសត្យានុម័ត ការពង្រីកនិងការពង្រឹងសេវាកម្មគាំទ្រដ៏មានប្រសិទ្ធភាព ដូចជាការស្រាវជ្រាវ ការផ្សព្វផ្សាយនូវបច្ចេកវិទ្យាទំនើបទៅតាមអនុវិស័យ អាស្រ័យទៅតាមសក្តានុពលនៃភូមិសាស្ត្រ ការកែលម្អពូជ ការប្រើប្រាស់ជី សម្ភារកសិកម្ម និងការផ្តល់ឥណទានជនបទ ត្រូវបានយកចិត្តទុកដាក់ និងជាអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ផលិតភាពកសិកម្ម ឆ្លើយតបទៅតាមតម្រូវការទីផ្សារ ទាំងបរិមាណ គុណភាព សុវត្ថិភាព និងស្តង់ដារអន្តរជាតិ។

បច្ចុប្បន្ននេះ យើងបានកត់សម្គាល់ថា ប្រជាកសិករយើងកំពុងផ្លាស់ប្តូរទម្លាប់ជាបណ្តើរៗ ពីការផលិតសម្រាប់បម្រើសេចក្តីត្រូវការផ្ទាល់ខ្លួន មកជាការផលិតដើម្បីលក់ ព្រោះមានទីផ្សារ និងចំណូលខ្ពស់។ ផ្អែកលើការប្រែប្រួលនេះ យើងអាចសន្និដ្ឋានបានថា សហគមន៍កសិកម្មកំពុងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់ ដែលនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គមជនបទកម្ពុជា ជាពិសេសទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន និងបរិស្ថានល្អ។ ជាការកត់សម្គាល់ កសិករបានចងក្រងគ្នាបង្កើតជាសហគមន៍អភិវឌ្ឍន៍កសិកម្មផលិតបន្លែសរីរាង្គ ហើយធ្វើការសម្អាតរួចវេចខ្ចប់ ដើម្បីផ្គត់ផ្គង់ទៅកាន់ទីផ្សារទំនើបផ្សេងៗនៅរាជធានីភ្នំពេញ។ នេះបង្ហាញឱ្យឃើញថា កសិករយើងបាននិងកំពុងប្រែក្លាយខ្លួនចេញពី “កសិករ ទៅជាកសិ-ពាណិជ្ជករ” ដើម្បីទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួន។ ក្នុងបរិបទនេះ យើងសង្កេតឃើញថា មានស្ថាប័នជាច្រើនទាំងរាជរដ្ឋាភិបាល វិស័យឯក-ជន និងអង្គការក្រៅរដ្ឋាភិបាលបាន និងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹង និងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយក៏មានកសិករជាច្រើនបានក្រេបជញ្ជក់យកបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាមនិងថ្នៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើនទៅតាមអនុវិស័យនីមួយៗ។

បច្ចុប្បន្ននេះ តម្រូវការប្រើប្រាស់សម្ភារកសិកម្មមានការកើនឡើងជារៀងរាល់ឆ្នាំ ស្របតាមស្ថានភាពអភិវឌ្ឍន៍ផលិតកម្មកសិកម្មនៅក្នុងប្រទេស ដែលធ្វើឱ្យបរិមាណសម្ភារកសិកម្មនាំចូល និងបរិមាណសម្ភារកសិកម្មដែលផលិតលាយផ្សំនៅក្នុងស្រុកត្រូវបានកើនឡើង។ រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្ត្រមិនយកពន្ធ ឬកំណត់អត្រាពន្ធសូន្យលើការនាំចូលសម្ភារកសិកម្ម ក្នុងគោលបំណងបង្កភាពប្រកួតប្រជែងទីផ្សារនៃផលិតកម្មក្នុងស្រុក ដែលអាចឱ្យកសិករទិញសម្ភារកសិកម្មប្រកបដោយគុណភាព និងមានតម្លៃថោក។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បានខិតខំពង្រឹងលើការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្ម ដែលបានចុះបញ្ជិកាត្រឹមត្រូវ ព្រមទាំងពង្រឹងការត្រួតពិនិត្យអាជីវកម្មលក់ដុំ និងលក់រាយសម្ភារកសិកម្មនៅតាមបណ្តារាជធានីខេត្ត ឱ្យបានសមស្របតាមនីតិវិធី និងមានកម្រិតស្តង់ដារច្បាស់លាស់ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការធ្វើផលិតកម្មកសិកម្ម។

### ក- ផលិតកម្មដំណាំស្រូវ

ផ្ទៃដីភ្ជួររាស់ដាំដុះដំណាំស្រូវឆ្នាំ២០១៨-២០១៩ នៅទូទាំងប្រទេសសម្រេចបានចំនួន៣,៦៤លានហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មចំនួន៣,៥២លានហ.ត ឬស្មើនឹង៩៦,៨៦%។ ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបានលើផ្ទៃដី៣លានហិកតានៅឆ្នាំ២០១៤ និងបានកើនដល់៣,៣៤លានហិកតានៅឆ្នាំ២០១៨។ ទិន្នផលស្រូវគិតជាមធ្យមទាំងប្រាំង និងវស្សាបានកើនពី៣,០៧៩តោន/ហ.តពីឆ្នាំ២០១៤ ដល់៣,៣៥៣តោន/ហ.ត នៅឆ្នាំ២០១៨។ បរិមាណផលស្រូវបានកើនឡើងពី៩,៣២លានតោននៅឆ្នាំ២០១៤ ដល់ប្រមាណ១០,៨៩លានតោននៅឆ្នាំ២០១៨។ អតិរេកស្រូវបានកើនពី៤,៧លានតោននៅឆ្នាំ២០១៤ ដល់ប្រមាណ៥,៨លានតោននៅឆ្នាំ២០១៨នេះ។

**តារាងទី១: ផលិតកម្មដំណាំស្រូវពីឆ្នាំ២០១៤-២០១៨**

| ឆ្នាំ | បរិយាយ | | | | |
|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (លានហ.ត) | | | ទិន្នផល (តោន/ហ.ត) | បរិមាណផល (លានតោន) |
| | ផែនការ | ដាំដុះ | ប្រមូលផល | | |
| ២០១៤ | ២,៨២ | ៣,០៥ | ៣,០៣ | ៣,០៧៩ | ៩,៣២ |
| ២០១៥ | ២,៩៨ | ៣,០៥ | ៣,០២ | ៣,០៨៥ | ៩,៣៣ |
| ២០១៦ | ២,៩១ | ៣,១២ | ៣,១០ | ៣,២១១ | ៩,៩៥ |
| ២០១៧ | ២,៩៤ | ៣,២១ | ៣,១៩ | ៣,២៩៨ | ១០,៥២ |
| ២០១៨ | ២,៩៦ | ៣,៣៤ | ៣,២៥ | ៣,៣៥៣ | ១០,៨៩ |

គួរកត់សម្គាល់ថា បច្ចុប្បន្ននេះផលិតកម្មដំណាំស្រូវមានការរីកចម្រើនឡើងជាលំដាប់ គឺដោយសារមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិនិងអន្តរជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ វិស័យឯកជន និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ។ ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវបណ្តាលមកពីកត្តាសំខាន់ៗ មួយចំនួនដូចជា៖

១) ការផ្លាស់ប្តូរពូជស្រូវមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ និងផ្សព្វផ្សាយ។

២) ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេសការពង្រីកឱ្យកាន់តែមានប្រសិទ្ធភាពលើការធ្វើស្រែបង្ហាញតាមប្រព័ន្ធវប្បកម្មដំណាំស្រូវ។

៣) ការអនុវត្តបច្ចេកទេសគ្រប់គ្រងដី ទឹក ដើម្បីបង្កើនជីជាតិ និងទិន្នផលដំណាំ។

៤) ការបង្កើនការស្រាវជ្រាវ និងអភិវឌ្ឍពូជស្រូវ ដែលស្របនឹងលក្ខណៈដី អាកាសធាតុ។

៥) ការកំណត់ប្រភេទពូជស្រូវសំខាន់ៗស្របតាមតម្រូវការទីផ្សារ ដូចជា ពូជស្រូវផ្ការំដួល។

ជាការកត់សម្គាល់បន្ថែមទៀត យន្តូបនីយកម្មកសិកម្មពិតជាបាន និងកំពុងដើរតួសំខាន់ ព្រមទាំងបំពេញនូវកម្លាំងពលកម្មដែលកំពុងខ្វះខាតក្នុងវិស័យកសិកម្មនាពេលកន្លងមក។

### ខ-ដំណាំរួមផ្សំ និងឧស្សាហកម្មរយៈពេលខ្លី

ផលិតកម្មដំណាំរួមផ្សំ សាកវប្បកម្ម និងឧស្សាហកម្ម ត្រូវបានកត់សម្គាល់ឃើញថា ផ្ទៃដីដាំដុះបានកើនពី ៩៥៣.៥៩៧ហ.តនៅឆ្នាំ២០១៤ ដល់ប្រមាណ១,០៩១លានហ.តនៅឆ្នាំ២០១៨ (កំណើនជាមធ្យមក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះមានប្រមាណ៣%)។ ចំពោះបរិមាណផលនៃដំណាំរួមផ្សំ និងឧស្សាហកម្មរយៈពេលខ្លីបានកើនពី ១៤,៧លានតោននាឆ្នាំ២០១៤ ដល់ប្រមាណ១៦,៦លានតោននាឆ្នាំ២០១៨ (កំណើនជាមធ្យមក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះមានប្រមាណ១០,៥%)។

### គ. ការនាំចេញផលិតផលកសិកម្ម

ការនាំចេញផលិតផលកសិកម្មមាននិន្នាការកើនឡើងជាលំដាប់ ហើយមានសន្ទុះខ្លាំងក្លានៅក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ។ ជាក់ស្តែង នៅឆ្នាំ២០១៤ ការនាំចេញផលិតផលកសិកម្មសម្រេចបានចំនួន៣,៤៤លានតោន នៅឆ្នាំ២០១៥ សម្រេចបានចំនួន៤,១៥លានតោន ឆ្នាំ២០១៦ សម្រេចបានចំនួន៤,៧លានតោន និងឆ្នាំ ២០១៨ សម្រេចបានចំនួន៤,២៣លានតោន។ ជារួមកំណើននៃការនាំចេញក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះមាន ប្រមាណជា២២,៨% ប្រៀបធៀបពីឆ្នាំ២០១៤ និងឆ្នាំ២០១៨។

**ក្រាហ្វិកទី១÷ ការនាំចេញផលិតផលកសិកម្មពីឆ្នាំ២០១៤-២០១៨**




ការនាំចេញអង្ករក៏មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ជាក់ស្តែងការនាំចេញអង្ករនៅឆ្នាំ២០១៤សម្រេចបានត្រឹមតែជាង៣៨៧ពាន់តោន និងបានកើនដល់ជាង៦២៦ពាន់តោននៅឆ្នាំ ២០១៨។ ដោយឡែក ការនាំចេញអង្ករនៅក្នុងឆ្នាំ២០១៨ មានប្រភេទអង្ករក្រអូប៧៨,៨២% អង្ករសគ្រាប់វែង ១៦,៩៣% និងអង្ករចំហុយគ្រាប់វែង៤,២៥% ទៅកាន់ទិសដៅ៦១ប្រទេស និងមានក្រុមហ៊ុននាំចេញចំនួន៨៧ ក្រុមហ៊ុន។

### ឃ-ការផ្សព្វផ្សាយ និងអភិវឌ្ឍន៍សហគមន៍កសិកម្ម

ការងារអប់រំ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្មត្រូវបានអនុវត្តតាមរយៈ(១) ការបណ្តុះបណ្តាល និងអនុវត្តជាក់ស្តែងនៅទីវាល ឬសាលារៀនស្រែកសិករ ការធ្វើស្រែបង្ហាញ ទិវាស្រែ និងទស្សនកិច្ចសិក្សា (២) មជ្ឈមណ្ឌលបណ្តុំព័ត៌មានផ្សព្វផ្សាយកសិកម្ម គេហទំព័រផ្សព្វផ្សាយកសិកម្ម និងវេទិកាសាធារណៈ និង (៣) ការបោះពុម្ព និងចែកចាយឯកសារបច្ចេកទេសកសិកម្ម។

ក្នុងឆ្នាំ២០១៨ មន្ត្រីបច្ចេកទេសកសិកម្មខេត្ត ស្រុក ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ព្រមទាំងប្រជាកសិករចំនួនជាង ២១ ៦២៧នាក់ ក្នុងនោះស្ត្រីមានចំនួន ៦ ៦៤៩នាក់ ឬស្មើនឹង៣១%

ទទួលបានចំណេះដឹងទាក់ទងនឹងបច្ចេកទេសរៀបចំដី បច្ចេកទេសដាំដុះដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម កិច្ចការពារដំណាំ ការអនុវត្តកសិកម្មល្អ ការអនុវត្តកសិកម្មសរីរាង្គ បច្ចេកវិទ្យាក្រោយប្រមូលផលដំណាំ ការវាយតម្លៃ និងចាត់ចំណាត់ថ្នាក់ដី ការប្រើប្រាស់ថែទាំ និងជួសជុលគ្រឿងយន្ត ឧបករណ៍ និងសម្ភារកសិកម្ម សមត្ថភាពក្នុងការវិភាគ ជី ដី ទឹក សំណល់ថ្នាំកសិកម្ម ជាលិកាវប្បកម្ម និងគុណភាពគ្រាប់ពូជដំណាំ និងការធ្វើផែនការអាជីវកម្ម រួមទាំងការគ្រប់គ្រងសហគមន៍កសិកម្ម។ ក្រៅពីនេះ ឯកសារបច្ចេកទេសកសិកម្មចំនួន ៥៣ ៧៤០ ច្បាប់ត្រូវបានបោះពុម្ព និងចែកចាយ ព្រមទាំងអត្ថបទកសិកម្មចំនួន៧៤ប្រធានបទ ត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសាធារណៈ ដូចជាទូរទស្សន៍និងវិទ្យុជាដើម។ ទន្ទឹមនឹងនេះ ក្រសួងបានដំណើរការមជ្ឈមណ្ឌលបណ្តុំព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មដែលមានឯកសារផ្សព្វផ្សាយចំនួន៣៦៧ឯកសារ និងមានអ្នកចូលមើលឯកសារផ្សព្វផ្សាយចំនួន ៣៨ ២០០នាក់ក្នុងឆ្នាំ២០១៨។

គិតត្រឹមឆ្នាំ២០១៨នេះ នៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន ១ ១១៦សហគមន៍ ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន ១៣០ ០៥៩នាក់ ក្នុងនោះមានសមាជិកនារីចំនួន ៨០ ៤៣៩នាក់ ស្មើនឹងប្រមាណ៦២% នៃសមាជិកសរុប ប្រាក់ភាគហ៊ុនសរុបចំនួនជាង ៣៧ ២៩៧លានរៀល (ជាង៩,៣លានដុល្លារអាមេរិក) និងមានដើមទុនសរុបចំនួនជាង ៦៩ ០៧៧លានរៀល (ជាង១៧,២លានដុល្លារអាមេរិក)។ ក្រៅពីសហគមន៍កសិកម្ម ក្រសួងបានជំរុញ និងចុះបញ្ជីសហភាពសហគមន៍កសិកម្មទូទាំងប្រទេសសរុបបានចំនួន៨ ដែលមានសមាជិកជាសហគមន៍កសិកម្មចំនួន៩៧ និងដើមទុនសរុបចំនួនជាង៤១៣លានរៀល។

## ខ. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម

រយៈពេល៥ឆ្នាំកន្លងមកនេះ ក្នុងមួយឆ្នាំៗវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) បានធ្វើពិសោធន៍ជាមធ្យមចំនួន៩០ប្រភេទ នៅលើទីតាំង៥៣៦កន្លែង និងអង្កេតចំនួន៩ប្រភេទ លើកសិករប្រមាណ ៣ ៧៥៥នាក់ ព្រមទាំងការងារស្រាវជ្រាវផ្សេងៗទៀត ហើយសម្រេចបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**សម្ងូហកម្មជីវករពូជដំណាំ និងអភិរក្សកម្មពូជដំណាំ៖** ពូជដំណាំក្នុងស្រុកចំនួន៣៨ប្រភេទរួមមាន១ ៤៨៤ បញ្ញិក/សំណាកត្រូវបានធ្វើសម្ងូហកម្ម និងវាយតម្លៃអំពីចរិតលក្ខណៈមុននឹងបន្តយកទៅធ្វើអភិរក្សបន្ថែមនៅក្នុងធនាគារពន្ធុពូជដំណាំ បន្ថែមលើពូជដំណាំដែលបានអភិរក្សកន្លងមក ហើយបានធ្វើយុវកម្មពូជដំណាំចំនួន៧២១ បញ្ញិក/សំណាកផងដែរ។ ដូច្នេះចំនួនជីវករពូជដំណាំក្នុងស្រុករបស់កម្ពុជាដែលបាន និងកំពុងអភិរក្សនៅក្នុងធនាគារពន្ធុដំណាំមានចំនួនសរុប ៨ ៣៧៦បញ្ញិក/សំណាកសម្រាប់ការប្រើប្រាស់នាពេលអនាគត។ ទន្ទឹមនឹងនេះ ពូជស្រូវ២១៤បញ្ញិកត្រូវបានបញ្ជូនទៅផ្ញើរក្សាទុកក្នុងធនាគារពន្ធុក្នុងរយៈពេលយូរនៅសាធារណរដ្ឋកូរ៉េ។

**បញ្ចេញប្រភេទពូជថ្មីនៃដំណាំចំនួន៩៖** ពូជស្រូវខា១៤ (ធន់នឹងជំងឺខ្នារអំបោះត្នោត) ខា១៥ (ធន់នឹងមមាចត្នោត និងជំងឺបាត់តេរីស្រពោនស្លឹក) ខា១៦ (ធន់នឹងកម្ដៅ) ផ្ការំដួលប្រាំង (សមស្របសម្រាប់ដាំដុះខែតុលា-វិច្ឆិកា ប្រមូលផលខែកុម្ភៈ-មីនា ក្រអូបប្រណីត) ស្នាច់២ (អង្ករក្រហម) ដំណើបស្បៃមង្គល (ធន់នឹងទឹកជំនន់ និងរាំងស្ងួត អង្ករមានគុណភាពប្រណីត) និងផ្កាមាលតី (ធន់មធ្យមនឹងរាំងស្ងួត ធន់នឹងទឹកជំនន់ និងការដួលដើម អង្ករមានគុណភាពល្អ និងបាយឆ្ងាញ់) ពោតដំណើបស៊ីអឹម១ និងសណ្តែកដីខេប១ ត្រូវបានបញ្ចេញឱ្យកសិករ និងគ្រប់អ្នកពាក់ព័ន្ធប្រើប្រាស់។ ពូជស្រូវផ្កាមាលតី ត្រូវបានបញ្ចេញថ្មីក្នុងខែឧសភា ឆ្នាំ២០១៨។

**ការគ្រប់គ្រងជីជាតិដី៖** បានសិក្សារកឃើញអំពីបរិមាណអាសូតដែលដំណាំស្រូបយកពីជីអាសូត និងបរិស្ថានដាំដុះ ប្រសិទ្ធភាពនៃការប្រើប្រាស់អនុសាសន៍ជីលើដំណាំស្រូវ បរិមាណដីហូរច្រោះដីដោយដំណាំដំឡូងមី និងការស្រូបយកសារធាតុចិញ្ចឹមរបស់ដំឡូងមី ការប្រើប្រាស់កំបោរបង្កើនគុណភាពដី និងផលដៃថាវ ។ល។ ទន្ទឹមនឹងនេះ បានចងក្រងព័ត៌មានលម្អិតអំពីដី និងផែនទីក្រុមដីដាំដុះស្រូវនៃអនុតំបន់ស្រោចស្រពចំនួន ១០ បានកសាងនូវព័ត៌មានលម្អិតដែលពិពណ៌នាអំពីដី និងផែនទីនៃរបាយដីនៅក្នុងស្រុកចំនួន៦ (គងពិសី

ត្រាំកក់ ពញាក្រែក អូររាំងឪ សំឡូត និងបាណន់) និងផែនទីដីថ្នាក់ខេត្តចំនួនមួយគឺខេត្តប៉ៃលិន។ បានចុះជីក ប្រូហ្វីលដីបានចំនួន៣០០ និងយកសំណាកប្រមាណ៧០០ មកវិភាគ ព្រមទាំងបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រឹះអំពីដីកសិកម្មសម្រាប់ប្រទេសកម្ពុជា ដែលមានជាសរុបជិត២០០០កំណត់ត្រាប្រូហ្វីលដី។

**ការគ្រប់គ្រងកត្តាចង្រៃ៖** បានសិក្សារកឃើញពីភាពធន់ទ្រាំទៅនឹងជំងឺ និងសត្វល្អិតចង្រៃរបស់ពូជស្រូវ វិធានការការពារ និងកម្ចាត់ខ្យងពណ៌មាស និងកណ្ដុរស្រែ កំណត់ជំងឺ និងសត្វល្អិតលើដំណាំស្វាយ។

**វិស្វកម្មកសិកម្ម៖** បានសិក្សាបង្កើតឧបករណ៍ដាំស្រូវ សណ្ដែក និងពោតស្ងួតជាជួរ វិធីសាស្ត្រវេចខ្ចប់នាពេលដឹកជញ្ជូន និងថែរក្សាបន្លែយកស្លឹក ផ្លែឱ្យបានយូរ ការបាត់បង់ស្រូវដោយកំបែ និងមូលហេតុនៃការបាក់គ្រាប់អង្ករពេលកិន។

**វិទ្យាសាស្ត្រសេដ្ឋកិច្ច សង្គម៖** បានសិក្សាអំពីខ្សែច្រវាក់ផ្គត់ផ្គង់ និងតម្រូវការផលិតផលបន្លែ និងស្វាយកែវរមៀតនៅលើទីផ្សារ ផលិតកម្មនិងបម្រែបម្រួលតម្លៃដំឡូងមី វាយតម្លៃអំពីការទទួលយកប្រភេទពូជស្រូវ ការប្រើប្រាស់ជី គ្រឿងយន្តកសិកម្ម និងវិធីសាស្ត្រដាំដុះជាដើម។

**ក្សេត្រសាស្ត្រ និងប្រព័ន្ធកសិកម្ម៖** បានបង្កើតនូវបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវវស្សា ស្រូវតំបន់ឆ្នេរ និងសណ្ដែកបាយក្រោយពេលប្រមូលផលស្រូវវស្សា។ បានបង្ហាត់បង្ហាញអំពីវិធានការដាំដុះ និងថែទាំដំណាំស្រូវ សណ្ដែកបាយ សម្រិតសម្រាំងគ្រាប់ពូជជូនដល់កសិករ។

**ការផ្សព្វផ្សាយបច្ចេកទេស៖** បានធ្វើទិវាស្រែបង្ហាញ និងការបណ្ដុះបណ្ដាលទេពកោសល្យសរុប១៦៨លើកដល់កសិករ និងអ្នកពាក់ព័ន្ធគោលដៅសរុបចំនួន ៨ ៥៨០នាក់។ គ្រាប់ពូជស្រូវប្រកបដោយគុណភាពល្អនៃប្រភេទពូជស្រូវដែលមានតម្រូវការខ្ពស់ពីទីផ្សារសរុបច្រើនជាង២៥៥តោន ត្រូវបានចែកចាយឱ្យកសិករគោលដៅប្រើប្រាស់ពីរដូវមួយទៅរដូវមួយបន្តបន្ទាប់។ ទន្ទឹមនឹងនេះ ឯកសារបច្ចេកទេស និងសៀវភៅបច្ចេកទេសប្រមាណ ១២៧ ៥៥០ច្បាប់ ត្រូវបានសរសេរ ចងក្រង និងចែកចាយជាសាធារណៈ ដែលក្នុងនោះមានទាំងសៀវភៅសមិទ្ធផលនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា (១៩៩៩-២០១៧) Description of Crop Varieties Released by CARDI និង Rice Germplasm Catalog of Cambodia IV ផងដែរ។ អត្ថបទវិទ្យាសាស្ត្រចំនួន៣៣ ត្រូវបានសរសេរ និងបោះពុម្ពនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រកសិកម្មអន្តរជាតិ។

បន្ថែមលើសពីនេះ អង្ករផ្ការំដួលត្រូវបានជំរុញឱ្យទីផ្សារអង្ករពិភពលោកទទួលស្គាល់លើទិដ្ឋភាពគុណភាពល្អប្រណីត ដែលនាំឱ្យមានតម្លៃបន្ថែមល្អនៅក្នុងច្រវាក់ផលិតកម្មស្រូវស្រែទំនាបពឹងទឹកភ្លៀងនៅកម្ពុជាដោយបានទទួលជ័យលាភីលេខ១បួនឆ្នាំ (២០១២ ២០១៣ ២០១៤ និង២០១៨)។ ក្នុងឆ្នាំ២០១៧ លោកបណ្ឌិត អ៊ុក ម៉ាកាវា នាយកវិទ្យាស្ថានកាឌី ត្រូវបានក្រសួងអប់រំ យុវជន និងកីឡាជ្រើសរើសជា **អ្នកវិទ្យាសាស្ត្រឆ្នើម** សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ ទន្ទឹមនឹងនេះក៏ត្រូវបានជ្រើសរើសជា **អ្នកវិទ្យាសាស្ត្រស្រូវឆ្នើម** និងជា **ឯកអគ្គរាជទូតវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាស្រូវ** តំណាងប្រទេសកម្ពុជា ក្នុងខួបលើកទី៥០របស់អាស៊ាន។

### ច-ការអភិវឌ្ឍដំណាំកៅស៊ូ

ផ្ទៃដីកៅស៊ូកម្ពុជាសរុបបានកើនពី៣៥៧,៨៣ពាន់ហិកតានៅឆ្នាំ២០១៤ ដល់៤៣៦,៦៨៣ពាន់ហិកតានៅឆ្នាំ២០១៨ (កើនប្រមាណ២២%) ដែលក្នុងនោះផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្ម (ផ្ទៃដីរបស់អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) មានចំនួន៦៤,២២% និងកៅស៊ូគ្រួសារមានចំនួន៣៥,៧៨%។ ផ្ទៃដីកៅស៊ូគ្រួសារបានកើនឡើងពី១៤០,៣៤ពាន់ហិកតានៅឆ្នាំ២០១៤ ដល់១៦១,១ពាន់ហ.តនៅឆ្នាំ២០១៨ (គឺកើនប្រមាណជា១៤,៧% ពីចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨)។ រីឯផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្មក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ពោលគឺបានកើនពី២១៧,៤៦ពាន់ហ.ត

នៅឆ្នាំ២០១៤ ដល់២៧៥,៥៧៣ពាន់ហ.តនៅឆ្នាំ២០១៨ (គឺកើនប្រមាណ២៧% ពីចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ ២០១៨)។

**តារាងទី២: ផលិតកម្មដំណាំកៅស៊ូពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨**

| ផលិតកម្មកៅស៊ូ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១.ផ្ទៃដីដាំកៅស៊ូសរុប | ពាន់ហិកតា | ៣៥៧,៨ | ៣៨៩ | ៤៣២,៧ | ៤៣៦,៣ | ៤៣៦,៦ |
| ២.ផ្ទៃដីចៀរជ័រ | ពាន់ហិកតា | ៩០,៥ | ១១១,២ | ១២៧ | ១៧០,២ | ២០១,៩ |
| ៣.ផលិតផលកៅស៊ូ | ពាន់តោន | ៩៧,១ | ១២៦,៩ | ១៤៥,២ | ១៩៣,៣ | ២២០,១ |

ទោះបីជាថ្លៃកៅស៊ូបន្តនៅទាប និងមានកត្តាអវិជ្ជមានមួយចំនួន ដែលបានជួបប្រទះកន្លងមកក៏ពិតមែន តែជារួម សមិទ្ធផលបានសម្រេចទៅតាមគោលដៅដែលបានគ្រោងទុក។ ទាំងអស់នេះ គឺកើតឡើងដោយការខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនចម្ការកៅស៊ូកសិ-ឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសកម្មពីកសិករកៅស៊ូគ្រួសារផងដែរ។ ទោះបីជាយ៉ាងនេះក្តី ការបង្កើនលទ្ធភាព និងសមត្ថភាពក្នុងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូត្រូវតែបន្តយកចិត្តទុកដាក់ និងត្រូវជំរុញបន្ថែមទៀត ដើម្បីរួមចំណែកដោយជោគជ័យក្នុងការអនុវត្តយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ផលិតផលកៅស៊ូក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ បានកើនជាងពីរដង គឺពី៩៧ពាន់តោននៅឆ្នាំ២០១៤ ដល់ ២២០ពាន់តោននៅឆ្នាំ២០១៨។ ជាមួយគ្នានេះ ការនាំចេញផលិតផលកៅស៊ូក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ក៏បានកើនជាងពីរដង គឺពី១០០ពាន់តោននៅឆ្នាំ២០១៤ ដល់ ២១៧,៥ពាន់តោននៅឆ្នាំ២០១៨។

## ២.២.២. ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារ និងពាណិជ្ជកម្មនៅកម្ពុជាក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើនទាំងអស់នេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមសត្វ ការជ្រើសរើស និងការបង្កាត់ពូជសត្វ ការផលិតចំណីសត្វ និងការផ្តល់សេវាថែទាំសុខភាពសត្វ។ ជាមួយគ្នានេះ ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ក៏ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលច្បាប់នេះជាឧបករណ៍សម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាព ក្នុងការអភិវឌ្ឍផ្នែកផលិតកម្មសត្វ និងសុខភាពសត្វនៅកម្ពុជាផងដែរ។

ជារួមផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានអត្រាកំណើនគួរឱ្យកត់សម្គាល់ គឺបានកើនពី ៣៧ ៩៤៨ ៨៧៨ក្បាលនៅឆ្នាំ២០១៤ ដល់ ៤៤ ៣៧៥ ៣៩៥ក្បាលនៅឆ្នាំ២០១៨ ដែលក្នុងនោះមាន គោចំនួន ២ ៩២៨ ៥៣៤ក្បាល ក្របីចំនួន ៥០០ ៩៩៥ក្បាល ជ្រូកចំនួន ២ ៧៤៧ ៨៥៥ក្បាល បក្សីចំនួន៣៨ ១៦៦ ៧៥១ក្បាល សេះចំនួន ៤ ២៩៦ក្បាល ចៀមចំនួន៤៥៩ក្បាល ពពែចំនួន ២៦ ៤៤៧ក្បាល និងដំរី៥៨ក្បាល។

ជំងឺឆ្លងសត្វគឺជាឧបសគ្គចម្បងក្នុងផលិតកម្មសត្វ ពិសេសផលិតកម្មសត្វជ្រូក និងបក្សី (មាន់និងទា)។ ម្យ៉ាងទៀត ការប្រកួតប្រជែងក្នុងផលិតកម្មសត្វនៅតែជាបញ្ហាប្រឈមត្រូវដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានលក្ខណៈអន្តរវិស័យ ដែលពាក់ព័ន្ធដល់ឧស្សាហកម្មផលិតចំណីសត្វ ការផលិតវ៉ាក់សាំងក្នុងស្រុកមានចំនួនតិចតួច ពោលគឺបានពឹងផ្អែកខ្លាំងលើការនាំចូលពីបរទេស និងថ្លៃអគ្គិសនីក៏មានតម្លៃខ្ពស់ ដែលធ្វើឱ្យថ្លៃដើមផលិតកម្មនៃការចិញ្ចឹមសត្វមានកម្រិតខ្ពស់ ពិបាកក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាង។

**ក្រាហ្វិកទី២៖ ផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម) ឆ្នាំ២០១៤-២០១៨**




ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ ជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពី ៦ ៣៣៥ ០០២ក្បាល នៅឆ្នាំ២០១៤ ឡើងដល់ ១០ ០៣៥ ៥៨៥ក្បាល នៅក្នុងឆ្នាំ២០១៨។ កំណើននៃការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មមានប្រមាណ៥៨% បើប្រៀបធៀបពីឆ្នាំ២០១៤ និងឆ្នាំ២០១៨ ខណៈដែលការចិញ្ចឹមជាលក្ខណៈគ្រួសារមានកំណើនតែ៨,៦%ប៉ុណ្ណោះ។ ដោយឡែកនៅក្នុងឆ្នាំ២០១៨នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានកំណើន២៣% ក្នុងនោះផលិតកម្មជ្រូកលក្ខណៈពាណិជ្ជកម្មមានកំណើន៣០% និងផលិតកម្មបក្សីមានកំណើន២៤%។ អត្រានៃកំណើនផលិតសត្វជាលក្ខណៈពាណិជ្ជកម្មនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើង។

**តារាងទី៣៖ ស្ថិតិសត្វតាមបែបផែនផលិតកម្មពីឆ្នាំ២០១៤-២០១៨**

| បែបផែន ផលិតកម្មសត្វ | ស្ថិតិសត្វ៥ឆ្នាំចុងក្រោយ (២០១៤-២០១៨) | | | | | ប្រៀបធៀបឆ្នាំ ២០១៤/២០១៨ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | |
| លក្ខណៈគ្រួសារ | ៣១.៦១៣.៨៧៦ | ៣២.៤៨៧.៤៩៩ | ៣៤.២២៣.០០៧ | ៣៤.៤៧៧.៨៥៩ | ៣៤.៣៣៩.៨១០ | ៨,៦% |
| លក្ខណៈពាណិជ្ជកម្ម | ៦.៣៣៥.០០២ | ៨.២៦៥.៩០៥ | ៧.៩៦០.៣៨៧ | ៨.៣៥៦.៣០៩ | ១០.០៣៥.៥៨៥ | ៥៨% |
| សរុប | ៣៧.៩៤៨.៨៧៨ | ៤០.៧៥៣.៤០៤ | ៤២.១៨៣.៣៩៤ | ៤២.៨៣៤.១៦៨ | ៤៤.៣៧៥.៣៩៥ | ១៧% |

ការចិញ្ចឹមគោមានការប្រែប្រួលថយចុះប្រមាណពី៣លានក្បាលនាឆ្នាំ២០១៤ មកត្រឹមតែ២,៩២លានក្បាលនាឆ្នាំ២០១៨។ រីឯក្របីក៏មានការប្រែប្រួលថយចុះប្រមាណពី៥៤២ពាន់ក្បាលនាឆ្នាំ២០១៤ មកត្រឹមតែ៥០១ពាន់ក្បាលនាឆ្នាំ២០១៨។ ការថយចុះចំពោះផលិតកម្មចិញ្ចឹមសត្វគោក្របីនេះ គឺជាការថយចុះគោក្របីអូសទាញ មូលហេតុបណ្តាលមកពីកសិករកាន់តែច្រើនឡើងៗ បោះបង់ការភ្ជួររាស់ដោយគោ ក្របី មកប្រើប្រាស់សេវាគ្រឿងយន្តកសិកម្ម (ជាង៩៦% នៃផ្ទៃដីដាំដុះដំណាំស្រូវ ត្រូវបានអនុវត្តដោយគ្រឿងយន្តកសិកម្ម) កង្វះកម្លាំង

ពលកម្មនៅជនបទ (ចំណាកស្រុក) មានការលំបាកក្នុងការស្វែងរកតំបន់មានទឹក និងចំណីគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមសត្វគោក្របីជាលក្ខណៈគ្រួសារ។ ទន្ទឹមនឹងការថយចុះគោអូសទាញនេះ កសិករបានងាកមកចិញ្ចឹមគោមេ និងគោយកសាច់ ហើយជាមួយគ្នានោះក៏មានការចាប់ផ្តើមការវិនិយោគឯកជនចិញ្ចឹមគោសាច់វិញផងដែរ។

ការចិញ្ចឹមសត្វស្លាបសរុប (ពិសេសមាន់ ទា) មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ជាង២០,៨% បើប្រៀបធៀបពីឆ្នាំ២០១៤ និងឆ្នាំ២០១៨។ ការចិញ្ចឹមជាលក្ខណៈគ្រួសារ និងកសិដ្ឋានក្នុងអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០១៤-២០១៨) បានកើនពីជាង៣១,៥៨លានក្បាលនៅឆ្នាំ២០១៤ ដល់ជិត៣៨,១៦លានក្បាលនាឆ្នាំ២០១៨។ នេះសបញ្ជាក់ឱ្យឃើញថាមានកំណើនការវិនិយោគក្នុងការចិញ្ចឹមសត្វស្លាប ពិសេសការចិញ្ចឹមមាន់ទា ក្នុងគោលដៅពាណិជ្ជកម្មរបស់កសិករ។

ចំពោះការផលិតចំណីសត្វ មានការវិនិយោគបង្កើតរោងចក្រចំណីសត្វ សម្រាប់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងស្រុកពីផ្នែកឯកជន ប៉ុន្តែមានចំនួនតិចតួចនៅឡើយ។ ជាមួយគ្នានេះ ប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការដាំដុះដំណាំចំណីសត្វ ព្រមទាំងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីសត្វផ្សំស្រេចយ៉ាងផុលផុស។ ទោះជាយ៉ាងនេះក្តី ចំណីនិងថ្នាំសត្វនៅមានតម្លៃខ្ពស់នៅឡើយ ដែលទាមទារឱ្យមានការធ្វើអន្តរាគមន៍សម្រាប់បន្ទាបថ្លៃដើម។

ជាការកត់សម្គាល់ ប្រជាកសិករមានការយល់ដឹងបណ្តើរៗនូវបច្ចេកទេសចិញ្ចឹមសត្វតាមគោលការណ៍ជីវ-សុវត្ថិភាព និងការយល់ដឹងអំពីវិធានការទប់ស្កាត់ជំងឺឆ្លង។ ការបង្ការការពារសុវត្ថិភាពមនុស្ស សត្វក៏ត្រូវបានអនុវត្ត និងទទួលបានលទ្ធផលល្អប្រសើរ ដោយអត្រាឈឺស្លាប់សត្វមានកម្រិតទាប។ ជាមួយគ្នានេះ ជំងឺផ្តាសាយបក្សីត្រូវបានទប់ស្កាត់ ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ត្រូវបានយកចិត្តទុកដាក់ដោយអនុវត្តចាប់ផ្តើមពីកសិដ្ឋាន កន្លែងពិឃាដដល់ទីផ្សារ ជាពិសេសការត្រួតពិនិត្យអនាម័យក្នុងការនាំចេញ នាំចូល នាំឆ្លងកាត់សត្វ និងផលិតផលមានដើមកំណើតពីសត្វ។

ទន្ទឹមនឹងនោះ កម្ពុជាត្រូវបន្តធ្វើការងារជាច្រើន ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តជាអន្តរជាតិ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការអនុវត្តបទដ្ឋានអនាម័យសម្រាប់ផលិតផលសត្វ ជាមួយនឹងការពង្រឹងការអនុ-វត្តវិធានការអនាម័យសត្វ ដើម្បីការពារ និងប្រយុទ្ធប្រឆាំងជំងឺឆ្លង ការពារសុខភាពសាធារណៈ តាមរយៈការការពារជំងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ព្រមទាំងការបង្កើតសត្តឃាតដ្ឋានទំនើប ដើម្បីការពារសុខភាពសាធារណៈ និងជួយសម្រួលពាណិជ្ជកម្ម។

ចំពោះការកែលម្អពូជ គឺកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរៗផងដែរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វ ជាកត្តាសំខាន់ដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ ហើយនឹងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។ ជាមួយគ្នានោះ ការផ្សព្វផ្សាយបច្ចេកទេសក្នុងជួរកសិករត្រូវបានអនុវត្តយ៉ាងសកម្ម និងមានប្រសិទ្ធភាព ដែលជាលទ្ធផលចំនួនសត្វស្លាបមានការកើនឡើង និងធានាបាននូវការផ្គត់ផ្គង់សាច់ ស៊ុតនៅក្នុងប្រទេស ហើយកសិដ្ឋានផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មកំពុងរីកចម្រើនជាបណ្តើរៗគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។

ដោយមានការអភិវឌ្ឍវិស័យចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអនុវត្តគោលនយោបាយឡជីវឧស្ម័ន ការអប់រំណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរលើការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវ-ឧស្ម័នថ្នាក់ជាតិបាន និងកំពុងអនុវត្តយ៉ាងសកម្មផុសផុល ដែលមកទល់ឆ្នាំ២០១៨ ឡជីវឧស្ម័នសរុបចំនួន ២៧ ២៣៣ឡ ត្រូវបានសាងសង់នៅតាមបណ្តាខេត្តគោលដៅចំនួន១៣។

### ២.២.៣. ការគ្រប់គ្រងធនធានជលផល និងវារីវប្បកម្ម

ត្រីជាអាហារប្រចាំថ្ងៃយ៉ាងសំខាន់របស់ប្រជាជនកម្ពុជាតាំងពីដើមរៀងមក ព្រោះត្រីផ្តល់នូវសារជាតិប្រូតេ-អ៊ីនប្រមាណជាង៨១% នៃប្រូតេអ៊ីនសាច់ដែលប្រជាជនកម្ពុជាបរិភោគ។ វិស័យជលផលក៏បានចូលរួមចំណែកផ្តល់មុខរបរដល់ប្រជាពលរដ្ឋប្រមាណ៦លាននាក់ បង្កើតប្រាក់ចំណូលដល់ប្រជាជន ដើម្បីជួយកាត់បន្ថយភាពក្រីក្រ និងជួយអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានរដ្ឋបាលជលផលជាសេនាធិការបានអនុវត្តការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល សម្រេចបានលទ្ធផលលើគ្រប់ផ្នែកក្នុងវិស័យ ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការការពារកន្លែងអភិរក្សជលផល ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការបង្ក្រាបបទល្មើសនេសាទ និងការផ្សព្វផ្សាយពង្រឹងការអនុវត្តច្បាប់ជាដើម។ ដោយឡែក ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល និងបទដ្ឋានបច្ចេកទេសមួយចំនួនដែលបានរៀបចំត្រូវបានពិនិត្យកែសម្រួល និងអនុម័តដើម្បីដាក់ឱ្យអនុវត្ត ធានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព។

សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយវិស័យជលផលជាតិ បានដាក់ចេញនូវទស្សនវិស័យសម្រាប់វិស័យជលផលក្នុងថ្ងៃអនាគតគឺ "គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍប្រទេសជាតិ" នេះគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាក់ស្តែងមកទល់ពេលនេះសមិទ្ធផលធំៗដែលសម្រេចបានមានដូចខាងក្រោមៈ

**ក - ការអភិវឌ្ឍសហគមន៍នេសាទ**

មកដល់បច្ចុប្បន្ននេះ រដ្ឋបាលជលផលបានរៀបចំសហគមន៍នេសាទសរុបចំនួន៥១៦ នៅតាមបណ្តាខេត្តនានា ដោយមានសមាជិកចូលរួមសរុប ១៤៧ ៥១៨គ្រួសារ ស្មើនឹង ៣៣២ ១៦៨នាក់ ដែលមានទីតាំងក្នុងដែននេសាទទឹកសាបចំនួន៤៧៥សហគមន៍ និងតំបន់ឆ្នេរសមុទ្រចំនួន៤១សហគមន៍ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលក្នុងមូលដ្ឋានប្រកបដោយចីរភាព ក្នុងនោះសហគមន៍នេសាទចំនួន៤០៨បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ។ នៅក្នុងដែននេសាទសហគមន៍មកដល់បច្ចុប្បន្ននេះបានបង្កើតតំបន់អភិរក្សបានចំនួន៤៩៦កន្លែង ដោយមានការបោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស និងស្លាកសញ្ញាកន្លែងអភិរក្សសម្រាប់សម្គាល់ទីតាំងកន្លែងអភិរក្សនៃកន្លែងនេសាទសហគមន៍នីមួយៗដែលត្រូវការពារ និងគ្រប់គ្រង។ ការគ្រប់គ្រងសហគមន៍នេសាទ គឺជាប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់សិទ្ធិគ្រប់គ្រាន់ដល់ប្រជានេសាទនៅក្នុងមូលដ្ឋាន ដើម្បីគ្រប់គ្រងកន្លែងនេសាទរបស់ពួកគាត់ ហើយកន្លងមកសហគមន៍នេសាទទាំងអស់បានអបអរសាទរដល់គុណប្រយោជន៍ពីការធ្វើនេសាទ ដែលបានផ្គត់ផ្គង់ការហូបចុកផង និងបានបង្កើនប្រាក់ចំណូលក្នុងគ្រួសារផង។

**ខ - ការងារអភិរក្សជលផល**

ការងារអភិរក្សត្រូវបានយកចិត្តទុកដាក់បំផុត ដើម្បីចូលរួមចំណែកធានាផលចាប់ប្រកបដោយនិរន្តរភាព។ ក្រោយការរំសាយឡូត៍នេសាទឆ្នាំ២០១២មក មានកន្លែងអភិរក្សដែលបានបង្កើតថ្មីចំនួន៥០កន្លែងត្រូវបានបង្កើតឡើងមានទំហំសរុប ៩៧ ៥៨៣ហិកតា។ បើគិតរួមទាំងកន្លែងអភិរក្សជលផលនៅតាមដែនសហគមន៍នេសាទ និងកន្លែងអភិរក្សសម្រាប់ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ និងកន្លែងអភិរក្សនៅតាមតំបន់ឆ្នេរ គឺមានរហូតដល់៦៤៤កន្លែង។ ជារួម គិតចាប់ពីឆ្នាំ២០១៣មក បានសាងសង់បង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សជលផលកម្ពស់៨ម៉ែត្របានចំនួន១៦១បង្គោល និងកម្ពស់១២ម៉ែត្របានចំនួន៧២បង្គោល ស្នាក់ការល្បាតបណ្តែត

ទឹកចំនួន២៥ខ្ទង ស្នាក់ការបេតុងចំនួន៨ខ្ទង និងស្នាក់ការធំ (ស្រឡង់) ចំនួន០៤។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតរួមមាន៖ អភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន ៤ ០៥០ហ.ត នៅតាមតំបន់ឆ្នេរ ដាំព្រៃលិចទឹក និងព្រៃកោងកាងបានចំនួន ៣ ០៩២ហ.ត បោះបង្គោលកំណត់ព្រំប្រទល់ព្រៃកោងកាងបានចំនួន១០៩បង្គោល រៀបចំអន្លង់ត្រីមេពូជបានចំនួន៩៧កន្លែង នៅតំបន់មេគង្គលើក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង លែងកូនត្រីនិងកូនបង្កងចំនួនជាង៥លានក្បាលទៅក្នុងបឹងធម្មជាតិ និងបានអភិរក្សធនធានជលផលកំពុងរងគ្រោះថ្នាក់ ដូចជាអណ្តើកសរសៃ អណ្តើកសមុទ្រ កន្ធាយក្បាលកង្កែប ក្រពើ ត្រីផ្សោតទឹកសាប ផ្សោតទឹកប្រៃ និងសេះសមុទ្រ។ល។ ដែលធ្វើឱ្យចំនួនកើនឡើងក្នុងចន្លោះពី១០-១៥%។

**គ - ការងារបង្ក្រាបបទល្មើសជលផល**

រដ្ឋបាលជលផលបានអនុវត្តតាមគ្រប់រូបភាព ដោយអនុវត្តតាមច្បាប់ស្តីពីជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាពិសេសបទបញ្ជាលេខ០១បប របស់រាជរដ្ឋាភិបាលទទួលបានលទ្ធផលគួរជាទីមោទនៈ ព្រមទាំងធានាបាននូវនិរន្តរភាពធនធានជលផល និងសន្តិសុខស្បៀងជូនប្រជាពលរដ្ឋ។ លទ្ធផលដែលសម្រេចបានខាងលើនេះ គឺដោយសារមានកិច្ចសហការអំពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសសហគមន៍មូលដ្ឋាន។ នៅឆ្នាំ២០១៤ ករណីបទល្មើសជលផលមានចំនួន៣ ៦៨៦ករណី ចំនួនត្រូវបានថយចុះមកត្រឹម ២ ៦៥០ករណីនៅឆ្នាំ២០១៨។

**ឃ - ការអភិវឌ្ឍវារីវប្បកម្ម**

ជាគោលនយោបាយដ៏ចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការធានាសន្តិសុខស្បៀងជូនប្រជាពលរដ្ឋ និងកាត់បន្ថយការដាក់សម្ពាធលើធនធានជលផលក្នុងដែនទឹកធម្មជាតិ ការអភិវឌ្ឍវារីវប្បកម្មក៏ត្រូវអនុវត្តតាមគ្រប់រូបភាព និងគ្រប់ទីកន្លែង រួមទាំងការបង្កើតស្រះជម្រកត្រីសហគមន៍ផងដែរ ដើម្បីធ្វើឱ្យផលវារីវប្បកម្មមានការកើនឡើងប្រមាណ២០%ជារៀងរាល់ឆ្នាំ។ ការអភិវឌ្ឍវារីវប្បកម្មសំខាន់រួមមានការចិញ្ចឹមត្រី-បង្គា ដែលនៅឆ្នាំ២០១៨ អនុវត្តបានចំនួន២៥៤ពាន់តោន គឺបានកើនឡើងជាង២ដងធៀបនឹងឆ្នាំ២០១៤ (១២០ពាន់តោន)។ ការចិញ្ចឹមក្រពើក៏មានសន្ទុះកើនឡើងផងដែរ គឺបានកើនប្រមាណ២ដង ពី២១៥ពាន់ក្បាលនាឆ្នាំ២០១៤ ដល់ ៤១០ពាន់ក្បាលនាឆ្នាំ២០១៨ និងការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន១២០លានក្បាលនាឆ្នាំ២០១៤ និងកើនដល់២១៥លានក្បាលនាឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ យើងបានបង្កើតកន្លែងភ្ញាស់ត្រីនៅទូទាំងប្រទេសបានចំនួន៣០៩កន្លែង ក្នុងនោះមាន២៩៦កន្លែងជារបស់កសិករ ដែលអនុវត្តតាមរយៈការផ្តល់បច្ចេកទេសពីរដ្ឋបាលជលផល និងបានបង្កើតសហគមន៍ស្រះជម្រកត្រីបានចំនួន៨៦៤កន្លែង ព្រមជាមួយគ្នានោះ កន្លែងដែលបានរៀបចំបានធ្វើឱ្យផលត្រីតាមវាលស្រែកើនឡើង។ នេះអាចបញ្ជាក់បានថា ប្រជាកសិករ ប្រជានេសាទបានទទួលយកនូវបច្ចេកទេសវារីវប្បកម្មដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្សព្វផ្សាយឱ្យអនុវត្តកន្លងមក។

**ង - ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងគុណភាព**

ផ្នែកកែច្នៃជលផលគឺជាផ្នែកដែលមានសក្តានុពលមួយយ៉ាងសំខាន់សម្រាប់វិស័យជលផល ក្នុងការចូលរួមចំណែកផ្គត់ផ្គង់សន្តិសុខស្បៀង អាហារូបត្ថម្ភ ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអភិវឌ្ឍផ្នែកកែច្នៃជលផលត្រូវបានរំលេចក្នុងគោលនយោបាយវិស័យជលផលជាតិ ហើយផែនការសកម្មភាពត្រូវបានដាក់បញ្ចូលនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផលឆ្នាំ២០១៥-២០២៤ ក្នុងនោះសកម្មភាពអាទិភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗ នៃការអភិវឌ្ឍផ្នែកកែច្នៃជលផល គឺការធ្វើឱ្យប្រសើរឡើងនូវគុណភាព សុវត្ថិភាពលើផល ផលិតផលជលផល ដើម្បីការពារសុខភាពសាធារណៈ និងជំរុញការនាំចេញ។

បច្ចុប្បន្ននេះ រដ្ឋបាលជលផលបាន និងកំពុងយកចិត្តទុកដាក់ពង្រឹងនូវបទដ្ឋានគតិយុត្តដែលចាំបាច់ ព្រមទាំងបានរៀបចំឱ្យមានមន្ទីរពិសោធន៍សម្រាប់វិភាគគុណភាព និងសុវត្ថិភាព ដើម្បីជួយសម្រួលដល់ការអនុវត្ត

ប្រព័ន្ធតាមដាន និងត្រួតពិនិត្យគុណភាពឱ្យកាន់តែមានប្រសិទ្ធភាព។ មកដល់បច្ចុប្បន្ននេះ រដ្ឋបាលជលផលសម្រេចបាននូវការរៀបចំបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសមួយចំនួន រួមមាន៖ ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គំរូ ទម្រង់ និងបែបបទនៃវិញ្ញាបនបត្រសុខភាពសម្រាប់បញ្ជាក់គុណភាពផល ផលិតផលជលផល ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល សៀវភៅណែនាំស្តីពីការនាំចេញផល ផលិតផលជលផល គោលការណ៍បច្ចេកទេសស្តីពីការអនុវត្តអនាម័យល្អ ការអនុវត្តផលិតល្អ និងគោលការណ៍ HACCP ស្តង់ដារទឹកត្រី ស្តង់ដារងៀតត្រីរ៉ស់-ឆ្តោ ស្តង់ដារបង្គាបង្កក និងស្តង់ដារប្រហុក និងក្រុមអនុវត្តសម្រាប់ការកែច្នៃបង្គាបង្កក បង្គាក្រៀម សាច់ក្តាម និងការកែច្នៃទឹកត្រី។

ចំពោះការតាមដាន និងត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផល ផលិតផលជលផល រដ្ឋបាលជលផលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយបានបញ្ជូនមន្ត្រីជំនាញសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីទប់ស្កាត់លើការប្រើសារធាតុគីមីដែលហាមឃាត់ ជាពិសេសលើផល ផលិតផលជលផលនាំចូលពីក្រៅប្រទេស។ ទន្ទឹមនឹងនេះ រដ្ឋបាលជលផលក៏បានខិតខំពង្រឹងសមត្ថភាពមន្ត្រីជំនាញ ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាព តាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រវិភាគ និងយកសំណាកសម្រាប់វិភាគគុណភាពខ្សែច្រវាក់តម្លៃជលផល និងបានពង្រឹងការយល់ដឹងរបស់អ្នកកែច្នៃ និងអ្នកពាក់ព័ន្ធដទៃទៀតអំពីការអនុវត្តអនាម័យល្អ និងការអនុវត្តផលិតល្អតាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាលផងដែរ។ ការពង្រឹងប្រព័ន្ធទីផ្សារតាមរយៈការបង្កើតសមាគមអ្នកកែច្នៃបានចំនួន២១សមាគម និងពង្រឹងការអនុវត្តនូវគោលនយោបាយច្រកចេញចូលតែមួយតាមរយៈការផ្តល់នូវសេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព សម្រាប់ជួយសម្រួលដល់វិស័យឯកជន។

**ច - ការសិក្សាស្រាវជ្រាវជលផល**

ការងារស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាប និងសមុទ្របានដំណើរការល្អប្រសើរ ដោយបានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានាដូចជា EU, JICA, MRC, FAO, NACA, CI, SEAFDEC និង World Fish Center ជាដើម។ល។ ដែលមានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវ សៀវភៅជាច្រើនពាន់ក្បាល និងប៉ុស្ទ័រជាច្រើនម៉ឺនសន្លឹកត្រូវបានបោះពុម្ពផ្សាយ។

**ឆ - វឌ្ឍនភាពផ្នែកជលផល និងផលនេសាទ**

ក្រោយពេលមានកំណែទម្រង់ស៊ីជម្រៅកន្លងមកនេះ ផលវិជ្ជមានជាច្រើនត្រូវបានផ្តល់ជូនដល់ប្រជាពលរដ្ឋ ពិសេសការធ្វើនេសាទជាលក្ខណៈគ្រួសារ និងការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវច្បាស់លាស់ តាមរយៈប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទទឹកសាប និងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាដល់ការប្រើប្រាស់ដោយចីរភាពផង និងធានាផលស្តុកក្នុងធម្មជាតិផង។

ជាក់ស្តែង បរិមាណផលនេសាទសរុប ( ទឹកសាប សមុទ្រ និងវារីវប្បកម្ម ) បានកើនឡើងគួរឱ្យកត់សម្គាល់ គឺបានកើនពី៧៤៥ពាន់តោនក្នុងឆ្នាំ២០១៤ ដល់៩១១ពាន់តោនក្នុងឆ្នាំ២០១៨ ក្នុងនោះបរិមាណផលនេសាទទឹកសាបបានកើនឡើងពី៥០៥ពាន់តោន ដល់៥៣៨ពាន់តោន ផលនេសាទសមុទ្របានកើនឡើងពី១២០ពាន់តោន ដល់១២៣ពាន់តោន និងវារីវប្បកម្មក៏មានសន្ទុះកើនឡើងដូចគ្នា គឺបានកើនពី១២០ពាន់តោន ដល់២៥៤ពាន់តោន ក្នុងចន្លោះឆ្នាំ២០១៤និង២០១៨នេះ។

**តារាងទី៤៖ ស្ថានភាពផលនេសាទពីឆ្នាំ ២០១៤ - ២០១៨**

| ល.រ | បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១ | ផលវារីវប្បកម្ម | ពាន់តោន | ១២០,០៥ | ១៤៣,១៤ | ១៧២,៥០ | ២០៧,៤៤ | ២៥៤,០៤ |
| ២ | ផលនេសាទទឹកសាប | ពាន់តោន | ៥០៥,០១ | ៤៨៧,៩០ | ៥០៩,៣៥ | ៥២៧,៨០ | ៥៣៥,០០ |
| ៣ | ផលនេសាទសមុទ្រ | ពាន់តោន | ១២០,២៥ | ១២០,៥០ | ១២០,៦០ | ១២១,០២ | ១២១,១០ |

**ជ - ការកសាងហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យផ្នែកជលផល**

ជារួម ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផលរយៈពេល៥ឆ្នាំកន្លងមកនេះ មានការប្រែប្រួលរីកចម្រើនគួរឱ្យកត់សម្គាល់ដែលជាលទ្ធផលសំខាន់រួមមាន៖ ការសាងសង់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្ម **សម្តេចតេជោ ហ៊ុន សែន** ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ ការសាងសង់មជ្ឈ-មណ្ឌលស្រាវជ្រាវនេសាទបឹងទន្លេសាប ការរៀបចំបង្កើតវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ ការរៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល១០ឆ្នាំ(២០១៥-២០២៤)។

រួមសេចក្តីមក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានជំរុញការអភិវឌ្ឍវិស័យជលផល តាមរយៈការកែទម្រង់ស៊ីជម្រៅវិស័យជលផល ដែលជាលទ្ធផល ផលិតផលជលផល ជាពិសេសត្រីសម្រាប់បម្រើឱ្យតម្រូវការម្ហូបអាហារប្រចាំថ្ងៃមានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងខណៈពេលដែលប្រជាពលរដ្ឋមានការកើនឡើងយ៉ាងលឿន។ ជាក់ស្តែង ផលត្រីដែលប្រមូលបានពីដែនទឹកធម្មជាតិមានលក្ខណៈថេរក្នុងរង្វង់៥០០ពាន់តោន ព្រមទាំងផលត្រីដែលប្រមូលតាមវាលស្រែ និងវារីវប្បកម្មមានការកើនឡើងប្រមាណ២០%ជារៀងរាល់ឆ្នាំ ដែលធានាបាននូវការផ្គត់ផ្គង់ត្រីប្រមាណ៥២,៤គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗក្នុងមួយឆ្នាំ និងរក្សាបាននូវវត្តមានគ្រប់ប្រភេទនៃធនធានជលផលទាំងអស់សម្រាប់កូនចៅជំនាន់ក្រោយបានស្គាល់ និងប្រើប្រាស់ជាបន្តទៀត។

## ២.២.៤. ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ

ធនធានព្រៃឈើ បានផ្តល់សារប្រយោជន៍យ៉ាងច្រើនក្រៃលែងដល់សង្គមជាតិយើង តាំងពីដើមរហូតមកដល់បច្ចុប្បន្ន និងទៅអនាគត។ ព្រៃឈើពុំគ្រាន់តែមានតម្លៃខាងសេដ្ឋកិច្ច និងសង្គមជាតិប៉ុណ្ណោះទេ ប៉ុន្តែវានៅមានតម្លៃខ្ពស់មិនអាចប៉ាន់ប្រមាណបានលើផ្នែកថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិ ធ្វើឱ្យធាតុអាកាសមានភាពកាន់តែប្រសើរឡើង ធ្វើឱ្យខ្យល់បរិសុទ្ធ រក្សាបាននូវនិយ័តភាពប្រភពទឹក ការពារទីជម្រាល និងជីវចម្រុះ។ ព្រៃឈើបានជួយទ្រទ្រង់ និងលើកកម្ពស់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋរាប់លាននាក់ ដែលពឹងអាស្រ័យទៅលើផល អនុផលព្រៃឈើ។ សរុបសេចក្តីមក ព្រៃឈើគឺជាប្រភពការពារភពផែនដីយើង និងជីវិតយើង។

ព្រៃឈើគឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលបានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងជាពិសេសក្នុងច្បាប់ស្តីពីព្រៃឈើ។ ដោយហេតុផលនេះ ប្រជាពលរដ្ឋគ្រប់រូបត្រូវមានកាតព្វកិច្ចចូលរួមចំណែកថែរក្សាការពារ អភិរក្ស និងអភិវឌ្ឍព្រៃឈើឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយៗទៀត។ សកម្មភាពកាប់ឈើខុសច្បាប់ ការកាប់ រានដីព្រៃឈើ និងបទល្មើសព្រៃឈើផ្សេងទៀតបានធ្វើឱ្យព្រៃឈើរេចរឹល និងឈានទៅដល់ការបាត់បង់ព្រៃឈើ ដែលជាកត្តាជះឥទ្ធិពលដល់កា-លានុវត្តភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការបាត់បង់ព្រៃឈើអាចរួមចំណែកធ្វើឱ្យប្រឈមមុខនឹងគ្រោះមហន្ត-រាយធម្មជាតិនានា ដូចជា៖ គ្រោះរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ ការហូរច្រោះបាក់ដី ការកើនឡើងកម្តៅលើភពផែនដី ការប្រែប្រួលអាកាសធាតុ និងការបាត់បង់ប្រភពទឹកសម្រាប់ប្រើប្រាស់ជាដើម។

កម្មវិធីព្រៃឈើជាតិត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអនុម័តនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។ រាជរដ្ឋាភិបាលបានប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ បន្តធ្វើសកម្មភាពកែទម្រង់វិស័យព្រៃឈើ ដើម្បីពង្រឹងការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព ដោយបានដាក់ចេញនូវបទបញ្ជាជាបន្តបន្ទាប់ និងផ្អែកលើមូលដ្ឋានសំខាន់៣គឺ៖

(១) គ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព ដោយត្រួតពិនិត្យយ៉ាងតឹងរ៉ឹងនូវការធ្វើអាជីវកម្មព្រៃឈើ និងការគ្រប់គ្រងព្រៃឈើ ដែលធានាបានគ្រប់គ្រាន់នូវព្រៃបម្រុងទុកសម្រាប់ការប្រើប្រាស់ក្នុងស្រុក ការការពារទប់ទល់នឹងគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ព្រមទាំងរក្សាបាននូវតំបន់ដីសើម ដែលជាដែនជម្រកមច្ឆជាតិ។

(២) ការពារធនធានធម្មជាតិ ជីវចម្រុះ និងប្រភេទជិតផុតពូជ។

(៣) ជំរុញនិងអភិវឌ្ឍសហគមន៍ព្រៃឈើដោយតម្លាភាព និងគ្រប់គ្រងដោយប្រជាពលរដ្ឋនៅមូលដ្ឋាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តកម្មវិធីកែទម្រង់វិស័យព្រៃឈើ។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ក្រសួងបានយកចិត្តទុកដាក់អនុវត្តលើសកម្មភាពជាច្រើនរួមមាន ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការបង្កើតនិងពង្រឹងសហគមន៍ព្រៃឈើ ការអនុវត្តវិធានការយ៉ាងម៉ឺងមាត់ក្នុងការគ្រប់គ្រង និងទប់ស្កាត់បទល្មើសព្រៃឈើ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃឈើ ការបង្កើតតំបន់ព្រៃសម្រាប់អភិរក្សធនធានពន្ធុរុក្ខជាតិ និងសត្វព្រៃ ព្រមទាំងបោះបង្គោលព្រំប្រទល់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ការបណ្តុះកូនឈើនៅតាមស្ថានីយផ្សព្វផ្សាយ ការដាំកូនឈើនៅតំបន់ស្តារព្រៃឈើឡើងវិញ និងទីតាំងផ្សេងៗ ដែលការងារទាំងអស់នេះ ពិតជាបានឆ្លើយតបទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការកែទម្រង់វិស័យព្រៃឈើ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់លើការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលធំៗមួយចំនួនគួរជាទីពេញចិត្ត។ លើសពីនេះទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញអំពីការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា តាមរយៈការអនុវត្តអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤។ នាពេលកន្លងទៅនេះ ក្រសួងបានចូលរួមអនុវត្តយ៉ាងពេញទំហឹងជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងជាពិសេសបទល្មើសនានានៅភាគឦសាន្តនៃប្រទេស។

នៅក្នុងឆ្នាំកន្លងទៅនេះ រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់ធំមួយទៀតក្នុងវិស័យព្រៃឈើ ដោយបានសម្រេចផ្ទេរផ្ទៃដីព្រៃការពារចំនួន១៣កន្លែង ស្មើនឹង១ ៦៨៤ ៧៥៥ហ.ត និងផ្ទៃដីព្រៃដែលរដ្ឋបាលព្រៃឈើកំពុងដំណើរការរៀបចំដាក់ជាព្រៃការពារ៥កន្លែងទៀតមានទំហំ៩៥១ ៣២៥ហ.ត ដែលនាំឱ្យផ្ទៃដីដែលត្រូវផ្ទេរសមត្ថកិច្ចនេះមានទំហំសរុប ២ ៦៣៦ ០៨០ហ.ត ផ្ទេរការគ្រប់គ្រងពីរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថានគ្រប់គ្រងបន្ត ហើយក្រសួងបរិស្ថានបានផ្ទេរត្រឡប់មកវិញនូវដីសម្បទានសេដ្ឋកិច្ច ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់គ្រងវិញ។ នេះគឺជារបត់មួយថ្មីទៀតនៃការកែទម្រង់ស៊ីជម្រៅក្នុងវិស័យព្រៃឈើដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីអនុវត្តកិច្ចការដ៏សំខាន់នេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ស្របជាមួយនឹងការកែទម្រង់ថ្មីនេះដែរ ក្រសួងបានប្តូរឈ្មោះពីមន្ទីរកសិកម្មរាជធានីខេត្ត ទៅជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងបានដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។ បន្ថែមពីនេះទៀតនោះ ក្រសួងក៏បានផ្ទេរធនធាន

និងក្រុមខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៃខណ្ឌ ផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។

ទន្ទឹមនឹងនេះ ក្រសួងបានចូលរួមត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ជូនក្រុមហ៊ុនឯកជននាពេលកន្លងមក និងបានចាត់វិធានការដកហូតមកវិញចំពោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលមិនបានអនុវត្តតាមកិច្ចសន្យា ព្រមទាំងបានពង្រឹងយន្តការនៃការប្រមូលចំណូលពីសម្បទានដីសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព។

ក្នុងការចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ក្រសួងសម្រេចបានលទ្ធផលសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងវិស័យព្រៃឈើដូចខាងក្រោម៖

**ក- សហគមន៍ព្រៃឈើ**

គិតត្រឹមឆ្នាំ២០១៨ ក្រសួងបានបង្កើតសហគមន៍ព្រៃឈើសរុបចំនួន៦១៤សហគមន៍ គ្របដណ្តប់លើផ្ទៃដី ៥០៨ ២០៧ហ.ត ក្នុងនោះ ក្រសួងបានចេញប្រកាសទទួលស្គាល់ចំនួន៤៨៤សហគមន៍ លើផ្ទៃដី ៤៣៧ ៣៧២ ហ.ត និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន៤៣២សហគមន៍ លើផ្ទៃដី ៣៦៤ ៥៤៨ហ.ត និងបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន៨៥សហគមន៍ គ្របដណ្តប់លើផ្ទៃដីទំហំ ៥៥ ៣៧១ហ.ត។

ជាការវាយតម្លៃរួម សហគមន៍ព្រៃឈើបានចូលរួមចំណែកក្នុងការការពារធនធានព្រៃឈើបានយ៉ាងល្អប្រសើរ។ ទោះជាយ៉ាងនេះក្តី សហគមន៍ព្រៃឈើមួយចំនួននៅមានភាពទន់ខ្សោយផ្នែកគ្រប់គ្រងសហគមន៍ និងម្យ៉ាងទៀត សហគមន៍ព្រៃឈើក៏នៅជួបការលំបាកខាងជីវភាព ពឹងផ្អែកខ្លាំងលើការយកផលអនុផលព្រៃឈើ ដែលនៅពេលខាងមុខនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវបង្កើនការផ្តល់បច្ចេកទេសកសិកម្មចម្រុះ ការចិញ្ចឹមសត្វក្នុងដែនព្រៃសហគមន៍គ្រប់គ្រង ដើម្បីបង្កើនជីវភាពរស់នៅឱ្យបានល្អប្រសើរបន្ថែមទៀត។

**ខ- គម្របព្រៃឈើ**

តាមទិន្នន័យគម្របព្រៃឈើ នៅឆ្នាំ២០១០ មានផ្ទៃដីសរុបទំហំ ១០ ៣៦៣ ៧៨៩ហ.ត ស្មើនឹង៥៧,០៧% និងផ្ទៃដីពុំមានគម្របព្រៃឈើមានទំហំសរុប ៧ ៧៩៦ ៨៨៥ ស្មើនឹង ៤២,៩៣% នៃផ្ទៃដីសរុប។ នៅឆ្នាំ២០១៤ ផ្ទៃដីគម្របព្រៃឈើមានទំហំ ៨ ៩៨៥ ១៦៣ហ.ត ស្មើនឹង៤៩,៤៨% និងដីមិនមែនគម្របព្រៃឈើមានទំហំសរុប ៩ ១៧៥ ៥១០ហ.ត ស្មើនឹង ៥០,៥២% នៃផ្ទៃដីសរុប។ បច្ចុប្បន្ន រដ្ឋបាលព្រៃឈើបាននិងកំពុងធ្វើការបកស្រាយគម្របព្រៃឈើឆ្នាំ២០១៨ ក្នុងនោះបានបញ្ចប់ការទាញយករូបភាពផ្កាយរណប (Landsat 8) និងបញ្ចប់ការបកស្រាយចំណាត់ថ្នាក់ប្រភេទព្រៃឈើនីមួយៗ។

**គ- ការងារដាំឈើ**

ផ្ទៃដីដាំឈើសរុបពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ សម្រេចបានចំនួន ៣៣៨ ០៤០ហ.ត ក្នុងនោះការដាំឈើជាចម្ការដោយផ្នែកឯកជន ពិសេសសម្បទានដីសេដ្ឋកិច្ចមានចំនួន ៣៣១ ៩៤៣ហ.ត។ ការកែទម្រង់លើការងារដាំឈើឡើងវិញ ត្រូវបានយកចិត្តទុកដាក់អនុវត្តយ៉ាងមានប្រសិទ្ធភាព។ ផ្អែកតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតជាគោលការណ៍ដាំឈើលើដីព្រៃរេចរិលដោយសហការដៃគូជាមួយវិស័យឯកជន (លិខិតលេខ១២០ សជណ.កស ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា)។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីវិធានព្រៃឯកជន (ប្រកាសលេខ៣២៧ ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧) ដែលប្រកាសនេះ មានគោលបំណងកំណត់នូវវិធានព្រៃឯកជន សម្រាប់ជាគោលការណ៍ណែនាំក្នុងការបង្កើត និងអភិវឌ្ឍន៍ព្រៃឯកជន។

ក្រសួងបានស្នើសុំចុះបញ្ជីដីរដ្ឋ និងរៀបចំឯកសារស្នើសុំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៣៨ទីតាំង ដែលមានផ្ទៃដីសរុបទំហំ ២១១ ៩២២ហ.ត ស្ថិតក្នុងខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ និងខេត្តស្ទឹងត្រែង។

ជារៀងរាល់ឆ្នាំ ក្រសួងបានរៀបចំពិធីរុក្ខទិវាថ្នាក់ជាតិ ០៩ កក្កដា ដែលប្រារព្ធឡើងក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ស្ថិតនៅភូមិសាស្ត្រមួយចំនួន និងបានដាំដើមឈើប្រភេទគ្រញូង ធ្នង់ កកោះ គីនីន និងឈើទាល។ល។ ព្រមទាំងបានដឹកប្រឡាយការពារចម្ការឈើដាំ ស្ថិតនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ និងបានបង្កើតឡូត៍បង្ហាញកសិ-រុក្ខកម្ម នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ។

**តារាងទី៥÷ ការដាំឈើដោយរដ្ឋបាលព្រៃឈើ និងដៃគូឆ្នាំ២០១៤-២០១៨**

| ឆ្នាំ | ដាំឈើជាចម្ការ (ហ.ត) | | | | រុក្ខទិវា (ហ.ត) | | សរុប |
|---|---|---|---|---|---|---|---|
| | រដ្ឋបាលព្រៃឈើ | ដៃគូអភិវឌ្ឍន៍ | លក្ខណៈគ្រួសារ | សម្បទានដីសេដ្ឋកិច្ច | ថ្នាក់ជាតិ | រាជធានី-ខេត្ត | |
| ២០១៤ | ៤១០ | ១ ៥២១ | ៣៩ | ៣ ៨៦៣,០០ | ២០ | ៤០,៥០ | **៥ ៨៩៣,៥០** |
| ២០១៥ | ៤០៥ | ១ ៨១០ | ៦០ | ៥១ ៧០៧,០០ | ១០ | ២០,០០ | **៥៤ ០១២,០០** |
| ២០១៦ | ៣៦០ | ៥៧៥ | | ២៥០ ០៥៦,៥៨ | ១២ | ៨០,៧០ | **២៥១ ០៨៤,២៨** |
| ២០១៧ | ៦៥ | ៣៨០ | | ២៦ ៣១៦,៤២ | ១០ | ២៨,០០ | **២៦ ៧៩៩,៤២** |
| ២០១៨ | ១៧៦ | ៦៥ | | ៦៥៣,០ | ១០ | ២៥,០០ | **៧៧៤,០០** |
| សរុប | **១ ៤១៦** | **៤ ២៨៦** | **៩៩** | **៣៣២ ៥៩៦**,០០ | **៦២** | **១៩៣,២០** | **៣៣៨ ៥៦៣,២០** |

### ឃ. ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើពីឆ្នាំ២០១៤ ដល់២០១៨ ត្រូវបានអនុវត្តយ៉ាងសកម្ម។ នៅឆ្នាំ២០១៨ បានទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃសរុបចំនួន ១ ០៩៣ករណី ថយចុះ៣៣៥ ករណី បើប្រៀបធៀបឆ្នាំ២០១៧ មានចំនួន១ ៤២៨ករណី ក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន៥៨២ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការមានចំនួន៥១១ករណី។ ជាមួយគ្នានេះ រដ្ឋបាលព្រៃឈើបានចុះផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្ត និងចែកឯកសារពាក់ព័ន្ធដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ស្តីពីព្រៃឈើ។

## ២.៣. ការពង្រឹងសមត្ថភាពស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

នៅក្នុងនីតិកាលកន្លងមក ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលបានកំណត់អាទិភាពចម្បងចំនួន៤ គឺ៖ ផ្លូវ ទឹក ភ្លើង និងមនុស្ស។ ប៉ុន្តែនៅក្នុងបរិបទសេដ្ឋកិច្ចពុទ្ធិ និងបច្ចេកវិទ្យាទំនើបប្រកបដោយឧត្តមភាព និងការប្រកួតប្រជែងដែលមានសន្ទុះយ៉ាងខ្លាំងក្លា រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភាបានផ្តល់ការយកចិត្តទុកដាក់កាន់តែខ្លាំងលើការអភិវឌ្ឍធនធានមនុស្ស មានន័យថាប្រែក្លាយអាទិភាពចម្បងចំនួន៤គឺ៖ មនុស្ស ផ្លូវ ភ្លើង និងទឹក។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រងធនធានមនុស្សតាមរយៈការសិក្សាពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងគុណភាពដោយផ្អែកលើទំហំការងារជាក់ស្តែង ការកំណត់តួនាទីភារកិច្ច ការពិពណ៌នាការងារ ការវាយតម្លៃលើលទ្ធផលការងារ ការរៀបចំគោលនយោបាយធនធានមនុស្ស ការរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា ការកែទម្រង់រចនាសម្ព័ន្ធ មុខងារនិងការអនុវត្តការងារ ការចុះពង្រឹងការគ្រប់គ្រងមន្ត្រីកសិកម្មនៅតាមបណ្តាអង្គភាព ទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានីខេត្តជាប់ជាប្រចាំ។ ក្នុងឆ្នាំ២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន ៦ ៧៩៤ នាក់ មាននារី ១ ៦០៤នាក់ ស្មើនឹង២៣% ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានចំនួន ២ ៨៨៣នាក់ នារី ៨១៥នាក់ ស្មើនឹង២៨% ថ្នាក់រាជធានី ខេត្តមានចំនួន ៣ ៩១១នាក់ នារី ៧៨៩នាក់ ស្មើនឹង២០%។

ដើម្បីឆ្លើយតបទៅនឹងការកំណត់អាទិភាព "មូលធនមនុស្ស" របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការប្រកបដោយគុណវុឌ្ឍិខ្ពស់តាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យម និងរយៈពេលវែង ទាំងក្នុងនិងក្រៅប្រទេស។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ កន្លងមកនេះ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីរាជការបានចំនួន ២ ៩២៣នាក់ ក្នុងនោះមាននារីចំនួន៦៥២នាក់។ វគ្គបណ្តុះបណ្តាលក្នុងប្រទេសសរុបបានចំនួន ២ ២៨៧នាក់ នារី ៤៦៤នាក់ ក្នុងនោះវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យមបានចំនួន ២ ២៨០នាក់ នារីចំនួន៤៦៣នាក់ និងបណ្តុះបណ្តាលរយៈពេលវែងបានចំនួន០៧នាក់ នារីចំនួន០១នាក់ (វគ្គវិក្រឹត្យការ)។ ដោយឡែកចំពោះវគ្គបណ្តុះបណ្តាលក្រៅប្រទេសសរុបបានចំនួន៦៣៦នាក់ នារីចំនួន១៨៨នាក់ ក្នុងនោះវគ្គបណ្តុះបណ្តាលរយៈពេលខ្លីបានចំនួន៦១៦នាក់ នារីចំនួន១៧៨នាក់ និងវគ្គបណ្តុះបណ្តាលរយៈពេលវែងបានចំនួន២០នាក់ នារីចំនួន១០នាក់។

ទោះបីជាយ៉ាងនេះក៏ដោយ ជាទូទៅក្រសួងមានមន្ត្រីដែលមានវិជ្ជាជីវៈសមស្រប តិចជាងតម្រូវការជាក់ស្តែង។ ជាលទ្ធផល សមត្ថភាពកិច្ចការរដ្ឋបាល និងបច្ចេកទេសនៅមានកម្រិត និងមានកង្វះខាតមន្ត្រីជំនាញ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល និងការផ្លាស់ប្តូរនៃល្បឿនសេដ្ឋកិច្ចបច្ចុប្បន្ន សម្រាប់បម្រើឱ្យការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព។ ដោយសារកត្តាទាំងអស់នេះ ក្រសួងត្រូវរៀបចំផែនការ កម្មវិធីអប់រំ និងបណ្តុះបណ្តាល និងការគ្រប់គ្រងមន្ត្រីរាជការឱ្យបានសមស្របតាមតម្រូវការជាក់ស្តែង។

ការពង្រឹងសមត្ថភាពស្ថាប័នគឺជាអាទិភាពសម្រាប់កំណែទម្រង់ និងការអនុវត្ត **ផ.ក.យ.អ.វ.ក** ក៏ដូចជាការប្រើប្រាស់ និងអភិរក្សធនធានធម្មជាតិ ដូចជាព្រៃឈើ និងជលផលឱ្យមាននិរន្តរភាព។ ក្រសួងនឹងសហការគ្នាជាមួយភាគីផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ដូចជា វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍នានា ដែលមានជំនាញពិសេសរៀងខ្លួន ឱ្យចូលរួមចំណែកក្នុងការពង្រឹងសមត្ថភាពស្ថាប័នវិស័យកសិម្មផងដែរ។ សមត្ថភាពក្នុងការអភិវឌ្ឍបច្ចេកទេស និងការផ្សព្វផ្សាយ ទាមទារឱ្យគ្រប់ផ្នែកពាក់ព័ន្ធចូលរួមចំណែកទៅតាមជំនាញផ្សេងៗ។ ស្ថាប័នស្រាវជ្រាវ និងអភិវឌ្ឍន៍ សាកលវិទ្យាល័យ សាលាជាតិកសិកម្មទាំងពីរ និងស្ថាប័នពាក់ព័ន្ធដ៏ទៃទៀត ដោយសហការជាមួយវិស័យឯកជន សង្គមស៊ីវិល និងដៃគូដទៃទៀត ត្រូវកំណត់អាទិភាព អភិវឌ្ឍការស្រាវជ្រាវកសិកម្ម រៀបចំផ្សព្វផ្សាយបច្ចេកទេសតាមរបៀបទំនើបជាលក្ខណៈឌីជីថល ហើយត្រូវឱ្យច្បាស់ថាបច្ចេកទេសថ្មីមានលក្ខណៈសមស្រប និងបំពេញនូវតម្រូវការទីផ្សារ ព្រមទាំងជួយដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជនបទ។

ដោយឡែក កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងវិស័យឯកជនផងដែរ កំពុងត្រូវបានពង្រឹង និងយកចិត្តទុកដាក់ខ្ពស់។ រីឯដំណើរការប្រព្រឹត្តទៅនៃការកែទម្រង់រដ្ឋបាលសាធារណៈ ហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងការបញ្ជ្រាបយេនឌ័រនិងកុមារ ក៏ដូចជាការលើកកម្ពស់ការពង្រឹងរចនា-សម្ព័ន្ធចាត់តាំងដឹកនាំរបស់ក្រសួងទាំងថ្នាក់កណ្តាល រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ក៏ត្រូវបានពង្រឹងក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់ និងប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

## ២.៤. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការអនុវត្តគម្រោងសកម្មភាពនិងសូចនាករនានា សម្រាប់ផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធភាពសម្រេចបាន ដែលបានកំណត់យ៉ាងសមស្របនៅក្នុងការធ្វើផែនការ និងការរៀបចំគម្រោងសកម្មភាពនីមួយៗ។ ដូច្នេះ ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាឧបករណ៍ដ៏ស័ក្តិសិទ្ធិសម្រាប់ផ្ទៀងផ្ទាត់រាល់សូចនាករលទ្ធផល (Outcomes & Outputs) នៅពាក់កណ្តាលអាណត្តិ និង

ពេញអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងដើម្បីជាមូលដ្ឋានសម្រាប់វាយតម្លៃការអនុវត្តគោលនយោបាយតាមផ្នែក ក៏ដូចជាគោលនយោបាយថ្នាក់ជាតិ។ ទោះបីយ៉ាងណាក៏ដោយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ក៏នឹងត្រូវបង្ហាញ និងបញ្ជាក់នូវសូចនាករជាច្រើនសម្រាប់ធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្តផងដែរ។

ដើម្បីធានាដល់ការអនុវត្តយ៉ាងពេញលេញ នូវការពិនិត្យតាមដាននិងវាយតម្លៃ នាយកដ្ឋានផែនការនិងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តសកម្មភាពតាមដាននិងវាយតម្លៃនេះ។ របាយការណ៍លទ្ធផលការងារសម្រាប់គម្រោងទាំងនោះ ត្រូវរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត និងការវាយតម្លៃក្រោយពេលអនុវត្ត។ បណ្តានាយកដ្ឋានអង្គភាពជំនាញនានាដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ បានរាយការណ៍ជូនក្រសួង (នាយកដ្ឋានផែនការនិងស្ថិតិ) ពីលទ្ធផលសម្រេចបានតាមរយៈការផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ។ របាយការណ៍អនុវត្ត និងសមិទ្ធផលសម្រេចបានក្នុងការអនុវត្តនេះ ត្រូវបានរៀបចំបូកសរុបដោយនាយកដ្ឋានផែនការនិងស្ថិតិ ហើយត្រូវរាយការណ៍ជូនក្រសួងពិនិត្យនិងសម្រេច។ ផ្អែកលើរបាយការណ៍ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការបូកសរុប រួចរាយការណ៍ជូនទៅក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានរាយការណ៍ជូនរាជរដ្ឋាភិបាលកម្ពុជា។

## ២.៥. បញ្ហាប្រឈមក្នុងវិស័យកសិកម្ម

ជារួម កសិកម្មកម្ពុជានៅមានសក្តានុពលច្រើន ដែលយើងពុំទាន់បានប្រើប្រាស់ឱ្យអស់លទ្ធភាពនៅឡើយ។ ការអនុវត្ត **ផ.យ.អ.វ.ក** (២០១៤ - ២០១៨) កន្លងមក គឺត្រូវបានវាយតម្លៃថា សម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។ ទោះបីជាយ៉ាងនេះក្តី ក៏យើងនៅជួបប្រទះបញ្ហាប្រឈមមួយចំនួន មានជាអាទិ៍៖

(១) **ផ្នែកផលិតភាពកសិកម្មនិងទីផ្សារ៖** ផលិតភាពក្នុងការដាំដុះ ក៏ដូចជាការចិញ្ចឹមសត្វ នៅមានកម្រិតទាបនៅឡើយ ដែលប្រឈមខ្លាំងក្នុងការប្រកួតប្រជែងទីផ្សារ ពិសេសថ្លៃដើមផលិតកម្មរបស់កសិករនៅមានកម្រិតខ្ពស់។ ម៉្យាងវិញទៀត ធាតុចូលកសិកម្ម ពិសេសជីគីមី ថ្នាំកសិកម្ម ចំណីសត្វ ថ្នាំព្យាបាលសត្វជាដើម ត្រូវបាននាំចូលពីបរទេស ដោយសារឧស្សាហកម្មក្នុងស្រុកផ្នែកនេះនៅមិនទាន់រីកចម្រើនគ្រប់គ្រាន់នៅឡើយ ដែលធ្វើឱ្យថ្លៃដើមខ្ពស់។ ការបន្សុំារបស់កសិករទៅនឹងការប្រែប្រួលអាកាសធាតុ ការផ្សព្វផ្សាយបច្ចេកទេសតាមផ្នែកនីមួយៗ និងការផ្តល់សេវាព័ត៌មានទីផ្សារកសិផលទៅដល់កសិករ គឺនៅមិនទាន់មានភាពទូលំទូលាយ។ ម៉្យាងទៀត កសិករតែងជួបប្រទះនូវការធ្លាក់ចុះនៃតម្លៃកសិផលក្រោយពេលប្រមូលផល ហើយការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាក៏នៅពុំទាន់បានល្អប្រសើរ។ ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្មឱ្យចំគោលដៅ និងសក្តានុពលនៅតាមភូមិសាស្ត្រនីមួយៗស្ថិតនៅតែជាបញ្ហា ដែលក្រសួងកំពុងគិតគូរអំពីការកំណត់តំបន់ដាំដុះកសិកម្មឱ្យបានសមស្រប។ លើសពីនេះទៀត អត្រាការប្រាក់ខ្ពស់ និងការទទួលបានហិរញ្ញប្បទាននៅមានកម្រិត ដែលជាហេតុនាំឱ្យប៉ះពាល់ដល់ថ្លៃដើមផលិត។

(២) **ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងភស្តុភារកម្ម** (Logistics)៖ ប្រព័ន្ធស្រោចស្រពកសិកម្មនៅពុំទាន់បានគ្របដណ្តប់លើផ្ទៃដីដាំដុះឱ្យបានទូលំទូលាយ ជាពិសេសការរៀបចំប្រព័ន្ធប្រឡាយបង្ហូរទឹកចូលស្រែដោយស្វ័យប្រវត្តិពុំទាន់បានពង្រីកដល់ដីស្រែរបស់កសិករនៅឡើយ។ កសិករភាគច្រើនបានប្រើប្រាស់ចំណាយក្នុងការបូមទឹកជាកត្តាមួយបន្ថែមលើថ្លៃដើមផលិតកម្ម។ បញ្ហាតម្លៃដឹកជញ្ជូន អគ្គិសនី និងប្រព័ន្ធសេវាភស្តុភារ គឺជាបញ្ហាមួយដែលរួមចំណែកធ្វើឱ្យថ្លៃដើមផលិតកម្មខ្ពស់ ពិបាកនឹងធ្វើការប្រកួតប្រជែងជាមួយផលិតផលកសិកម្មពីបរទេស។

ជាមួយនេះ កង្វះធនធានក្នុងការស្តារ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការបង្កើនផលិតភាពលើសក្កា-នុពលដីធ្លី និងស្រែចម្ការរបស់កសិករក៏ត្រូវតែមានវិធានការដោះស្រាយនាពេលខាងមុខ។

(៣) **ផ្នែកស្រាវជ្រាវបច្ចេកវិទ្យា និងបច្ចេកទេសកសិកម្ម៖** ការងារស្រាវជ្រាវ និងការផ្តល់សេវាបច្ចេកទេសកសិកម្មនៅមានកម្រិត ហើយសមត្ថភាពទទួលយកចំណេះដឹងអំពីបច្ចេកទេសដាំដុះ ចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងការប្រើប្រាស់ធាតុចូលកសិកម្មសមស្របតាមបទដ្ឋានបច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផលរបស់ប្រជាកសិករក៏នៅមានកម្រិត ដែលបានជះឥទ្ធិពលដល់ថ្លៃដើមផលិតខ្ពស់ ពិបាកប្រជែងនៅលើទីផ្សារ។ ម៉្យាងវិញទៀត ការវិនិយោគក្នុងផ្នែកអប់រំ ស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មនៅមានទំហំតូច ដែលត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់នាពេលខាងមុខ។

(៤) **ការបង្ក្រាបបទល្មើស៖** បទល្មើសព្រៃឈើ ជលផល ការលួចនាំចូលនិងនាំចេញសត្វ សម្ភារកសិកម្មដោយខុសច្បាប់នៅតែកើតមាន ជាពិសេសនៅបណ្តាខេត្តជាប់ព្រំដែន។ សកម្មភាពកាប់រានហ៊ុមព័ទ្ធដីព្រៃឈើ ការរានដីព្រៃលិចទឹកដោយខុសច្បាប់ គឺនៅតែកើតមានពុំចេះចប់រហូតមកទល់បច្ចុប្បន្ននេះ។ ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល ទាមទារឱ្យមានការកែសម្រួលស្របទៅតាមសភាពការណ៍ជាក់ស្តែង។ កិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធក្នុងការងារបង្ក្រាបបទល្មើសគ្រប់ប្រភេទគឺជាកត្តាចាំបាច់បំផុត។

(៥) **ធនធានមនុស្ស៖** ធនធានមនុស្សត្រូវបានចាត់ទុកជាអាទិភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ សំដៅលើកកម្ពស់ចំណេះដឹង ជំនាញបច្ចេកទេស សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ សម្រាប់បម្រើឱ្យការអភិវឌ្ឍន៍វិស័យកសិកម្ម។ ទោះបីជាយ៉ាងនេះក្តី តម្រូវការពង្រឹងសមត្ថភាព និងគុណភាព នៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ដែលបាននិងកំពុងប្រែប្រួលរីកចម្រើនទៅតាមសេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មទី៤។

## ២.៦. ការវាយតម្លៃ និងសេចក្តីសន្និដ្ឋាន

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ សមិទ្ធផលធំៗនៃវិស័យកសិកម្មត្រូវបានវាយតម្លៃថាសម្រេចបានគួរជាទីមោទនៈ ថ្វីត្បិតវិស័យនេះទទួលរងនូវឥទ្ធិពលអាក្រក់ពីការប្រែប្រួលអាកាសធាតុយ៉ាងណាក្តី។ ជាក់ស្តែង ផលិតកម្មដំណាំស្រូវដែលជាដំណាំសៀងយុទ្ធសាស្ត្ររបស់កម្ពុជាបានកើនឡើង សម្រាប់បម្រើឱ្យឧស្សាហកម្មចំណីអាហារក្នុងស្រុក និងការនាំចេញទៅកាន់ទីផ្សារតំបន់និងពិភពលោក។ ផលិតកម្មដំណាំឧស្សាហកម្ម ពិសេសដំណាំកៅស៊ូ ដំឡូងមី ដូងប្រេង ស្វាយចន្ទី ពោត ចេក ស្វាយ សណ្តែកគ្រប់ប្រភេទ ម្រេច ... ។ល។ កំពុងមានសន្ទុះរីកចម្រើនគួរជាទីពេញចិត្ត ពិសេសការរីកលូតលាស់នៃកសិដ្ឋានរបស់ផ្នែកឯកជន ក៏ដូចជាកសិដ្ឋានរបស់គ្រួសារកសិករ។

ជាការកត់សម្គាល់ ផលិតកម្មសត្វនៅកម្ពុជា ជាពិសេស ជ្រូក និងបក្សី (មាន់ទា) មានការវិវឌ្ឍឈានឡើងគួរជាទីពេញចិត្ត ទាំងការផលិតជាលក្ខណៈគ្រួសារ និងកសិដ្ឋានមានលក្ខណៈពាណិជ្ជកម្ម។ ទោះជាយ៉ាងនេះក្តី ការចិញ្ចឹមគោក្របីសម្រាប់បម្រើឱ្យការអូសទាញរបស់កសិករបានធ្លាក់ចុះ។ ការថយចុះនេះគឺបណ្តាលមកពីកង្វះពលកម្មនៅជនបទ (ចំណាកស្រុក) ប៉ុន្តែការប្រើប្រាស់គ្រឿងយន្តក្នុងផលិតកម្មកសិកម្មបានជំនួសឱ្យការប្រើប្រាស់កម្លាំងអូសទាញគោក្របី។ ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ និងកសិដ្ឋានឯកជនមានការរីកចម្រើន ប៉ុន្តែនៅជួបបញ្ហាប្រជែងទីផ្សារខ្ពស់។ ជាការវាយតម្លៃជារួម ការបង្កើនការងារស្រាវជ្រាវ និងផ្សព្វផ្សាយពូជ ការបង្ការជំងឺឆ្លងសត្វ និងការពង្រីកចំណេះដឹងផ្នែកបច្ចេកទេសនៃការចិញ្ចឹមសត្វដល់ប្រជាកសិករមានភាពប្រសើរជាងមុន និងមានប្រសិទ្ធភាពក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ។

ការគ្រប់គ្រងធនធានព្រៃឈើទទួលរងបញ្ហាប្រឈមជាច្រើន ដែលទាមទារឱ្យមានការខិតខំបន្ថែមទៀត ដោយត្រូវរក្សាតុល្យភាពរវាង "ការអភិរក្ស និងការអភិវឌ្ឍ" ហើយដែលត្រូវតែខិតខំរកឱ្យឃើញនូវដំណោះស្រាយដ៏សមស្របមួយប្រកបដោយប្រសិទ្ធភាព និងចូលរួមដោយសុឆន្ទៈជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗ។ យុទ្ធសាស្ត្រក្នុងការបង្កើនគម្របព្រៃឈើនឹងត្រូវបន្តអនុវត្ត ពិសេសការបង្កើនការដាំដុះដើមឈើពីផ្នែកឯកជនតាមរយៈដីសម្បទានសេដ្ឋកិច្ច (ព្រៃដាំ កៅស៊ូជាដើម) បណ្តុះនិងចែកចាយកូនឈើសម្រាប់ប្រជាជននិងសហគមន៍ដាំនៅមូលដ្ឋាន និងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ ដោយយកច្បាប់ស្តីពីព្រៃឈើជាបង្អែកដ៏រឹងមាំ ព្រមទាំងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើឱ្យមានលក្ខណៈល្អប្រសើរជាងមុន ដើម្បីជួយដល់ការអភិរក្សព្រៃឈើសហគមន៍។

ការគ្រប់គ្រងធនធានជលផលក៏ទទួលរងបញ្ហាប្រឈមដូចគ្នានឹងផ្នែកព្រៃឈើដែរ។ បទល្មើសនេសាទ ការរុករានកាប់បំផ្លាញព្រៃលិចទឹកនៅតែបន្តកើតមាន។ សហគមន៍នេសាទនៅតែមានសមត្ថភាពមិនទាន់គ្រប់គ្រាន់ ដែលទាំងអស់នេះទាមទារឱ្យមានការបន្តពង្រឹងបន្ថែមទៀត ហើយច្បាប់ស្តីពីជលផលចាំបាច់ត្រូវតែបង្កើនប្រសិទ្ធភាពនៃការអនុវត្តនាពេលខាងមុខ។

លើសពីនេះទៅទៀត ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល។ តែទោះយ៉ាងណាក្តី អ្វីដែលសម្រេចបានទាំងអស់នេះ មិនទាន់ឆ្លើយតបបានទៅនឹងមហិច្ឆតាធំធេងដែលយើងចង់បាននៅឡើយទេ ហើយនៅតែទាមទារឱ្យបន្តជំរុញការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាមានលក្ខណៈវិទ្យាសាស្ត្រទំនើប បរិយាប័ន្ន និងមានប្រសិទ្ធភាពខ្ពស់។

# ជំពូកទី៣ : យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម

## ៣.១. ចក្ខុវិស័យ និងបេសកកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសិក្សា និងវាយតម្លៃអំពីកាលានុវត្តភាព ផលប៉ះពាល់ និងកង្វះខាតផ្សេងៗ តាមរយៈមេរៀន និងបទពិសោធន៍ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម កម្មវិធី និងអនុកម្មវិធីកន្លងមក ដែលជាមូលដ្ឋានសំខាន់សម្រាប់រៀបចំ និងវិភាជធនធានក្នុងផែនការយុទ្ធសាស្ត្រសម្រាប់អនុវត្តបន្តឆ្នាំ២០១៩-២០២៣។ អាទិភាពគោលនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥។ល។ ត្រូវបានយកមកធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣។ ក្នុងការរៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ក្រសួងក៏បានធ្វើការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិលដែលពាក់ព័ន្ធទាំងអស់ ដើម្បីកៀរគរធនធានទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុផងដែរ។

ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ គឺជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តរយៈពេល៥ឆ្នាំទៅមុខ ដោយបង្ហាញនូវគោលដៅជាអាទិភាពសំខាន់ៗ និងសូចនាករដែលត្រូវសម្រេចបាន។ គោលដៅអាទិភាពសំខាន់ៗទាំងនោះរួមមាន៖

ក) បន្តពង្រីកសមិទ្ធផលនានាដែលក្រសួងបានសម្រេចជោគជ័យកន្លងមក ក្នុងការអនុវត្តកម្មវិធីទាំង៥ របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ លើខ្សែច្រវាក់ផលិតកម្ម និងពិពិធកម្មដំណាំ សត្វ និងវារីវប្បកម្ម ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល ព្រៃឈើ និងសត្វព្រៃ។ល។ ដែលបានចូលរួមក្នុងការបង្កើតការងារ លើកកម្ពស់កម្រិតជីវភាពរស់នៅដល់ប្រជាកសិករ និងអ្នកទទួលផលផ្សេងៗ ព្រមទាំងពង្រឹងគុណភាពនៃការផ្តល់សេវាបច្ចេកទេសដល់អ្នកពាក់ព័ន្ធក្នុងវិស័យកសិកម្ម។

ខ) បង្កើនធនធាន និងពង្រីកបច្ចេកទេសថ្មីៗ ដោយបញ្ចូលកម្មវិធីឌីជីថល ដើម្បីបង្កើនជីវភាព និងកំណើនសេដ្ឋកិច្ចដល់ប្រជាកសិករ និងអ្នកពាក់ព័ន្ធផ្សេងៗ។ ទន្ទឹមនឹងនោះ ត្រូវចាប់យកឱកាស និងកាលានុវត្តភាព ដោយលើកកម្ពស់ការប្រកួតប្រជែងដើម្បីសម្រេចបានក្នុងឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។

### ៣.១.១. ចក្ខុវិស័យ

ចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មគឺ៖ *"កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា"*។ ចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មនេះគឺមានអត្ថន័យដូចខាងក្រោម៖

**ប្រកួតប្រជែង** ៖ កសិកម្មកម្ពុជាត្រូវតែអាចប្រកួតប្រជែងបានតាមរយៈ (ទី១) ការកាត់បន្ថយថ្លៃដើមផលិតកម្មឱ្យបានទាបជាអតិបរិមា ដោយត្រូវយកចិត្តទុកដាក់ខ្ពស់ដល់ការបង្កើនផលិតភាព ការជំរុញការអនុវត្តបច្ចេកវិទ្យាទំនើបសមស្រប ប្រើប្រាស់ពូជមានទិន្នផលខ្ពស់ បច្ចេកទេសដែលប្រើប្រាស់ធាតុចូលតិច មានតម្លៃទាប (ដូចជាឧបករណ៍ព្រោះស្រូវជាដើម) ការប្រើប្រាស់គ្រឿងយន្តកសិកម្ម (ម៉ាស៊ីនដាំ ស្ទូង ច្រូតកាត់បោកបែន ជំនួសការប្រើកម្លាំងពលកម្មច្រើន) (ទី២) ផលិតផលកសិកម្មត្រូវមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភខ្ពស់ស្របតាមតម្រូវការទីផ្សារ។

**បរិយាប័ន្ន៖** កសិកម្មកម្ពុជាត្រូវតែរីកលូតលាស់ដោយសមធម៌ មានការចូលរួមក្នុងខ្សែច្រវាក់តម្លៃពីគ្រប់តួអង្គ អ្នកមានធនធាន និងនវានុវត្តន៍ផលិត ត្រូវបង្កើនភាពជាដៃគូជាមួយអ្នកផលិតខ្នាតតូច សម្រាប់ដំណើរការកសិ-ធុរកិច្ចប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ភ្ជាប់ទីផ្សារកសិផលតាមយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា កាត់បន្ថយគម្លាតប្រាក់ចំណូលរបស់តួអង្គផលិត សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ផលិតករ កសិករ សហ-គមន៍កសិកម្មឱ្យកាន់តែធូរធារឡើង។ នៅក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច យន្តការភាពជាដៃគូរវាង "រដ្ឋ-ឯកជន និងអ្នកផលិត" ត្រូវបានជំរុញឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ធន់នឹងការប្រែប្រួលអាកាសធាតុ៖** កសិកម្មកម្ពុជាត្រូវទប់ទល់ជាមួយគ្រោះធម្មជាតិក្នុងកម្រិតមួយដែលអាចធ្វើបានតាមវិធានការពីរជាសំខាន់គឺ៖ (១) ការបន្សាំ ឬភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ផ្តោតលើការផលិតពូជដំណាំ និងដាំដំណាំដែលធន់នឹងកម្តៅ ឬទឹកជំនន់ (២) ការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដោយបង្កើនសកម្មភាពនានាពាក់ព័ន្ធដល់ការបង្កើតប្រព័ន្ធដាំដុះ ការចិញ្ចឹមសត្វដែលមានលក្ខណៈទប់ទល់ជាមួយអាកាសធាតុ (ប្រព័ន្ធកសិដ្ឋានទំនើប សន្សំសំចៃទឹក គ្រប់គ្រងបានលើកម្តៅ/ទឹកភ្លៀង)។

**និរន្តរភាព៖** កសិកម្មកម្ពុជានឹងត្រូវតែអភិវឌ្ឍឱ្យស្របតាមគោលការណ៍ "***អភិវឌ្ឍន៍បៃតង***" កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គម ព្រមទាំងរក្សាបាននូវតុល្យភាពរវាង "***ការអភិរក្ស***" និង "***អភិវឌ្ឍន៍***"។

### ៣.១.២. បេសកកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបេសកកម្ម "***ផ្តល់សេវាគាំទ្រមានគុណភាពខ្ពស់ មានលក្ខណៈវិទ្យាសាស្ត្របច្ចេកទេសទំនើប បទដ្ឋានគតិយុត្ត និងគោលនយោបាយច្បាស់លាស់សម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព***"។

## ៣.២. គោលបំណង និងគោលដៅយុទ្ធសាស្ត្រ

### ៣.២.១. គោលបំណងយុទ្ធសាស្ត្រ

ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនេះ ក្រសួងកំណត់គោលបំណងយុទ្ធសាស្ត្ររួមសម្រាប់អនុវត្តគឺ "***ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហា-រូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព***"។

វិស័យកសិកម្មនៅតែដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការអភិវឌ្ឍជនបទ ជាពិសេសបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ កំណើនកសិកម្មត្រូវរីកលូតលាស់ និងត្រូវបានវាស់វែងដោយអត្រាកំណើននៃតម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម។

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ តម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម (Gross Value Added-GVA) សម្រេចបានក្នុងរង្វង់ពី៣%ទៅ៥%ក្នុងមួយឆ្នាំ។ ក្នុងរយៈពេល៥ឆ្នាំខាងមុខ ការព្យាករនៃកំណើននេះ នឹងត្រូវសម្រេចឱ្យបានក្នុងរង្វង់៤%ក្នុងមួយឆ្នាំ ពោលគឺនឹងត្រូវកើនពី ២១ ៩១៣ពាន់លានរៀលនៅឆ្នាំ២០១៨ ដល់ ២៥ ៧០០ពាន់លានរៀលនៅឆ្នាំ២០២៣។

### ៣.២.២. គោលដៅយុទ្ធសាស្ត្រ

គោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន០២ត្រូវបានកំណត់គឺ៖

*(ទី១) បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម*

*(ទី២) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព*

**គោលដៅយុទ្ធសាស្ត្រទី១៖** ជំរុញផលិតកម្មកសិកម្មតាមលក្ខណៈទំនើប និងយន្តូបនីយកម្មដោយជំនួសឱ្យការថយចុះនៃកម្លាំងពលកម្មកសិកម្ម មានលក្ខណៈសន្សំសំចៃ ធ្វើឱ្យថ្លៃដើមផលិតទាប ធ្វើពិពិធកម្មដំណាំដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ផ្តល់ប្រាក់ចំណេញច្រើនសម្រាប់កសិករ សហគមន៍កសិកម្ម ដែលនឹងនាំដល់ការប្រកួតប្រជែងទីផ្សារខ្ពស់ ព្រមទាំងដំណើរការកសិ-ធុរកិច្ចមានលក្ខណៈបរិយាប័ន្ន ប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាព។

**គោលដៅយុទ្ធសាស្ត្រទី២៖** គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។ ក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ សមត្ថភាពបច្ចេកទេសក្នុងការគ្រប់គ្រងនឹងត្រូវកើនឡើងជាចាំបាច់ ដើម្បីចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច។

## ៣.៣. យុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម

ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅយុទ្ធសាស្ត្រខាងលើ យុទ្ធសាស្ត្រអាទិភាពចំនួន៥ ត្រូវបានដាក់ចេញឱ្យអនុវត្តក្នុងរយៈពេល៥ឆ្នាំខាងមុខនេះគឺ៖

*(១) បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិ-ធុរកិច្ច*
*(២) លើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម*
*(៣) ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព*
*(៤) ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព*
*(៥) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស*

ដើម្បីអនុវត្តយុទ្ធសាស្ត្រទាំង៥ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំណត់អភិក្រមចំនួន ១០ដូចខាងក្រោម៖

ទី១-បន្តលើកកម្ពស់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើប ក្នុងទិសដៅបង្កើនបរិមាណ គុណភាព អាហារូបត្ថម្ភ និងពិពិធកម្មផលិតផលកសិកម្មប្រកបដោយនិរន្តរភាពធន់នឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុង និងក្រៅប្រទេស។ យកចិត្តទុកដាក់អភិវឌ្ឍន៍ធនធានមនុស្ស និងជាពិសេសបង្កើនចំនួនអ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រកសិកម្មឱ្យបានច្រើន ដោយផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រជាចាំបាច់។ ត្រូវធ្វើកសិកម្មចម្រុះប្រកបដោយភាពវៃឆ្លាត មិនត្រូវធ្វើតែដំណាំស្រូវមួយមុខ ឬការធ្វើតាមគ្នា ដោយមិនបានវិភាគឱ្យបានស៊ីជម្រៅនោះឡើយ។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់ជំរុញការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មីៗ ប្រកបដោយនវានុវត្តន៍ មានជាអាទិ៍ ការអនុវត្តកសិកម្មល្អ ការកែលម្អការគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយចីរភាព ការកែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹក ការប្រើប្រាស់យន្តូបនីយ-កម្មកសិកម្ម និងបច្ចេកវិទ្យាក្រោយប្រមូលផល ការបង្កើនភាពធន់នឹងអាកាសធាតុ និងគ្រោះធម្មជាតិ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ឱ្យបានទៅដល់សហគមន៍កសិកម្ម ព្រមទាំងពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យពូជដំណាំកសិកម្ម និងធាតុចូលកសិកម្មរួមទាំងការកែលម្អពូជសត្វ ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ជាតិ កសិដ្ឋានផលិតពូជ ស្ថានីយ និងមជ្ឈមណ្ឌលស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មឱ្យបានល្អប្រសើរ។ ត្រូវជំរុញការរៀបចំកសាងលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ពាក់ព័ន្ធនឹងវិស័យកសិកម្ម ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមអនុ-វិស័យនីមួយៗ។

ទី២- ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងសហគមន៍អ្នកចិញ្ចឹមសត្វដែលបានចុះបញ្ជីរួចហើយ ឱ្យមានលក្ខណៈជាពាណិជ្ជកម្ម ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់ប្រព័ន្ធស្រោចដោយសន្សំសំចៃទឹកនៅ

តាមសហគមន៍កសិកម្ម និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម តាមអភិក្រមភាពជាដៃគូរវាង "រដ្ឋ- ឯកជន និងផលិតករ/សហគមន៍" ឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការរកទីផ្សារបន្ថែមសម្រាប់ផលិតផលកសិកម្មជាអាទិភាព។ លើសពីនេះទៀត ត្រូវពិនិត្យមើលលទ្ធភាពធ្វើយ៉ាងណាឱ្យសហគមន៍អាចទទួលបានផលប្រយោជន៍ និងមានចំណូលសម្រាប់ដំណើរការអភិវឌ្ឍន៍របស់ខ្លួនប្រកបដោយភាពម្ចាស់ការ។ ទន្ទឹមនឹងនេះ ត្រូវបន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា និងស្វែងរកដៃគូថ្មីៗទៀត ដើម្បីអនុវត្តគម្រោងបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីជំនាញ និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍ ព្រមទាំងជំរុញ និងរួមគ្នាធ្វើការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានឱ្យយល់ដឹងជាសាធារណៈ អំពីការអភិវឌ្ឍវិស័យកសិកម្ម។

ទី៣- ពង្រឹងនិងពង្រីកសហគមន៍កសិករកៅស៊ូគ្រួសារ ដើម្បីបង្កើនកាលានុវត្តភាពក្នុងការការពារផលប្រយោជន៍របស់កសិករ ទាំងការដាំដុះ ការយកផល ការកែច្នៃ ព្រមទាំងអំណាចនៃការចរចាថ្លៃនៅពេលលក់ផលិតផលទាំងនោះ។ ជំរុញការវិនិយោគលើការកែច្នៃផលិតផលកៅស៊ូ ដើម្បីបង្កើនតម្លៃបន្ថែម បង្កើតការងារ ចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទ។ ជាមួយគ្នានេះ ត្រូវពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។

ទី៤- ជំរុញការធ្វើពិពិធកម្មកសិកម្មទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងមានសក្តានុពលលើដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម ផលិតផលឈើដាំ និងការវិនិយោគលើការកែច្នៃកសិផលសំខាន់ៗ ដោយត្រូវបន្តលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ការកែច្នៃវេចខ្ចប់ និងពង្រឹងសមត្ថភាពពិសោធន៍ ស្តង់ដារគុណភាព ក៏ដូចជាពង្រឹងវិធានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ (SPS) តាមរយៈការចរចាជាមួយបណ្តាប្រទេសដែលទិញផលិតផលកសិកម្មពីកម្ពុជា ការរៀបចំពិធីសារស្តីពីការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។

ទី៥- ជំរុញការចិញ្ចឹមសត្វរបស់កសិករឱ្យទៅជាការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ជាពិសេសការចិញ្ចឹមគោពូជកូនកាត់ ដើម្បីបង្កើនប្រាក់ចំណូល ព្រមទាំងលើកទឹកចិត្តដល់ការចិញ្ចឹមសត្វខ្នាតតូច មធ្យម និងខ្នាតធំដែលមានផលិតភាពខ្ពស់ ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងបង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់ការនាំចេញ។ គ្រប់គ្រងការធ្វើអាជីវកម្មសត្វរស់ ផលិតផលសត្វ ចំណីសត្វ បសុឱសថ និងធាតុចូលផ្សេងៗ ដោយមិនឱ្យមានការធ្វើអាជីវកម្មផ្តាច់មុខដែលប៉ះពាល់ដល់តម្លៃ និងបញ្ហាទីផ្សារ។ ត្រូវជំរុញការកែច្នៃផលិតផលសាច់ ដោយត្រូវគ្រប់គ្រងសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងកន្លែងកែច្នៃឱ្យអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល និងមានការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ធានាបាននូវគុណភាព អនាម័យ និងសុវត្ថិភាពសាច់សម្រាប់ធានាតម្រូវការក្នុងស្រុក និងឆ្ពោះទៅរកការនាំចេញទៅបរទេស។ ជាមួយគ្នានេះ ត្រូវពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ដើម្បីបង្ការការពារជំងឺឆ្លងរាលដាលសត្វ ផលិតផលសត្វប្រកបដោយសុវត្ថិភាព និងគ្រប់គ្រងហានីភ័យជំងឺរាតត្បាតនានាជាយថាហេតុ។ ព្រមជាមួយនោះ ត្រូវពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងត្រូវរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទី៦- បង្កើតស្ថានីយ៍ចត្តាឡីស័ក ដំណាំ សត្វ និងជលផល នៅតាមតំបន់សំខាន់ៗ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលសមាសធាតុចង្រៃ ជំងឺសត្វ និងជំងឺស៊ូណូស ជំងឺត្រី និងទប់ស្កាត់ការនាំចូល នាំចេញ ឆ្លងកាត់នូវផលិតផលកសិកម្មខូចគុណភាព ដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងខូចទីផ្សារក្នុងស្រុក និងនាំចេញ។ ជំរុញឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេសរដ្ឋបាលខេត្តនៅជាប់ព្រំដែន ត្រូវសហការឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ព្រមទាំងក្តាប់ឱ្យបាននូវព័ត៌មាន និងទិន្នន័យនៃការនាំចូល

និងនាំចេញផលិតផលកសិកម្មពីបណ្តាប្រទេសជិតខាង ដើម្បីធានានូវការគ្រប់គ្រងផលស្តុកក្នុងស្រុក និងផលប៉ះពាល់ទីផ្សារក្នុងតំបន់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ទី៧- ពង្រឹងសមត្ថភាពរបស់សហគមន៍នេសាទឱ្យបានរឹងមាំ ក្លាយជាសហគមន៍នេសាទគ្មានបទល្មើសជលផល ទាំងទឹកសាបនិងសមុទ្រ។ ជាមួយគ្នានេះ ត្រូវជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងត្រូវបន្តពង្រឹងការគ្រប់គ្រង និងការពារកន្លែងអភិរក្សជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសត្រូវថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាងឱ្យបានគង់វង្ស ដែលជាជម្រកដ៏សំខាន់របស់មច្ឆជាតិ។ លើសពីនេះទៀត បន្តចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល និងត្រូវខិតខំរៀបចំលិខិតបទដ្ឋានគតិយុត្ត ជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងការនេសាទល្មើសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយ-ការណ៍ (IUU Fishing) ដោយត្រូវបង្កើតយន្តការថ្នាក់ជាតិឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ជាមួយអន្តរស្ថាប័នស្របតាមនីតិវិធីជាធរមាន។

ទី៨- រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រៃផ្តល់ផល ដើម្បីឆ្លើយតបទៅនឹងបរិបទកែទម្រង់បច្ចុប្បន្ន សំដៅធានាបានស្ថិរភាពរឹងមាំលើការអភិវឌ្ឍអនុវិស័យព្រៃឈើជាតិយូរអង្វែង។ បន្ថែមលើនេះ ត្រូវបន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើ ដោយជួយប្រជាសហគមន៍ជនបទឱ្យបង្កើនចំណូល លើកកម្ពស់ជីវភាពរស់នៅតាមរយៈការដាក់បញ្ចូលប្រព័ន្ធកសិ-រុក្ខកម្ម។ ក្នុងគោលដៅពង្រីកគម្របព្រៃឈើ ត្រូវបន្តជំរុញការស្តារដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និងដីព្រៃដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយ សម្រាប់ចែកចាយជូនប្រជាពលរដ្ឋដាំដុះ។ ជាមួយគ្នានេះ ត្រូវរៀបចំបង្កើតសួនរុក្ខសាស្ត្រ (Botanical Garden) នៅតាមតំបន់អេកូឡូស៊ីរុក្ខជាតិកម្ពុជា ក្នុងគោលបំណងអប់រំបណ្តុះបណ្តាល និងផ្សព្វផ្សាយនូវប្រភេទរុក្ខជាតិមានដោយកម្រ និងជិតផុតពូជ ព្រមទាំងដាក់តាំងបង្ហាញនូវសំណាកប្រភេទរុក្ខជាតិសំខាន់ៗ ប្រភេទគ្រួសារ និងអំបូរដទៃទៀត ដោយប្រើប្រាស់ប្រភពថវិកាមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និងពីប្រភពផ្សេងៗទៀត។

ទី៩- បន្តចុះស្រាវជ្រាវ រុករក និងបង្ក្រាបបទល្មើសព្រៃឈើ ជលផល ការកាប់រាន ដុត ឈូសឆាយដីព្រៃឈើ និងព្រៃលិចទឹកយកដីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាព ដោយប្រើប្រាស់កម្លាំងចម្រុះ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងតុលាការ ព្រមទាំងបន្តយកចិត្តទុកដាក់ជំរុញការបោះបង្គោលព្រំព្រៃឈើ និងព្រៃលិចទឹកឱ្យបានឆាប់រហ័ស ដើម្បីទប់ស្កាត់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវការរំលោភបំពានលើដីព្រៃឈើ និងព្រៃលិចទឹកជាដើម។ តំបន់សម្បទានសេដ្ឋកិច្ចដែលនៅសេសសល់ពីមុនមកនឹងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹង ដើម្បីធានាថាដំណើរការអនុវត្តសម្បទានដីសេដ្ឋកិច្ចទាំងនោះ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធផល។ ព្រមជាមួយនោះ ត្រូវចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទី១០- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង និងបណ្តាប្រទេសដៃគូអភិវឌ្ឍន៍នានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអន្តរជាតិ ដើម្បីស្វែងរកជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសថ្មីៗ សម្រាប់ការធ្វើទំនើបភាវូបនីយកម្មកសិកម្ម ព្រមទាំងខិតខំបង្កើនកិច្ចសហ-ប្រតិបត្តិការ និងធ្វើការចរចាដើម្បីបើកច្រកទីផ្សារសម្រាប់ការនាំចេញផលិតផលកសិកម្ម ឱ្យបានទូលំទូលាយជាមួយប្រទេសនានាក្នុងបរិបទនៃសាកលភាវូបនីយកម្ម។ លើកទឹកចិត្តដល់អ្នកវិនិយោគទុនទាំងក្នុង និងក្រៅប្រទេស បង្កើនទុនវិនិយោគក្នុងវិស័យកសិកម្មលើគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម ពិសេសការកែច្នៃផលិតផលកសិកម្ម ដើម្បីផ្សារភ្ជាប់កសិករ ឬសហគមន៍កសិកម្ម ទៅនឹងទីផ្សារតាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និង

អ្នកផលិត។ ទន្ទឹមនឹងនេះ ត្រូវជំរុញដល់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិទាំងអស់ឱ្យបន្តគាំទ្រការលើកកម្ពស់ និងជំរុញការអភិវឌ្ឍវិស័យកសិកម្មតាមគ្រប់រូបភាព ដើម្បីធានាឱ្យមានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងនៅក្នុងកម្រិតគ្រួសារ សហគមន៍ និងថ្នាក់ជាតិ។ ជាមួយគ្នានេះ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងអនុវិស័យនៃវិស័យកសិកម្មនឹងត្រូវជំរុញរៀបចំ និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដើម្បីអនុវត្តយុទ្ធសាស្ត្រទាំង៥ និងអភិក្រមខាងលើឱ្យទទួលបានលទ្ធផលល្អប្រសើរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំណត់កម្មវិធីអាទិភាពចំនួន៥ សម្រាប់ប្រតិបត្តិ និងគ្រប់គ្រងដោយអង្គភាពថវិការបស់ក្រសួង រួមមាន៖

### ៣.៣.១. កម្មវិធីទី១÷ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តជំរុញការបង្កើនផលិតភាព គុណភាព និងពិពិធកម្ម តាមរយៈការបង្កើនការវិនិយោគប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តសិទ្ធិលើការស្រាវជ្រាវ និងការអភិវឌ្ឍពូជដំណាំដែលផ្តល់តម្លៃបន្ថែមខ្ពស់ ជាមួយនឹងបច្ចេកវិទ្យាវៃឆ្លាត ឌីជីថល និងទាន់សម័យ ការផ្សព្វផ្សាយដោយផ្ទាល់ដល់កសិករនៅទីជនបទដែលខ្វះជំនាញបច្ចេកទេស ការតភ្ជាប់រវាងសហព័ន្ធ ឬសហគមន៍កសិកម្ម និងវិស័យឯកជនតាមរយៈយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា លើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពលើការប្រើប្រាស់ទឹក ព្រមជាមួយនឹងការពង្រីកផ្ទៃដីស្រោចស្រព ព្រមទាំងបន្តជំរុញ និងសម្របសម្រួលក្នុងការផ្តល់ប័ណ្ណកាន់កាប់កម្មសិទ្ធិដីដល់កសិករ ការរៀបចំយុទ្ធសាស្ត្រទ្រទ្រង់ដល់ការផ្តល់សេវាធានារ៉ាប់រងផលិតកម្មកសិកម្ម ការពង្រឹងយន្តការការអនុវត្តកសិកម្មល្អ និងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនៃផលិតផលកសិកម្ម។

បន្ថែមលើសពីនេះ ក្រសួងបន្តជំរុញនិងលើកកម្ពស់កសិ-ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម តាមរយៈការពង្រីកឱ្យមានការវិនិយោគឯកជនលើផលិតផលកសិកម្ម ដែលមានសក្តានុពលដូចជា ស្រូវ ពោត ដំឡូងមី ពពួកសណ្តែក បន្លែ ស្វាយ ស្វាយចន្ទី ចេក កៅស៊ូ សត្វ និងផលិតផលសត្វ ផលិតផលជលផលជាដើម ដោយបន្តផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ ការកាត់បន្ថយថ្លៃអគ្គិសនី អត្រាការប្រាក់ និងចំណាយឡូជីស្ទីក ពិសេសជំរុញគម្រោងសាងសង់ឃ្លាំងស្តុក និងឡសម្ងួតបន្ថែមពីគម្រោងអន្តរាគមន៍របស់រាជរដ្ឋាភិបាល តាមរយៈយន្តការនៃការវិនិយោគរួមគ្នារវាងវិស័យសាធារណៈ និងវិស័យឯកជន ឬហិរញ្ញប្បទានពីបរទេស ព្រមទាំងបង្កើនការបណ្តុះបណ្តាលធនធានមនុស្សលើផ្នែកកសិ-ឧស្សាហកម្ម។

ក្នុងរយៈពេល៥ឆ្នាំ (២០១៩-២០២៣) ខាងមុខនេះ សូចនាករចំនួន០៣នឹងត្រូវសម្រេចឱ្យបានគឺ៖

*(១) ផលិតផលកសិកម្មសរុបនឹងត្រូវជំរុញឱ្យកើនពី២៨លានតោននៅឆ្នាំ២០១៩ ដល់៣៦លានតោននៅឆ្នាំ២០២៣។*

*(២) បង្កើនអនុបាត (%) នៃពិពិធកម្មដំណាំឱ្យកើនពី៦៣%នៅឆ្នាំ២០១៩ ដល់៦៧%នៅឆ្នាំ២០២៣។*

*(៣) ផលិតផលដំណាំកសិកម្មនាំចេញនឹងកើនពី៥,៨លានតោននៅឆ្នាំ២០១៩ ដល់៧,៧លានតោននៅឆ្នាំ២០២៣។*

ដើម្បីសម្រេចនូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជំរុញវិធានការគោលនយោបាយសំខាន់ៗដូចខាងក្រោម៖

- **ជំរុញផលិតកម្ម និងផលិតភាពដំណាំដែលមានសក្តានុពលទីផ្សារខ្ពស់**
  - ជំរុញការបង្កើនផលិតភាព ពិពិធកម្មកសិកម្ម លើមុខដំណាំដែលមានផលចំណេញខ្ពស់ និងមានតម្រូវការទីផ្សារ បង្កើនគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម ដោយត្រូវអនុវត្តផលិតកម្មកសិកម្ម

សរីរាង្គ ឬការអនុវត្តកសិកម្មល្អ (Good Agriculture Practice-GAP) ប្រកបដោយភាពវៃឆ្លាត រួមនឹងការបញ្ចូលនូវបច្ចេកវិទ្យាទំនើបឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ

- បន្តការលើកកម្ពស់យន្តូបនីយកម្មកសិកម្មតាមរយៈ (១)ការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម (២)ការបង្កើតមជ្ឈមណ្ឌលថែទាំជួសជុលគ្រឿងយន្តកសិកម្ម ការអភិវឌ្ឍវិស្វកម្មកសិកម្ម ការស្រាវជ្រាវ ផលិតឧបករណ៍ដើម្បីបំពាក់ក្នុងកសិដ្ឋានគំរូ និង(៣)ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតខ្ពស់នៅក្នុងគ្រប់ដំណាក់ខ្សែផលិតកម្មកសិកម្ម ដើម្បីធានាបាននូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ កាត់បន្ថយជាអតិបរមាដល់ការហូរច្រោះខូចគុណភាពដី ការខ្ជះខ្ជាយថាមពលទឹក និងការបាត់បង់ផលដែលផលិតបាន
- បន្តជំរុញការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព តាមរយៈការទប់ស្កាត់បញ្ហាឱនភាពដី ការកំណត់តំបន់ដាំដុះ ការកែលម្អដីជាតិដី ដោយបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យផែនទីកំណត់តំបន់ដាំដុះសម្រាប់ប្រើប្រាស់ដីកសិកម្មប្រកបដោយប្រសិទ្ធភាព និងការបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងជំរុញផលិតកម្មកសិកម្ម ពិសេសដំណាំទៅតាមតំបន់មានសក្តានុពល និងទាក់ទាញវិនិយោគទុនចូលរួមផលិត ឱ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥
- ជំរុញការអភិវឌ្ឍដំណាំស្រូវ តាមរយៈការស្រាវជ្រាវ និងការបណ្តុះបណ្តាលអំពីការបង្កើនគុណភាពពូជ និងលើកកម្ពស់បច្ចេកទេសដាំដុះប្រកបដោយគុណភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពផលិតកម្មធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដោយសហការជាមួយស្ថាប័ន និងអង្គភាពជំនាញពាក់ព័ន្ធ
- បន្តការអភិវឌ្ឍ ការលើកកម្ពស់គុណភាពផលិតភាព និងបរិមាណ ព្រមទាំងស្តង់ដារូបនីយកម្មដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម តាមរយៈកិច្ចសហប្រតិបត្តិការស្រាវជ្រាវជាមួយស្ថាប័នជាតិ និងអន្តរជាតិ ការផ្តល់សេវាបច្ចេកទេសដល់កសិករ និងសហគមន៍កសិកម្ម ព្រមទាំងសម្របសម្រួលការជំរុញការផលិតស្របតាមតម្រូវការទីផ្សារ។

➢ **លើកកម្ពស់ការការពារដំណាំ គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម**

- បន្តពង្រឹងនិងជំរុញការងារផ្សព្វផ្សាយកសិកម្ម ការប្រើប្រាស់យន្តការផ្សព្វផ្សាយតាមលក្ខណៈពហុនិយមលើការផ្ទេរបច្ចេកវិទ្យា ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យា ដល់អ្នកប្រើប្រាស់បានទាន់ពេលវេលា និងសមស្របទៅតាមតម្រូវការ
- ពង្រឹងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ (SPS) តាមរយៈការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពង្រឹងសមត្ថភាពមន្ត្រីភូតគាមអនាម័យ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការត្រួតពិនិត្យ និងមានការទទួលស្គាល់ជាអន្តរជាតិ ព្រមទាំងខិតខំបង្កើតប្រព័ន្ធភូតគាមអនាម័យអេឡិចត្រូនិច (E-Phyto System) ដើម្បីជំរុញការធ្វើកសិ-ពាណិជ្ជកម្ម និងផ្តល់ភាពងាយស្រួលដល់អ្នកនាំចេញផលិតផលកសិកម្ម
- ជំរុញដំណើរការចរចាអំពីលក្ខខណ្ឌតម្រូវអនាម័យ ភូតគាមអនាម័យ សម្រាប់បើកទីផ្សារនាំចេញផលិតផលកសិកម្មដែលមានសក្តានុពលមួយចំនួន ដោយត្រូវជំរុញឱ្យម្ចាស់កសិដ្ឋាន និងរោងចក្រកែច្នៃវេចខ្ចប់ផលិតផលកសិកម្មមកចុះបញ្ជី និងត្រូវពិនិត្យ វាយតម្លៃឱ្យបានត្រឹមត្រូវ
- ពង្រឹងនិងអភិវឌ្ឍសមត្ថភាពមន្ទីរពិសោធន៍ជាតិកសិកម្ម តាមរយៈការកែសម្រួលយន្តការការងារក្នុងការវិភាគគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ព្រមទាំងត្រូវធ្វើឱ្យមានការទទួលស្គាល់សមត្ថភាពមន្ទីរពិសោធន៍ជាតិកសិកម្មនេះជាចាំបាច់។

➢ **លើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម និងអភិវឌ្ឍន៍សហគមន៍កសិកម្ម**

- ពង្រឹងនិងជំរុញការងារផ្សព្វផ្សាយកសិកម្ម ស្របតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ពិសេសការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យា សំដៅបង្កើនចំនួនអ្នកប្រើប្រាស់ កសិករ សហគមន៍កសិកម្ម ឱ្យទទួលបាននូវឯកសារបច្ចេកទេសវិទ្យាសាស្ត្រថ្មីៗ ស្របតាមការរីកចម្រើននៃវិស័យកសិកម្ម
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្ម ដោយត្រូវបង្កើនសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍អាជីវកម្មមុខរបរសហគមន៍កសិកម្ម ដើម្បីឱ្យក្លាយទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មជនបទរឹងមាំមួយ តាមរយៈការបណ្តុះបណ្តាល ការពង្រឹងសមត្ថភាព ការរៀបចំវេទិកាធុរកិច្ចសហគមន៍កសិកម្ម ការផ្តល់អនុសាសន៍លើការងារដឹកនាំនិងគ្រប់គ្រង និងការវាយតម្លៃសមត្ថភាពសហគមន៍កសិកម្ម
- ជំរុញការអភិវឌ្ឍសហគមន៍កសិកម្ម ដើម្បីធ្វើឱ្យសហគមន៍ជាកន្លែងផលិតទ្រង់ទ្រាយធំ ដោយភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលជាគន្លឹះក្នុងការដោះស្រាយទីផ្សារកសិផល
- ពង្រឹងសមត្ថភាពសហគមន៍កសិកម្មដែលបានចុះបញ្ជីរួច ឱ្យមានលក្ខណៈជាជំនាញ អាជីព ដើម្បីចូលរួមវិនិយោគជាមួយវិស័យឯកជនក្នុងគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម តាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍កសិកម្ម។

➢ **លើកកម្ពស់ការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព**

- ពង្រឹងនិងជំរុញការផ្ទេរបច្ចេកវិទ្យាតាមរយៈការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ការអនុវត្តកែច្នៃល្អ និងទីផ្សារដល់ប្រតិបត្តិករកៅស៊ូគ្រួសារ ដើម្បីបង្កើនការទទួលយកបច្ចេក-វិទ្យាជឿនលឿន សមស្រប និងបង្កើនតម្លៃបន្ថែម
- ជំរុញការអភិវឌ្ឍជាចម្ការគំរូបង្ហាញ ដែលប្រើប្រាស់បច្ចេកទេសការអនុវត្តកសិកម្មល្អប្រកបដោយភាពវៃឆ្លាត ដើម្បីបង្កើនការទទួលយករបស់កសិករកៅស៊ូគ្រួសារនូវបច្ចេកវិទ្យាសមស្រប
- ពង្រឹងនិងចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ កែប្រែឱ្យទៅជាសហគ្រិនភាពមានលក្ខណៈប្រកួតប្រជែងខ្ពស់
- ពង្រឹងសមត្ថភាពបច្ចេកទេសកែច្នៃ ដើម្បីលើកកម្ពស់គុណភាពកៅស៊ូ និងពង្រឹងយន្តការទីផ្សាររវាងអ្នកផលិត និងអ្នកកែច្នៃកៅស៊ូ តាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា
- កសាងផែនការ និងកៀរគររកប្រភពហិរញ្ញប្បទានសហប្រតិបត្តិការពីគ្រប់ដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូ
- បន្តកសាងនិងពង្រឹងការអនុវត្តលិខិតុបករណ៍គតិយុត្តនានា ពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍អនុ-វិស័យកៅស៊ូឱ្យមានប្រសិទ្ធភាព
- ពង្រឹងនិងពង្រីកការងារពិសោធ និងស្រាវជ្រាវកៅស៊ូលើគ្រប់ផ្នែក ដោយមានការចូលរួមសហការស្រាវជ្រាវលើបច្ចេកទេសកៅស៊ូជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យការអភិវឌ្ឍកៅស៊ូនៅកម្ពុជាទទួលបានជោគជ័យ ពិសេសជំរុញការស្រាវជ្រាវបច្ចេកវិទ្យាកៅស៊ូ និងក្លូនកៅស៊ូថ្មីធន់នឹងការប្រែប្រួលអាកាសធាតុសំដៅបង្កើនឧត្តមភាពប្រកួតប្រជែង
- សិក្សារិះរកវិធីសាស្ត្រស្រាវជ្រាវថ្មីៗប្រកបដោយប្រសិទ្ធភាពទាំងផ្នែកលំហូរខាងលើ និងផ្នែកលំហូរខាងក្រោម ពិសេសបំផុតការបង្កើនគុណភាពផលិតផលកៅស៊ូ និងការអនុវត្តកសិកម្មល្អ ដើម្បីបម្រើផលប្រយោជន៍ឱ្យប្រតិបត្តិករកៅស៊ូ និងអ្នកពាក់ព័ន្ធ

- ពង្រឹងយន្តការគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ការស្រាវជ្រាវកៅស៊ូ ព្រមទាំងពង្រឹងគុណភាពលើការបណ្តុះបណ្តាលធនធានអ្នកស្រាវជ្រាវ ពង្រីកការផ្សព្វផ្សាយបច្ចេកទេសកៅស៊ូជូនដល់ប្រតិបត្តិករកៅស៊ូ។

➢ **លើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម**

- ជំរុញការអនុវត្តយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ពិសេសការភ្ជាប់ក្រុមផលិតករ សហគមន៍កសិកម្មជាមួយក្រុមអ្នកប្រមូលទិញ ឬក្រុមហ៊ុនឯកជនដែលប្រមូលទិញផលិតផលកសិកម្មសម្រាប់ការកែច្នៃ និងការនាំចេញ
- ជំរុញការរៀបចំកសាង និងអនុវត្តច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ ដើម្បីគាំទ្រការអភិវឌ្ឍកសិ-ឧស្សាហកម្មឱ្យមានប្រសិទ្ធភាពខ្ពស់
- សម្របសម្រួលក្នុងការបង្កើតសួនកសិ-ឧស្សាហកម្មកែច្នៃនិងនាំចេញ ដែលគ្រប់គ្រង និងប្រតិបត្តិដោយផ្នែកឯកជន ជាមូលដ្ឋានក្នុងការស្រូបយកផលិតផលកសិកម្មទៅធ្វើការកែច្នៃជាទ្រង់ទ្រាយធំសម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញ
- រៀបចំដំណើរការមន្ទីរពិសោធន៍ និងពង្រឹងសមត្ថភាពមន្ត្រីជំនាញសម្រាប់វិភាគគុណភាព និងសុវត្ថិ-ភាពផលិតផលកសិកម្ម សហការជាមួយជំនាញពាក់ព័ន្ធតាមភារកិច្ចឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីជួយសម្រួលដល់ការអនុវត្តប្រព័ន្ធតាមដាន និងត្រួតពិនិត្យគុណភាពឱ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំនិងអនុវត្តបទដ្ឋានគតិយុត្ត សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីទប់ស្កាត់លើការប្រើប្រាស់សារធាតុគីមីដែលហាមឃាត់ ដោយត្រូវត្រួតពិនិត្យឱ្យបានតឹងរ៉ឹងបំផុត ដើម្បីធានាសុខុមាលភាពសាធារណៈ
- បង្កើនការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលអំពីបច្ចេកទេសកែច្នៃកសិផល សម្រាប់ជំរុញការអភិវឌ្ឍផ្នែកកសិ-ឧស្សាហកម្មឱ្យមានសន្ទុះខ្លាំងក្លា។

➢ **ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព**

- ជំរុញគំនិតច្នៃប្រឌិតថ្មីៗសម្រាប់បង្កើនសន្ទុះទំនើបភាវូបនីយកម្មកសិកម្ម ឱ្យកាន់តែមានឧត្តមភាពប្រកួតប្រជែងខ្ពស់ ដោយយកចិត្តទុកដាក់លើការស្រាវជ្រាវ អភិវឌ្ឍន៍ ផ្សព្វផ្សាយ និងប្រើប្រាស់របកគំហើញថ្មីៗ ដូចជាបច្ចេកទេសផលិត កែច្នៃ បច្ចេកវិទ្យាកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ធាតុចូលកសិកម្មសមស្រប គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មច្នៃប្រឌិតថ្មីប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់
- បង្កើនការវិនិយោគលើការពង្រឹងសមត្ថភាពស្រាវជ្រាវកសិកម្មសម្រាប់ដំណាំអាទិភាព និងការអនុវត្តកម្មវិធីស្រាវជ្រាវសម្រាប់អភិវឌ្ឍន៍ តាមរយៈភាពជាដៃគូរវាងរាជរដ្ឋាភិបាល វិស័យឯកជន និងអ្នកផលិត
- រៀបចំកសាងនិងអនុវត្ត "គោលនយោបាយស្រាវជ្រាវកសិកម្ម"។

➢ **ការកសាង និងអនុវត្តគម្រោងពាក់ព័ន្ធគោលនយោបាយអន្តរវិស័យ**

- រៀបចំកសាង អនុវត្ត តាមដាននិងវាយតម្លៃគម្រោង ផែនការសកម្មភាព ដែលមានចែងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិផ្សេងទៀតទាក់ទងដល់ផ្នែកជំនាញ
- បន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ និងច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ និងរៀបចំកសាងបទដ្ឋានក្រោមច្បាប់ដើម្បីអនុវត្តបន្ត
- រៀបចំកសាងគម្រោង ឬផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី

ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម គោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ជាដើម។ល។

### ៣.៣.២. កម្មវិធីទី២÷ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ

អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការសម្រេចបាននូវគោលបំណងគោលនយោបាយដែលបានដាក់ចេញ។ អនុវិស័យនេះ មានយុទ្ធសាស្ត្រអាទិភាពសំខាន់ៗទាក់ទងទៅនឹងការបង្កើនផលិតកម្មសត្វ លើកកម្ពស់សុខភាពសត្វ ការពង្រីកទីផ្សារ សុវត្ថិភាពចំណីអាហារ សុខភាពសាធារណៈ សន្តិសុខស្បៀង និងតួនាទីរបស់វិស័យឯកជន ក្រុមកសិករ/សហគមន៍កសិកម្ម ភ្នាក់ងារសុខភាពសត្វភូមិ និងបញ្ហាអន្តរវិស័យមួយចំនួនដែលពាក់ព័ន្ធដល់ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ។

ក្នុងរយៈពេល៥ឆ្នាំ (២០១៩-២០២៣) ខាងមុខនេះ អនុវិស័យនេះនឹងត្រូវសម្រេចឱ្យបាននូវសូចនាករគន្លឹះចំនួន០៣គឺៈ

*(១) បង្កើនផលិតផលសាច់ឱ្យកើនពី២៤០ពាន់តោននៅឆ្នាំ២០១៩ ដល់២៧០ពាន់តោននៅឆ្នាំ ២០២៣*

*(២) បង្កើនអត្រា (%) នៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យកើនពី២៣%នៅឆ្នាំ២០១៩ ដល់ ៣០%នៅឆ្នាំ២០២៣*

*(៣) កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម៥%។*

ដើម្បីសម្រេចនូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជំរុញការអនុវត្តវិធានការគោលនយោបាយសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- **ពង្រឹងផលិតកម្មសត្វ រួមទាំងលើកកម្ពស់ការគ្រប់គ្រង និងការបង្កាត់ពូជសត្វ**
  - ជំរុញឱ្យការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មមានការកើនឡើង ទាំងក្នុងស្រទាប់ប្រជាកសិករ សហគមន៍ និងអ្នកចិញ្ចឹមសត្វផ្សេងទៀត
  - លើកកម្ពស់ការគ្រប់គ្រងធនធានសេនេទិកសត្វ តាមរយៈវិធានអភិរក្សពូជសត្វក្នុងស្រុក និងពូជសត្វថ្មី ពង្រីកចំណេះដឹងអំពីការបង្កាត់ពូជសត្វ និងអភិវឌ្ឍន៍ពូជសត្វថ្មីៗដែលផ្តល់នូវផលិតភាពខ្ពស់
  - អនុវត្តនិងផ្សព្វផ្សាយពីការអនុវត្តល្អលើការចិញ្ចឹមសត្វ (GAHP) ដល់អ្នកពាក់ព័ន្ធទាំងអស់ដែលចូលរួមនៅក្នុងផលិតកម្មសត្វ
  - តាមដាននិងត្រួតពិនិត្យគុណភាពចំណីសត្វ ដើម្បីធានាប្រសិទ្ធភាពនៃការចិញ្ចឹមសត្វ
  - កំណត់អត្តសញ្ញាណចុះបញ្ជី និងគ្រប់គ្រងទិន្នន័យសត្វ និងកសិដ្ឋានចិញ្ចឹមសត្វឱ្យបានល្អប្រសើរ
  - ជំរុញការប្រើប្រាស់បច្ចេកវិទ្យាថ្មីនៅក្នុងផលិតកម្មសត្វ និងការបង្កាត់ពូជសត្វតាមរយៈការបង្កើតកសិដ្ឋានបង្ហាញ និងការបណ្តុះបណ្តាលបច្ចេកទេសជំនាញ
  - ជំរុញឱ្យប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការដាំដុះដំណាំចំណីសត្វ
  - ជំរុញឱ្យមានការគ្រប់គ្រងកាកសំណល់សត្វនៅតាមកសិដ្ឋាន សត្តឃាតដ្ឋាន និងរោងចក្រកែច្នៃសំខាន់ៗ ស្របតាមគោលនយោបាយឡជីវឧស្ម័ន។
- **ពង្រឹងសុខភាពសត្វ សុខភាពសាធារណៈបសុព្យាបាល និងសុខុមាលភាពសត្វ**
  - ពង្រឹងការតាមដានជំងឺ ការចុះស្រាវជ្រាវនៅមូលដ្ឋាន ការធ្វើរោគវិនិច្ឆ័យក្នុងមន្ទីរពិសោធន៍ ការបង្ការ និងទប់ស្កាត់ជំងឺសត្វ និងជំងឺឆ្លងពីសត្វទៅមនុស្ស
  - ប្រព័ន្ធព័ត៌មានសុខភាពសត្វត្រូវដំណើរការប្រកបដោយប្រសិទ្ធភាព

- ផ្តល់ការគាំទ្រ ទាំងផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុ ដល់ភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) ដើម្បីចូលរួមក្នុងសកម្មភាពបង្កើនផលិតភាពសត្វនៅតាមមូលដ្ឋាន
- គ្រប់គ្រងសត្វ និងផលិតផលដើមកំណើតពីសត្វ រួមទាំងការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពនៅតាមស្ថានីយចត្តាឡីស័ក និងកន្លែងប្រមូលផ្តុំសត្វ ទប់ស្កាត់ការធ្វើចរាចរសត្វ និងផលិតផលសត្វខុសច្បាប់ ពិនិត្យគុណភាពសាច់នៅតាមសត្តឃាតដ្ឋាន ធានានូវសុវត្ថិភាពសាច់ជូនដល់អ្នកបរិភោគ
- លើកកម្ពស់ការអនុវត្តជីវសុវត្ថិភាពនៅក្នុងខ្សែច្រវាក់ផលិតកម្មសត្វឱ្យបានហ្មត់ចត់។

➢ **លើកកម្ពស់ការផ្សព្វផ្សាយច្បាប់ ពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយនានា**
- រៀបចំកសាងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងពង្រឹងការអនុវត្ត និងបង្កើនការយល់ដឹងអំពីច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងលិខិតបទដ្ឋានគតិ-យុត្តនានា ដើម្បីពង្រឹងការគ្រប់គ្រងផ្នែកសុខភាពសត្វ និងផលិតកម្មសត្វឱ្យមានប្រសិទ្ធភាពខ្ពស់
- រៀបចំនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតដល់កសិដ្ឋាន សត្តឃាតដ្ឋាន កន្លែងកែច្នៃ មន្ទីរពិសោធន៍ ស្ថាប័នសិក្សាស្រាវជ្រាវបសុឱសថ និងវ៉ាក់សាំងសត្វ សេវាបសុព្យាបាល និងកន្លែងលក់ផលិតផលចំណីសត្វ
- រៀបចំនីតិវិធីក្នុងការផ្តល់វិញ្ញាបនបត្រដល់អ្នកផ្តល់សេវាបសុពេទ្យ និងផ្តល់ការគាំទ្រដល់ការបង្កើតគណៈបសុពេទ្យ (Veterinary Statutory Body - VSB)។

➢ **ជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ**
- ពង្រឹងការអនុវត្ត និងគ្រប់គ្រងការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- ពង្រឹងសមត្ថភាពស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍អភិរក្សសេនេទិចពូជសត្វ កែច្នៃទឹកមេជីវិតបង្កកគោ ការបង្កាត់ពូជសត្វដោយសិប្បនិម្មិត
- ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការធ្វើរោគវិនិច្ឆ័យជំងឺសត្វ និងការអង្កេតតាមដានជំងឺសត្វ
- សិក្សាស្រាវជ្រាវគុណភាព និងសុវត្ថិភាពបសុឱសថ ចំណីសត្វ សាច់សត្វ និងផលិតផលសត្វ
- សិក្សាស្រាវជ្រាវភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ និងដាក់ចេញនូវវិធានការការពារ
- សិក្សាស្រាវជ្រាវ និងផលិតផលបសុឱសថនិងវ៉ាក់សាំង។

➢ **បង្កើនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ**
- ពង្រឹងសមត្ថភាពធនធានមនុស្សផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ និងការគ្រប់គ្រងក្នុងខ្សែច្រវាក់ផលិតកម្មសត្វ រួមទាំងពាណិជ្ជកម្មសត្វ
- គាំទ្រដល់ការពង្រឹងការអប់រំក្នុងប្រព័ន្ធវេជ្ជសាស្ត្របសុព្យាបាល និងវិទ្យាសាស្ត្រសត្វ
- ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់មន្ត្រីសុខភាពសត្វនិងផលិតកម្មសត្វ មន្ត្រីនៃការិយាល័យផលិតកម្មនិងបសុព្យាបាលខេត្ត និងពេទ្យសត្វស្រុក ដើម្បីបង្កើនផលិតកម្មសត្វ និងគ្រប់គ្រងជំងឺសត្វនៅថ្នាក់មូលដ្ឋាន។

➢ **លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនក្នុងផលិតកម្មសត្វ**
- គាំទ្រដល់គំនិតផ្តួចផ្តើម និងជំរុញការវិនិយោគរបស់វិស័យឯកជន នៅក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- សម្របសម្រួលការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការជាមួយនឹងវិស័យឯកជន អង្គការសង្គមស៊ីវិល និងសហគមន៍ចិញ្ចឹមសត្វ ដើម្បីលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ
- ពង្រីកការចែករំលែកព័ត៌មាន និងការសហការរវាងស្ថាប័នរដ្ឋាភិបាល និងវិស័យឯកជន ក្នុងអនុវិស័យផលិតកម្មសត្វ និងសុខភាពសត្វ។

- ➢ **ពង្រឹងសេវាផ្សព្វផ្សាយស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងអភិវឌ្ឍន៍ទីផ្សារ**
  - រៀបចំនិងបង្កើនការយល់ដឹងតាមរយៈឯកសារព័ត៌មាន អប់រំ និងប្រាស្រ័យទាក់ទង
  - បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្សព្វផ្សាយថ្នាក់តំបន់ ដើម្បីជំរុញផលិតកម្មសត្វ និងលើកកម្ពស់សុខភាពសត្វ
  - គាំទ្រព្រឹត្តិការណ៍រៀបចំឡើងដោយវិស័យសាធារណៈ និងវិស័យឯកជន ដែលផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយពាក់ព័ន្ធជាមួយនឹងសុខភាពសត្វ និងផលិតកម្មសត្វ។
- ➢ **ពង្រឹងកិច្ចសហប្រតិបត្តិការទាំងផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសកម្រិតជាតិ និងអន្តរជាតិលើអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ**
  - រៀបចំនិងចូលរួមនៅក្នុងសន្និសីទអំពីសុខភាពសត្វ និងផលិតកម្មសត្វនៅថ្នាក់ជាតិ អាស៊ាន និងថ្នាក់អន្តរជាតិ
  - បង្កើនកិច្ចសហប្រតិបត្តិការភាពជាដៃគូខាងសេដ្ឋកិច្ច និងបច្ចេកទេសនៅថ្នាក់ជាតិ អាស៊ាន និងអន្តរ-ជាតិ និងពង្រឹងទំនាក់ទំនងជាមួយនឹងដៃគូអភិវឌ្ឍន៍ អង្គការស្ថាប័នទ្វេភាគី និងពហុភាគី ជុំវិញបញ្ហានានាដែលពាក់ព័ន្ធជាមួយនឹងសុខភាពសត្វ និងផលិតកម្មសត្វ
  - រៀបចំកសាង និងអនុវត្តគម្រោងផែនការសកម្មភាពទាំងអស់ ដែលមានគ្រោងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មជាតិផ្សេងទៀតទាក់ទងដល់ផ្នែកជំនាញ ពិសេសគម្រោង ឬផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ជាដើម។ល។

### ៣.៣.៣. កម្មវិធីទី៣៖ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តការយកចិត្តទុកដាក់ទៅលើកំណែទម្រង់អនុវិស័យជលផលក្នុងគោលដៅបំពេញតម្រូវការសុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ បង្កើនប្រាក់ចំណូលប្រជាពលរដ្ឋ និងថែរក្សាធនធានមច្ឆជាតិឱ្យបានគង់វង្ស តាមរយៈការជំរុញការស្រាវជ្រាវវិទ្យាសាស្ត្រជលផល ការគ្រប់គ្រងសហគមន៍នេសាទ ការអភិរក្សជលផល ការការពារព្រៃលិចទឹក ការប្រយុទ្ធនឹងការនេសាទខុសច្បាប់ ជំរុញការអភិវឌ្ឍវារី-វប្បកម្ម និងការអភិវឌ្ឍការកែច្នៃ និងគុណភាពផល ផលិតផលជលផល។

ក្នុងរយៈពេល០៥ឆ្នាំខាងមុខ ក្រសួងនឹងបង្កើនការគ្រប់គ្រងធនធានជលផលឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ដោយពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល រក្សាផលនេសាទចាប់ពីធម្មជាតិក្នុងរង្វង់៦០០ពាន់តោនក្នុងមួយឆ្នាំ បង្កើនផលវារីវប្បកម្ម២០%ក្នុងមួយឆ្នាំ និងធ្វើឱ្យសហគមន៍នេសាទមានកម្រិតជីវភាពកាន់តែប្រសើរឡើង។

ឆ្លើយតបទៅនឹងគោលដៅនេះ វិធានការគោលនយោបាយសម្រាប់ការអនុវត្តការកែទម្រង់អនុវិស័យជលផលរួមមាន៖

(១) ពង្រឹងការសិក្សាស្រាវជ្រាវ ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយចីរភាពស្របតាមការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤ និងសេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយវិស័យជលផលជាតិ ពិសេសតាមរយៈការពង្រឹងការអនុវត្តច្បាប់ និងការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទគ្រប់ប្រភេទ ជាអាទិ៍៖ ការពង្រឹងការគ្រប់គ្រងឧបករណ៍នេសាទ ការលុបបំបាត់ការនេសាទហួសកម្រិត ការពង្រឹងសមត្ថភាពសហគមន៍នេសាទ ក្នុងការគ្រប់គ្រង ប្រើប្រាស់ និងអភិរក្សធនធានជល

ផល ការអភិរក្ស ការការពារជីវចម្រុះនិងជម្រកវារីសត្វ ការថែទាំនិងជំរុញការដាំព្រៃលិចទឹក និងព្រៃកោងកាង ការកំណត់ព្រំប្រទល់ព្រៃលិចទឹក និងកន្លែងអភិរក្សជលផល ព្រមទាំងការកសាងសមត្ថភាពអង្គភាព ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ។

(២) ការបង្កើនការអភិវឌ្ឍវារីវប្បកម្ម ដោយផ្តល់ការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី ដូចជាបច្ចេកទេស បង្កាត់ពូជត្រីមានគុណភាព ឥណទាន ទីផ្សារ ការសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយវារីវប្បកម្ម ស្របតាមផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០៣០។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តពង្រឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយចីរភាព ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផល ផលិផលជលផល និងបង្កើនផលវារីវប្បកម្មពី ២៩៨ពាន់តោននាឆ្នាំ២០១៩ ឱ្យកើនដល់៦១៩ពាន់តោននៅឆ្នាំ២០២៣ ដោយបង្កើនការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី ក្នុងន័យបង្កើនការគាំទ្រដល់ការការពារធនធានជលផល។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់យុទ្ធសាស្ត្រសំខាន់សម្រាប់ការអនុវត្តកម្មវិធីទី៣នេះ រួមមាន៖

- **ពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានជលផល**
  - ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ៖ បន្តពង្រឹងសហគមន៍នេសាទឱ្យក្លាយជាសហគមន៍មានភាពម្ចាស់ការ ដំណើរការល្អ រឹងមាំ និងសកម្មក្នុងការគ្រប់គ្រង និងអភិរក្សធនធានជលផលឱ្យមាននិរន្តរភាព ជាពិសេសជំរុញ និងគាំទ្រផ្តល់ឱកាសឱ្យសហគមន៍នេសាទអាចរកប្រាក់ចំណូលសម្រាប់ដំណើរការសហគមន៍ និងអភិរក្សធនធានជលផលប្រកបដោយប្រសិទ្ធភាព ដោយសហការជាមួយរដ្ឋ-បាលពាក់ព័ន្ធថ្នាក់ក្រោមជាតិ ដើម្បីប្រែក្លាយជា "សហគមន៍នេសាទគ្មានបទល្មើសជលផល"
  - ការគ្រប់គ្រងដែននេសាទ៖ បង្កើនកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ ចុះទប់ស្កាត់ការទន្ទ្រានឈូសឆាយបំផ្លិចបំផ្លាញយកដីព្រៃលិចទឹក និងព្រៃកោងកាងនៅតាមមូលដ្ឋាន ជាពិសេសយកចិត្តទុកដាក់ និងទប់ស្កាត់រាល់ឧបករណ៍នេសាទដែលបំផ្លិចបំផ្លាញធ្ងន់ធ្ងរដល់ធនធានធម្មជាតិ និងកែលម្អដែននេសាទ។ រៀបចំផែនទីកំណត់ព្រំប្រទល់ដែននេសាទ តំបន់ដែលអនុញ្ញាតឱ្យដាំដុះវារីរុក្ខជាតិ តំបន់នេសាទ និងការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ និងការប្រើប្រាស់ទូក កាណូតនាវានេសាទ ព្រមទាំងតាមដាន និងវាយតម្លៃសភាពការណ៍អាជីវកម្មនេសាទ ព្រមទាំងទប់ស្កាត់នូវរាល់សកម្មភាពបទល្មើសជលផល គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។
- **ការពារ និងអភិរក្សធនធានជលផល៖**
  - ត្រូវបន្តគ្រប់គ្រងកន្លែងអភិរក្សធនធានជលផលទាំងអស់ ទាំងក្នុងដែននេសាទសាធារណៈ និងក្នុងកន្លែងនេសាទសហគមន៍នេសាទឱ្យខាងតែបាន ព្រោះដែនអភិរក្សទាំងនេះជាជម្រកត្រីមេពូជដ៏សំខាន់សម្រាប់ថែរក្សាត្រីមេពូជឱ្យបានគង់វង្ស និងធានានិរន្តរភាពផលនេសាទ ដែលមានសារសំខាន់ដល់និរន្តរភាពនៃធនធានជលផល។
- **អភិវឌ្ឍន៍វារីវប្បកម្មទឹកសាប និងសមុទ្រ**
  - ជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន២០%/ឆ្នាំ៖ ដើម្បីបំពេញកំណើនតម្រូវការសាច់ត្រីជាអាហារ និងកាត់បន្ថយការនេសាទហួសកម្រិតនោះ ការអភិវឌ្ឍវារីវប្បកម្មត្រូវតែជំរុញឱ្យបានខ្លាំងក្លា ទាំងខ្នាតតូច មធ្យម និងធំ ដោយធានាឱ្យបានទាំងកំណើនបរិមាណ និងទាំងគុណភាព សុវត្ថិភាពចំណីអាហារ ដោយត្រូវជំរុញការអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០៣០។ ពិសេសវិធានការពង្រឹងសមត្ថភាពក្នុងការផលិតនូវកូនត្រីពូជក្នុងស្រុក សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីឆ្លើយតបនឹងតាមតម្រូវការរបស់អ្នកចិញ្ចឹម ជាពិសេសប្រភេទត្រីដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ព្រមទាំងបន្តផ្តល់

នូវបច្ចេកទេសថ្មីៗ និងបច្ចេកទេសសម្រាប់ជំរុញការបង្កាត់ពូជត្រី និងទីកន្លែងបង្កាត់ភ្ញាស់ពូជត្រី និងអនុវត្តគោលការណ៍អនុវត្តវារីវប្បកម្មល្អ

- ជំរុញលើកទឹកចិត្តដល់វិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស ឱ្យវិនិយោគលើការអភិវឌ្ឍវារីវប្បកម្ម ពិសេសការចិញ្ចឹមត្រីនិងបង្កង រួមទាំងការកែច្នៃផលិតផលជលផលប្រកបដោយគុណភាព និងសុវត្ថិភាព
- កំណត់ឱ្យបានជាក់លាក់ពីតំបន់ដែលមានសក្តានុពល សម្រាប់វិនិយោគវារីវប្បកម្មពីសំណាក់អ្នកវិនិ-យោគក្នុង និងក្រៅប្រទេស ជាពិសេសចំពោះការចិញ្ចឹមត្រីឆ្ពោនិងត្រីរ៉ស់ ត្រូវផ្តល់បច្ចេកទេសបង្កាត់ពូជត្រី និងផ្តល់នូវបច្ចេកទេសគ្រប់គ្រង និងតាមដានឱ្យមានប្រសិទ្ធភាព ដើម្បីចៀសវាងការប្រើចំណីដែលបានមកពីការប្រើឧបករណ៍នេសាទខុសច្បាប់ដូចជាស្បៃមុងចាប់កូនត្រីធ្វើជាចំណីជាដើម
- បង្កើតសមាគមន៍វារីវប្បកម្ម និងជំរុញឱ្យមានការធ្វើផលិតកម្មតាមកិច្ចសន្យា ជាមួយអ្នកប្រមូលទិញ ឬក្រុមហ៊ុនប្រមូលទិញសម្រាប់នាំចេញ
- បន្តជំរុញការងារស្រាវជ្រាវ ការអប់រំ និងអភិវឌ្ឍន៍បច្ចេកទេសវារីវប្បកម្ម និងបង្កើនការផ្សព្វផ្សាយបច្ចេកទេសបង្កាត់កូនត្រីពូជ និងចិញ្ចឹមដល់កសិករ ប្រជានេសាទ និងសហគមន៍នេសាទ។

➢ **ការគ្រប់គ្រង និងអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃជលផល**

- អភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងលើកកម្ពស់អាហារូបត្ថម្ភ រៀបចំនិងអនុវត្តសាកល្បងគោលការណ៍ណែនាំបច្ចេកទេសកែច្នៃតាមស្តង់ដារ និងជំរុញការអនុវត្តបច្ចេកទេសកែច្នៃជលផលប្រសើរឡើង ដើម្បីបង្កើនតម្លៃបន្ថែម
- ពង្រឹងការត្រួតពិនិត្យ និងវិភាគគុណភាពផល ផលិតផលជលផល ដើម្បីការពារសុខភាពសាធារណៈ និងជំរុញការនាំចេញ
- លើកកម្ពស់ការផលិតនូវផលិតផលកែច្នៃជលផលឆ្លើយតបតាមស្តង់ដារគុណភាព និងជំរុញទីផ្សារក្នុងស្រុកនិងអន្តរជាតិ ជាពិសេសតាមរយៈការពង្រឹងសមត្ថភាពប្រព័ន្ធគ្រប់គ្រងគុណភាព និងសុវត្ថិភាព ដោយផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលការណ៍ណែនាំបច្ចេកទេសផ្សេងៗដែលពាក់ព័ន្ធ។

➢ **ការស្រាវជ្រាវ និងអភិវឌ្ឍន៍ធនធានជលផល**

- ស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេស សម្រាប់ការរក្សានូវធនធានជលផលទឹកសាបនិងសមុទ្រ
- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវធនធានជលផលទឹកសាប និងសមុទ្រដល់អ្នកពាក់ព័ន្ធនានា
- ជំរុញនិងពង្រឹងកិច្ចសហការសិក្សាស្រាវជ្រាវធនធានជលផលទឹកសាប និងសមុទ្រជាមួយវិទ្យាស្ថានស្រាវជាវ សាកលវិទ្យាល័យនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធដទៃទៀត
- ពង្រឹងសមត្ថភាពមន្ត្រីស្រាវជ្រាវដែលធ្វើការងារស្រាវជ្រាវវិទ្យាស្ត្រជលផលទឹកសាប និងសមុទ្រ។

➢ **ពង្រឹងសមត្ថភាពមន្ត្រីជលផល ការអនុវត្តច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យជលផល**

- អនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យជលផល ព្រមទាំងបន្តពិនិត្យកែសម្រួលច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងវិស័យជលផលឱ្យទាន់សភាពការណ៍ជាក់ស្តែង
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ដើម្បីបង្ក្រាបបទល្មើសជលផលនៅក្នុងមូលដ្ឋាន ជាពិសេសយកចិត្តទុកដាក់ទប់ស្កាត់រាល់ឧបករណ៍នេសាទដែលបំផ្លិចបំផ្លាញធ្ងន់ធ្ងរដល់ធនធានធម្មជាតិ និងទប់ស្កាត់នូវរាល់សកម្មភាពបទល្មើសជលផល ការទន្ទ្រានយកដីព្រៃលិចទឹក ព្រៃកោងកាង និងដីដែលស្ថិតនៅក្នុងកន្លែងនេសាទសហគមន៍
- អនុវត្តផែនការសកម្មភាពជាតិស្តីពីការប្រយុទ្ធប្រឆាំង និងទប់ស្កាត់បទល្មើសនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (NPOA IUU) Fishing-National Plan of Action Illegal Fishing

Unreported and Unregulated) និងផែនការជាតិត្រួតពិនិត្យ និងអធិការកិច្ចសមុទ្រ (NPCI-National Plan for Control and Inspection) ព្រមទាំងផែនការជាតិសម្រាប់ការគ្រប់គ្រង និងអធិការកិច្ចឱ្យស្រប ទៅតាមច្បាប់ជាតិ និងសន្ធិសញ្ញាអន្តរជាតិ

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិនានា ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍនិងគ្រប់គ្រងវិស័យជលផលនៅកម្ពុជាឱ្យបានខ្លាំងក្លាថែមទៀត សំដៅធានានិរន្តរភាពធនធានជលផល កាត់បន្ថយភាពក្រីក្រ ធានាសន្តិសុខ និងសុវត្ថិភាពស្បៀង ព្រមទាំងចូលរួមសម្រេចឱ្យបាន "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០"
- រៀបចំកសាង និងអនុវត្តផែនការសកម្មភាពដែលមានគ្រោងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្ម-ភាពជាតិផ្សេងទៀតទាក់ទងនឹងជលផល ពិសេសគម្រោង ឬផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យជលផល និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។ល។
- អភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងបទដ្ឋានគតិយុត្តដល់មន្ត្រីជលផលនិងអ្នកពាក់ព័ន្ធ។

### ៣.៣.៤. កម្មវិធីទី៤÷ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

ព្រៃឈើជាប្រភពធនធានធម្មជាតិដ៏មានតម្លៃ ចូលរួមលើកកម្ពស់លើផ្នែកសេដ្ឋកិច្ច បរិស្ថាន ទេសចរណ៍ ការសិក្សាស្រាវជ្រាវប្រព័ន្ធការពារទីជម្រាល ប្រព័ន្ធការពារជីវចម្រុះ និងផ្តល់ជម្រកសម្រាប់ស្ថិរភាពនៃជីវិតរស់នៅរបស់មនុស្ស និងសត្វគ្រប់ប្រភេទ។ ការខិតខំប្រឹងប្រែងដើម្បីរួបរួមគ្នាទប់ស្កាត់គ្រោះមហន្តរាយនៃការបាត់បង់ធនធានព្រៃឈើគឺជាកត្តាចាំបាច់បំផុត ពិសេសការពង្រឹងស្មារតីម្ចាស់ការទទួលខុសត្រូវលើកិច្ចការនេះ។ ការស្តារព្រៃឈើគឺជាគោលដៅសំខាន់ក្នុងការជំរុញឱ្យមានគម្របព្រៃឈើបៃតង ក៏ដូចជាផ្តល់នូវការរីកចម្រើនសេដ្ឋកិច្ចសម្រាប់ប្រទេសជាតិ និងឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ឈើក្នុងស្រុកដែលកើតមានឡើងកាន់តែខ្លាំង។

ដើម្បីឱ្យការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ ទទួលបានប្រសិទ្ធភាពខ្ពស់ ឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ ក្នុងរយៈពេល៥ឆ្នាំ (២០១៩-២០២៣) ខាងមុខ សូចនាករចំនួន០២ នឹងត្រូវសម្រេចឱ្យបានគឺ៖

*(១) បរិមាណផលឈើដាំត្រូវបានប្រមូលកើនពី២០០ពាន់ម៉ែត្រគូបនាឆ្នាំ២០១៩ ដល់២៧៥ពាន់ម៉ែត្រគូបនៅឆ្នាំ២០២៣។*

*(២) អត្រាចំណូលសហគមន៍ព្រៃឈើនឹងកើនឡើងពី១០% នៅឆ្នាំ២០១៩ ដល់១៨% នៅឆ្នាំ២០២៣ ។*

ដើម្បីសម្រេចបាននូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព ចូលរួមជំរុញការថែរក្សាគម្របព្រៃឈើឱ្យបានល្អប្រសើរ ព្រមទាំងលើកកម្ពស់ជីវភាព និងការចូលរួមរបស់សហគមន៍ព្រៃឈើ ព្រមទាំងជំរុញការស្តារព្រៃឈើឡើងវិញ និងបន្តអនុវត្តនូវវិធានការចាំបាច់នានា ដើម្បីចូលរួមចំណែកធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីមានចីរភាព។ វិធានការជាយុទ្ធសាស្ត្រដែលត្រូវអនុវត្តរួមមាន៖

➢ **ការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ**

- អភិវឌ្ឍសហគមន៍ព្រៃឈើ និងគ្រប់គ្រងផល អនុផលព្រៃឈើ ដោយត្រូវបន្តពង្រឹងសមត្ថភាព និងពង្រីកសហគមន៍ព្រៃឈើឱ្យបានល្អប្រសើរ ជាពិសេសជួយប្រជាសហគមន៍ព្រៃឈើឱ្យបង្កើនប្រាក់

ចំណូល លើកកម្ពស់កម្រិតជីវភាពរស់នៅតាមរយៈការអនុវត្តប្រព័ន្ធកសិ-រុក្ខកម្ម និងចិញ្ចឹមសត្វនៅក្នុងតំបន់ដែលគ្រប់គ្រងដោយសហគមន៍ព្រៃឈើ

– អភិវឌ្ឍចម្ការឈើដាំ និងការងាររុក្ខវប្បកម្ម ក្នុងគោលដៅពង្រីកគម្របព្រៃឈើ ដោយត្រូវបន្តជំរុញការស្តារដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និងដីព្រៃដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច ដោយសហការជាមួយផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយ សម្រាប់ចែកចាយជូនប្រជាពលរដ្ឋដាំដុះ

– គ្រប់គ្រង និងអភិវឌ្ឍឧស្សាហកម្មព្រៃឈើ ពាណិជ្ជកម្ម និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអភិវឌ្ឍវិស័យព្រៃឈើ។

➢ **ពង្រឹងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ**

– ពង្រឹងការស្រាវជ្រាវ ថែរក្សា និងអភិវឌ្ឍសត្វព្រៃ និងជីវចម្រុះ

– សិក្សាស្រាវជ្រាវការស្តារព្រៃឈើរេចរឹល ជំរុញការអនុវត្តកសិ-រុក្ខកម្មទប់ស្កាត់ការហូរច្រោះដី និងពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងតំបន់ស្តារ និងអភិវឌ្ឍន៍ព្រៃឈើ សំដៅចូលរួមចំណែកដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

– រៀបចំបង្កើតសួនរុក្ខសាស្ត្រ (Botanical Garden) នៅតាមតំបន់អេកូឡូស៊ីរុក្ខជាតិ ក្នុងគោលបំណងអប់រំបណ្តុះបណ្តាល និងផ្សព្វផ្សាយនូវប្រភេទរុក្ខជាតិមានដោយកម្រ និងជិតផុតពូជ ព្រមទាំងដាក់តាំងបង្ហាញនូវសំណាកប្រភេទរុក្ខជាតិសំខាន់ៗ ប្រភេទ គ្រួសារ និងអំបូរដទៃទៀត។

➢ **ការគ្រប់គ្រងឧទ្យានសួនសត្វ និងសង្គ្រោះថែរក្សាសត្វព្រៃ**

– សង្គ្រោះ ថែរក្សាសត្វព្រៃ និងអប់រំផ្សព្វផ្សាយ ដើម្បីចូលរួមចំណែកទប់ស្កាត់ការផុតពូជធនធានសត្វព្រៃ និងជីវចម្រុះ

– ត្រួតពិនិត្យឱ្យបានហ្មត់ចត់លើទីតាំងថែរក្សាសត្វព្រៃ និងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ព្រមទាំងត្រូវជំរុញឱ្យចុះបញ្ជិកាត្រឹមត្រូវ

– សិក្សានិងចងក្រងឯកសារសត្វព្រៃ និងជីវចម្រុះ ព្រមទាំងសម្របសម្រួលបង្កើតសេវាកម្មទេសចរណ៍ដើម្បីបង្កើនប្រាក់ចំណូលដល់សហគមន៍ព្រៃឈើមូលដ្ឋាន។

➢ **ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ**

– ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសត្រូវបន្តចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើឱ្យបានខ្លាំងក្លា ដោយសហការជាមួយគណៈកម្មាធិការជាតិទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ និងគណៈបញ្ជាការឯកភាពរាជធានី ខេត្ត

– ចុះត្រួតពិនិត្យតំបន់ដីសម្បទានសេដ្ឋកិច្ច ដើម្បីធានាថាដំណើរការសម្បទានដីសេដ្ឋកិច្ចទាំងនោះប្រព្រឹត្តទៅប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់

– សហការចុះស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយអំពីការប្រមូលឈើក្រៅតំបន់ដីសម្បទានសេដ្ឋកិច្ចមកធ្វើការកែច្នៃក្រោមរូបភាពនៃការអនុវត្តសម្បទានដីសេដ្ឋកិច្ច

– បន្តត្រួតពិនិត្យ តាមដានឱ្យបានច្បាស់លាស់ និងពង្រឹងការគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់លើរាល់សកម្មភាពរបស់ឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទ ដែលគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ទៅក្រៅប្រទេសតាមច្រកព្រំដែន និងច្រករបៀង ដើម្បីលុបបំបាត់សកម្ម-ភាពដឹកជញ្ជូនខុសច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមនីតិវិធីនៃច្បាប់ស្តីពីព្រៃឈើ

– បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទបញ្ជា និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើឱ្យជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត រាជធានីទូទាំងប្រទេស

- ពង្រឹងការគ្រប់គ្រងចំណូលពីវិស័យព្រៃឈើ។

➢ **ពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រអង្គភាព**

- សម្របសម្រួលរៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីព្រៃឈើជាតិ និងរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រៃផ្តល់ផល ដើម្បីឆ្លើយតបទៅនឹងបរិបទកែទម្រង់បច្ចុប្បន្ន សំដៅធានាបានស្ថិរភាពរឹងមាំលើការអភិវឌ្ឍវិស័យព្រៃឈើយូរអង្វែង
- រៀបចំកសាង និងអនុវត្តគម្រោងផែនការសកម្មភាពទាំងអស់ ដែលមានគ្រោងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មផ្សេងទៀតដែលទាក់ទងដល់ផ្នែកជំនាញព្រៃឈើ ពិសេសគម្រោង ឬផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី និងការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យព្រៃឈើ។

## ៣.៣.៥. កម្មវិធីទី៥៖ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងការពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព គឺជាគ្រឹះដ៏រឹងមាំដើម្បីឈានទៅសម្រេចបាននូវគោលដៅគោលនយោបាយដែលបានដាក់ចេញ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ផ្តោតការអនុវត្តដោយផ្អែកលើអភិក្រមចំនួន៣ជាសំខាន់គឺ៖

**១. ការពង្រឹងស្ថាប័ន៖** បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងអង្គភាពក្រោមឱវាទក្រសួង ពិនិត្យកែសម្រួលរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងរបស់ក្រសួងឱ្យសមស្របទៅនឹងបរិបទរីកចម្រើននៃវិស័យកសិកម្ម បែងចែកមន្ត្រីរាជ-ការឱ្យស្របតាមជំនាញបច្ចេកទេស ពង្រឹងវិន័យការងារឱ្យបានហ្មត់ចត់ដោយផ្អែកលើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

**២. ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ៖** បង្កើនសមត្ថភាពកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រ ពង្រឹងប្រព័ន្ធព័ត៌មាននិងទីផ្សារកសិកម្ម ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនិងឯកជន ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ ការបង្កើនប្រសិទ្ធភាពការរៀបចំ គ្រប់គ្រង និងការអនុវត្តថវិកា ការធ្វើអធិការកិច្ច សវនកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសេវាគាំទ្រពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។

**៣. ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម៖** បង្កើនចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញកសិ-កម្មពាក់ព័ន្ធនានា ស្រាវជ្រាវបន្ថែមនូវបច្ចេកវិទ្យានិងរបកគំហើញថ្មីៗ សំដៅពង្រឹង និងពង្រីកធនធានមនុស្សក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

ក្នុងទិសដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តឱ្យបានជោគជ័យនូវសកម្មភាពគន្លឹះជាយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

➢ ពិនិត្យនិងរៀបចំកែសម្រួលរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួង រៀបចំបង្កើត និងដាក់ឱ្យដំណើរការនូវបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ប្រសិទ្ធភាពខ្ពស់ក្នុងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម និងសម្របសម្រួលរៀបចំកសាង “គោលនយោបាយស្រាវជ្រាវកសិកម្ម - Agricultural Research Policy”

➢ ពង្រឹងការគ្រប់គ្រងអង្គភាពឱ្យបានរឹងមាំ បង្កើនការផ្តល់សេវាគាំទ្រនានា និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាព ដោយត្រូវបង្កើនសមត្ថភាពក្នុងការអនុវត្តផែនការ ថវិកា

កម្មវិធី ពង្រឹងប្រព័ន្ធព័ត៌មានវិទ្យាក្នុងការកសាងផែនការ ការគ្រប់គ្រងថវិកា ការតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធី ឆ្លើយតបទៅនឹងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីកៀរគរធនធាន ទាំងបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា សម្រាប់ការអនុវត្តសកម្មភាពអាទិភាព ឆ្លើយតបទៅនឹងសភាពការណ៍រីកចម្រើននៃវិស័យកសិកម្ម
- ជំរុញនិងសម្របសម្រួលការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នានាដែលគាំទ្រវិស័យកសិកម្ម ពង្រឹងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវថ្នាំកសិកម្ម និងជីកសិកម្ម ព្រមទាំងលើកកម្ពស់សមត្ថភាពយល់ដឹងសាធារណៈក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មប្រកបដោយសុវត្ថិភាព
- លើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ការវិនិយោគឯកជន ដើម្បីចូលរួមក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្ម បង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (ICT) ដើម្បីទទួលបានព័ត៌មានកាន់តែងាយស្រួល ទាំងការយល់ដឹងពីបច្ចេកទេសក្នុងការផលិត ព័ត៌មានទីផ្សារ ខ្សែច្រវាក់តម្លៃ និងព័ត៌មានកសិកម្មផ្សេងៗទៀត
- ពង្រឹងនិងពង្រីកធនធានមនុស្សក្នុងវិស័យកសិកម្ម បង្កើនចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងជំនាញពាក់ព័ន្ធនានា ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារ បង្កើនសមត្ថភាពក្នុងការអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្តល់បច្ចេកទេសកសិកម្មទំនើបដល់និស្សិតដើម្បីពង្រីកកសិ-ធុរកិច្ច និងការបង្កើតថ្មីនូវសហ-គ្រាសកសិកម្មប្រកបដោយភាពប្រកួតប្រជែង និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ព្រមទាំងបន្តរៀបចំរចនា-សម្ព័ន្ធសម្រាប់គាំទ្រការងារកសិកម្មនៅថ្នាក់រាជធានី ខេត្ត ស្រុក ខណ្ឌ សំដៅសម្រេចបាននូវការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពខ្ពស់
- ពង្រឹងការងារសវនកម្មផ្ទៃក្នុងដើម្បីជួយឱ្យសវនដ្ឋានធ្វើការគ្រប់គ្រងហានិភ័យ ការងារអធិការកិច្ច ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អលើការងារគ្រប់គ្រង និងប្រតិបត្តិក្នុងវិស័យកសិកម្ម
- លើកកម្ពស់ប្រសិទ្ធភាពនៃការចូលរួមក្នុងការបញ្ជ្រាបយេនឌ័រ ការទប់ស្កាត់ និងលុបបំបាត់នូវរាល់សកម្ម-ភាពជួញដូរមនុស្ស និងបទល្មើសផ្សេងៗទៀតក្នុងវិស័យកសិកម្ម ដែលបង្កជាផលប៉ះពាល់ដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យកសិកម្ម
- លើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មកម្ពុជា ពិសេសបង្កើនប្រសិទ្ធភាពក្របខ័ណ្ឌការងារផ្សព្វផ្សាយ ក្របខ័ណ្ឌគតិយុត្ត យន្តការការងារ ការកៀរគរធនធានសម្រាប់គាំទ្រសេវាផ្សព្វផ្សាយ បង្កើនការផ្សព្វផ្សាយតាមបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ អភិវឌ្ឍន៍ធនធានមនុស្ស និងសម្ភារផ្សព្វផ្សាយកសិកម្ម។

## ៣.៤. ក្របខ័ណ្ឌអាទិភាពអន្តរវិស័យ

### ៣.៤.១. ក្របខ័ណ្ឌយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ មានគោលដៅសំខាន់គឺចូលរួមចំណែកជួយកាត់បន្ថយផលប៉ះពាល់ និងឥទ្ធិពលអវិជ្ជមានទាំងឡាយលើដំណាំកសិកម្ម ផលិតកម្មសត្វ ព្រៃឈើ និងជលផល ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ សំដៅស្តារនូវការខូចខាត និងការបាត់បង់ផលប្រយោជន៍នានា តាមរយៈការបង្កើនវិធានការបន្សាំ និងវិធានការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ គោលដៅអាទិភាពចំនួន៥ត្រូវបានកំណត់គឺៈ

ទី១. បង្កើនសមត្ថភាពស្ថាប័ន និងធនធានមនុស្សលើការការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗនៃពូជដំណាំ កៅស៊ូ សត្វ ព្រៃឈើ និងជលផល ដែលមានលទ្ធភាពបន្សាំទៅនឹងភាពរាំងស្ងួត ទឹកជំនន់ ការកើនកម្ដៅ ការជ្រាបចូលនៃទឹកប្រៃ និងការបំផ្លាញពីជំងឺ និងសត្វល្អិតចង្រៃ ដែលបណ្តាលមកអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។

ទី២. បង្កើនសមត្ថភាពដល់កសិករងាយរងគ្រោះ លើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ក្នុងផលិតកម្មដំណាំ និងសត្វ ដែលអាចបន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ ដោយជំរុញឱ្យបានខ្លាំងក្លានូវសេវាកម្មផ្សព្វផ្សាយប្រកប

ដោយប្រសិទ្ធភាព និងការផ្ទេរបច្ចេកវិទ្យាទាំងឡាយដែលបានអភិវឌ្ឍទៅក្នុងលក្ខខណ្ឌផលិតកម្មជាក់ស្តែង ដើម្បីធានាសុវត្ថិភាពស្បៀង និងបង្កើនប្រសិទ្ធភាពអន្តរាគមន៍ជួយសង្គ្រោះ និងស្តារការខូចខាតដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ទី៣. កាត់បន្ថយនូវការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ ពីផលិតកម្មដំណាំ ផលិត-កម្មសត្វ និងការកែច្នៃបឋមនៃផលិតផលកសិកម្មពុំសមស្រប ដោយជំរុញលើកទឹកចិត្តឱ្យមានការអភិរក្ស ការគ្រប់គ្រង និងការអភិវឌ្ឍធនធនព្រៃឈើប្រកបដោយចីរភាព ជាពិសេសសហគមន៍ព្រៃឈើ ព្រមទាំងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ (ជីវម៉ាស់ និងជីវឧស្ម័ន) និងការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មសមស្រប។

ទី៤. ជំរុញការអភិវឌ្ឍ និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យជលផល ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់ លើការកែលម្អប្រព័ន្ធអេកូឡូស៊ីទឹក ទប់ស្កាត់ការបំផ្លាញព្រៃលិចទឹក និងព្រៃកោងកាង បង្កើនការស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផល និងវារីវប្បកម្មគ្រប់ប្រភេទ ព្រមទាំងពង្រឹងសមត្ថភាពគ្រប់គ្រងសហគមន៍នេសាទឱ្យកាន់តែមានប្រសិទ្ធភាព។

ទី៥. ជំរុញការអភិវឌ្ឍធនធានមនុស្ស សម្រាប់ជាមូលដ្ឋានគន្លឹះនៃការចូលរួមចំណែកបន្សាំ និងកាត់បន្ថយផលប៉ះពាល់ ដែលបង្កដោយការប្រែប្រួលអាកាសធាតុលើផលិតកម្មដំណាំ សត្វ ព្រៃឈើ និងជលផល តាមរយៈការអប់រំបណ្តុះបណ្តាល ការផ្លាស់ប្តូរនិងចែករំលែកព័ត៌មាន និងការផ្សព្វផ្សាយចំណេះដឹង និងចំណេះធ្វើដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីសម្រេចបាននូវគោលដៅនេះ វិធានការគោលនយោបាយជាយុទ្ធសាស្ត្រមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តមានដូចខាងក្រោម៖

- ជំរុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មដំណាំសមស្របតាមប្រព័ន្ធគេ្យត្របរិស្ថាន និងពង្រឹងសមត្ថភាពបន្សាំ ដើម្បីបង្កើនការងារ និងកសិ-ពាណិជ្ជកម្មក្នុងវិស័យកសិកម្ម សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់កសិករ និងសហគមន៍ជនបទ ក្នុងដំណើរការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ
- ពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងរបកគំហើញ ដើម្បីអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ និងការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ សម្រាប់ពង្រឹងសមត្ថភាពបន្សាំ និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យកសិកម្ម សម្រាប់គ្រប់ប្រព័ន្ធគេ្យត្របរិស្ថាន
- ជំរុញការអភិវឌ្ឍដោយបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចក្នុងវិស័យកសិកម្ម តាមរយៈការគ្រប់គ្រងធនធានធម្ម-ជាតិសម្រាប់កសិកម្មដំណាំ និងស្បៀងអាហារប្រកបដោយនិរន្តរភាព និងការអនុវត្តកសិកម្មមានភាពឈ្លាសវៃជាមួយអាកាសធាតុ ដូចជាប្រព័ន្ធកសិកម្មចម្រុះ កសិ-រុក្ខកម្មកសិកម្មតាមបែបអភិរក្ស ព្រមទាំងការគ្រប់គ្រង និងប្រើប្រាស់សំណល់កសិកម្ម និងកសិ-ឧស្សាហកម្មគ្រប់ប្រភេទ សម្រាប់ការកែលម្អដីជាតិដីសំដៅរួមចំណែកដល់ការកសាងសង្គមដែលបញ្ចេញកាបូនតិច និងមានភាពធន់ទ្រាំនឹងអាកាសធាតុ
- ពង្រឹងសមត្ថភាពស្ថាប័នជំនាញក្នុងការសម្របសម្រួល ការធ្វើអន្តរាគមន៍គ្រោះមហន្តរាយដោយធម្មជាតិ ការអភិវឌ្ឍធនធានមនុស្ស ការកសាងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ និងការបញ្ជ្រាបការសិក្សាអប់រំលើចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុសម្រាប់គ្រប់កម្រិតសិក្សា ព្រមទាំងលើកកម្ពស់ការបំពាក់បំប៉ន និងផ្សព្វផ្សាយចំណេះដឹងបច្ចេកវិទ្យាដល់អ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋាន
- ពង្រឹងសមត្ថភាពសហគ្រាសវិនិយោគកសិកម្ម និងកសិ-ឧស្សាហកម្មឱ្យមានការទទួលខុសត្រូវខ្ពស់ចំពោះការកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនសមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសំដៅសម្រេចបាននូវផលប្រយោជន៍សេដ្ឋកិច្ចជាតិ ព្រមទាំងនិរន្តរភាពសង្គម និងបរិស្ថាន

– ការចិញ្ចឹមសត្វត្រូវធ្វើការផ្លាស់ប្តូរដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ រួមមាន ការធ្វើពិពិធកម្ម ការពង្រឹងឱ្យបានខ្លាំងក្លា និងសមាហរណកម្មនូវការគ្រប់គ្រងវាលស្មៅ និងផលិតកម្មសត្វនិងដំណាំ ការអភិរក្សធម្មជាតិ ប្រព័ន្ធបរិស្ថាន និងការបញ្ចូលនូវប្រព័ន្ធផលិតកម្មសត្វលាយគ្នានឹងប្រព័ន្ធកសិកម្មចម្រុះ
– ពូជសត្វក្នុងស្រុកជាច្រើនបានបន្សាំទៅនឹងលក្ខខណ្ឌរស់នៅដែលពិបាក ដូច្នេះបច្ចេកវិទ្យាបង្កាត់ពូជសត្វអាចជួយបង្កើនល្បឿននៃការបន្សាំរបស់សត្វ ទៅនឹងការប្រែប្រួលអាកាសធាតុ ដែលការបន្សាំនេះមិនត្រឹមតែអាចជួយឱ្យសត្វអាចធន់នឹងកំដៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យសត្វមានសមត្ថភាពអាចរស់រានលូតលាស់ និងបន្តពូជក្នុងលក្ខខណ្ឌដែលមានចំណីពុំសូវមានគុណភាពល្អ សត្វល្អិត និងជំងឺ
– បញ្ចូលនូវប្រភេទចំណីសត្វថ្មីៗដែលធន់នឹងភាពរាំងស្ងួតនិងទឹកជំនន់ និងការកែច្នៃកាកសំណល់កសិកម្មជាចំណីសត្វ អាចជួយធ្វើឱ្យប្រសើរឡើងនូវបរិមាណ និងគុណភាពចំណីសត្វសម្រាប់ផ្តល់ដល់សត្វ
– ការគ្រប់គ្រងកាកសំណល់សត្វ ត្រូវធ្វើឱ្យប្រសើរឡើងតាមរយៈយន្តការផ្សេងៗ ដូចជាការប្រើប្រាស់សម្ភារសម្រាប់ស្តុក និងគ្របកាកសំណល់សត្វឱ្យបានត្រឹមត្រូវ ដែលកិច្ចការនេះគឺមិនត្រឹមតែជួយទប់ស្កាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់ប៉ុណ្ណោះទេ តែថែមទាំងបង្កើតឱកាសសម្រាប់ប្រើប្រាស់ថាមពលកកើតឡើងវិញទៀតផងដែរ
– ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើ៖ មានកិច្ចការសំខាន់ៗមួយចំនួនដែលនឹងជួយរួមចំណែកបង្កើនប្រសិទ្ធភាព ក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព រួមមានជាអាទិ៍ ការពិនិត្យនិងកំណត់ឡើងវិញនូវព្រំប្រទល់ដែនព្រៃឈើ ការចុះបញ្ជី និងការរៀបចំផែនការគ្រប់គ្រងអភិវឌ្ឍន៍ និងអភិរក្សឱ្យស្របតាមមុខងារ និងស្ថានភាពព្រៃតាមតំបន់នីមួយៗ។ ក្នុងន័យនេះ តំបន់មានសក្តានុពលមួយចំនួនរួមទាំងតំបន់សហគមន៍ព្រៃឈើនឹងត្រូវបានរៀបចំអនុវត្តគម្រោង REDD+ ដែលជាកិច្ចការបន្ថែមទៅលើតំបន់មួយចំនួនដែលរដ្ឋបាលព្រៃឈើបាននិងកំពុងអនុវត្ត។ ចំណូលពីការលក់កាបូន គឺជាកម្លាំងចលករដ៏សំខាន់មួយក្នុងការជំរុញឱ្យភាគីពាក់ព័ន្ធនានាក្នុងវិស័យព្រៃឈើ ពិសេសប្រជាសហគមន៍ និងអាជ្ញាធរមូលដ្ឋានចូលរួមកាន់តែខ្លាំងក្លាថែមទៀត ក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព
– ជំរុញការងារអាទិភាពមួយចំនួនក្នុងការអភិរក្ស និងគ្រប់គ្រងព្រៃឈើ ក្នុងបរិបទនៃការការប្រែប្រួលអាកាសធាតុនេះ រួមមាន៖ ការជំរុញឱ្យមានផែនការប្រើប្រាស់ដីក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ការបង្កើនការយល់ដឹងអំពីភ្លើងឆេះព្រៃ និងការការពារ ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ព្រមទាំងការពារ និងអភិរក្សជីវចម្រុះ។ ការស្តារការដាំដុះដើមឈើ និងព្រៃឈើឡើងវិញ ជាពិសេស ផ្តោតទៅលើការស្តារគម្របព្រៃឈើតំបន់ព្រៃរេចរឹល ក៏ជាការងារចាំបាច់ផងដែរក្នុងការឆ្លើយតបនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ តាមរយៈការលើកទឹកចិត្តដល់ការដាំចម្ការឈើឯកជន សហគមន៍ និងជាលក្ខណៈចម្ការព្រៃឈើដៃគូ ដោយដាំប្រភេទឈើចម្រុះឬឈើឧស្សាហកម្ម ក្នុងគោលបំណងសម្រាប់បង្កើនជីវភាព និងបង្កើនសេវាកម្មបរិស្ថាន។ ទន្ទឹមគ្នានោះដែរត្រូវយកចិត្តទុកដាក់ផ្តោតលើការរៀបចំគោលនយោបាយ បទប្បញ្ញត្តិ ច្បាប់ និងឯកសារបច្ចេកទេសនានាសម្រាប់គាំទ្រការងារដាំឈើ និងស្តារព្រៃឈើប្រកបដោយប្រសិទ្ធភាពជាចាំបាច់
– ពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងការភ្ញាស់បង្កាត់ពូជ ការចិញ្ចឹម ចំណី និងវិធីសាស្ត្រកែច្នៃផល ផលិតផលជលផលថ្មីៗ ដែលមានលក្ខណៈបន្សាំទៅនឹងការប្រែប្រួលនៃអាកាសធាតុ និងមានការីកចម្រើនលូតលាស់ឆាប់រហ័ស ស្របទៅតាមតម្រូវការសេដ្ឋកិច្ចទីផ្សារ

- ពង្រឹងនិងពង្រីកសមត្ថភាពអង្គភាពជំនាញ និងអ្នកពាក់ព័ន្ធក្នុងការសម្របសម្រួលធ្វើអន្តរាគមន៍ ព្រមទាំងអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងវិស័យជលផល និងវិធានការបន្សាំ
- ពង្រឹងការគ្រប់គ្រង និងថែរក្សាដាំព្រៃលិចទឹក និងព្រៃកោងកាង ព្រមទាំងត្រូវដាំឡើងវិញនៅតំបន់ព្រៃរេចរឹលប្រកបដោយប្រសិទ្ធភាព។ ផ្សព្វផ្សាយឱ្យមានការយល់ដឹងជាសាធារណៈ រួមជាមួយនឹងការជំរុញឱ្យមានការបង្កើតកន្លែងអភិរក្សធនធានជលផលនៅគ្រប់សហគមន៍នេសាទទាំងអស់ ដើម្បីធានាបាននូវនិរន្តរភាពប្រព័ន្ធអេកូឡូស៊ីធនធានជលផល និងបង្កើននូវផលផលិតផលជលផលដើម្បីចូលរួមបន្សាំ ព្រមទាំងកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- ជំរុញការការពារបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី តាមរយៈការទប់ស្កាត់ការបញ្ចេញចោលកាកសំណល់ពីនាវានេសាទ ការកាប់បំផ្លាញ ការដុត ការរានយកដី ការប្រើប្រាស់ព្រៃលិចទឹក និងព្រៃកោងកាង ការបំពុលបរិស្ថានរបស់ទឹកនានា ដើម្បីរួមចំណែកទប់ស្កាត់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយសកម្មភាពជលផលដោយផ្ទាល់។

### ៣.៤.២. ក្របខំណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម

ប្រទេសកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការធានាបាននូវសមភាពយេនឌ័រ តាមរយៈគោលដៅអភិវឌ្ឍជាអាទិភាពរបស់ខ្លួន ការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ការចុះហត្ថលេខាលើសេចក្តីប្រកាសនានា ការបង្កើតផែនការជាតិដើម្បីស្ត្រី ការបង្កើតគណៈកម្មាធិការលើកកម្ពស់ស្ត្រីនៅគ្រប់ក្រសួង ការផ្តល់កូតាដល់ស្ត្រីក្នុងការចូលរួមនៅក្នុងរដ្ឋបាលផ្សេងៗ។ល។ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ផងដែរថា ការចូលរួមរបស់ស្ត្រីនៅគ្រប់វិស័យ និងគ្រប់កម្រិតជាពិសេសនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត គឺជាកត្តាដ៏សំខាន់មួយដែលមិនអាចខ្វះបាន ដើម្បីឈានទៅសម្រេចទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ទោះបីជាច្បាប់បានចែងថាស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក៏ដោយ ក៏បច្ចុប្បន្នស្ត្រីមានតិចតួចណាស់នៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេច។ ដោយឡែកក្នុងវិស័យកសិកម្មដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចរបស់ប្រទេស លទ្ធភាពរបស់ស្ត្រីក្នុងការប្រើប្រាស់ធនធានធម្មជាតិសព្វថ្ងៃនៅតែមានកម្រិតទាប នេះដោយសារតែពួកគាត់មានចំណេះដឹងទាប។ ជាក់ស្តែង ក្នុងចំណោមស្ត្រីជាកសិករ មានស្ត្រីប្រហែលពាក់កណ្តាលជាអនក្ខរជន ឬមានកម្រិតវប្បធម៌ក្រោមបឋមសិក្សា។ ម្យ៉ាងវិញទៀត ផ្នត់គំនិតសង្គមនៅតែយល់ថាការងារកសិកម្មគឺជាការងារបុរស ហើយស្ត្រីគ្រាន់តែជួយការងារនេះម្តងម្កាលប៉ុណ្ណោះ។ កត្តាទាំងនេះនាំឱ្យស្ត្រីមានឱកាសតិចតួច ក្នុងការចូលរួមក្នុងសកម្មភាពនានារបស់សហគមន៍ ការបណ្តុះបណ្តាល និងឱកាសផ្សេងទៀត ដែលជួយពង្រឹងចំណេះដឹង និងជំនាញបន្ថែមក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធាន ក៏ដូចជាឱកាសក្នុងការទទួលបាននូវសេវាកម្មសំខាន់ៗ ដូចជាសេវាផ្សព្វផ្សាយកសិកម្ម សេវាឥណទាន ព័ត៌មានទីផ្សារ និងការស្រាវជ្រាវនានា ដែលជាធនធានដ៏សំខាន់សម្រាប់កសិករជាស្ត្រីនៅក្នុងការកែលម្អផលិតកម្មកសិកម្ម និងការលើកកម្ពស់គុណភាពនៃការរស់នៅរបស់ស្ត្រី។

ឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្កើត និងអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម និងចូលរួមយ៉ាងសកម្មនៅក្នុងយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រុមការងារបច្ចេកទេសបញ្ជ្រាបយេនឌ័រតាមវិស័យ សំដៅលើកកម្ពស់សមភាពយេនឌ័រ លើកស្ទួយសិទ្ធិអំណាច ក៏ដូចជាស្ថានភាពស្ត្រីនៅគ្រប់កម្រិត។

ដើម្បីបន្តរួមចំណែកអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ក្នុងគោលបំណង (១) លើកកម្ពស់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចជូនស្ត្រី តាមរយៈការផ្តល់ជូនស្ត្រីនូវលទ្ធភាពក្នុងការទទួលបានធនធាន និងសេវាកម្ម សម្រាប់អភិវឌ្ឍផលិតកម្មកសិកម្ម និងការទទួលបានទីផ្សារ (២) ពង្រឹងសកម្មភាព ធនធាន និងការប្តេជ្ញាចិត្ត ដើម្បីធ្វើឱ្យបានប្រាកដនូវការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម និង (៣)បង្កើនភាពជាតំណាង និងការចូលរួមដោយស្មើភាពគ្នារវាងបុរស និងស្ត្រីក្នុងវិស័យកសិកម្ម។

ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រខាងលើ ក៏ដូចជាធានាឱ្យបាននូវប្រសិទ្ធភាពនៃការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់គោលដៅអាទិភាព ៥ចំណុចសម្រាប់អនុវត្តដូចខាងក្រោម៖

១. ធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។
២. បង្កើនការយល់ដឹងពីយេនឌ័រដល់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់កម្រិត។
៣. ពង្រឹងបណ្តាញស្ត្រីក្នុងវិស័យកសិកម្ម។
៤. បង្កើនឥទ្ធិពល លទ្ធភាព និងចំនួនស្ត្រីដែលមានលក្ខណសម្បត្តិទៅក្នុងតួនាទីជាអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
៥. បង្កើនលទ្ធភាពក្នុងការទទួលបាន និងគ្រប់គ្រងធនធាន និងសេវាកម្មកសិកម្ម ព្រមទាំងពង្រឹងប្រសិទ្ធភាពសេដ្ឋកិច្ចដល់ស្ត្រីជនបទ ដើម្បីរួមចំណែកលើកស្ទួយជីវភាពគ្រួសារ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៣.៤.៣. ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កិច្ចគាំពារ និងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ ក្នុងនាមជាប្រទេសហត្ថលេខីនៃអនុសញ្ញានេះ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ចំពោះផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់កុមារ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៤៨ "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច កាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខុមាលភាពរបស់កុមារ"។

ថ្វីត្បិតតែមានកិច្ចខិតខំប្រឹងប្រែងជាច្រើនពីរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធក្នុងការអនុវត្តសិទ្ធិកុមារ ក៏កុមារមួយចំនួននៅតែទទួលរងនូវការរំលោភបំពាន និងកេងប្រវ័ញ្ច។ កុមារទាំងនោះបាន និងកំពុងប្រឈមនឹងបញ្ហាជាច្រើនដូចជា កង្វះអាហារូបត្ថម្ភ មានជំងឺសើស្បែក ផ្លូវដង្ហើម សួត។ល។ បញ្ហាទាំងនេះបណ្តាលមកពី កង្វះយន្តការ និងសេវាគាំពារកុមារប្រកបដោយប្រសិទ្ធភាព សមត្ថភាពមន្ត្រីពាក់ព័ន្ធនៅមានកម្រិត ការយល់ដឹងរបស់មាតាបិតា និងអាណាព្យាបាល (ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល) លើកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារនៅមានកម្រិតទាប ឱកាសទទួលបានព័ត៌មាន និងចំណេះដឹងជុំវិញបញ្ហាកុមារពុំទាន់បានទូលំទូលាយ។ល។

ឆ្លើយតបទៅនឹងបញ្ហាខាងលើ រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយ និងផែនការសកម្មភាពជាតិ ក៏ដូចជាយន្តការនានាគាំពារកុមារនៅគ្រប់កម្រិតដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ។ល។

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច ឈានទៅសម្រេចបាននូវការកសាងធនធានមនុស្សប្រកបដោយការទទួលខុសត្រូវ និងមានការចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំបង្កើតគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធ-សាស្ត្រ ការពារ និងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម ក្នុងគោលបំណង (១) លើកកម្ពស់សន្តិសុខស្បៀង និងអាហា-រូបត្ថម្ភសម្រាប់កុមារដែលងាយរងគ្រោះ តាមរយៈការបង្កើនពិពិធកម្មនៃផលិតកម្មស្បៀង (២) បង្ការ និងទប់ស្កាត់កុមារពីពលកម្មកុមារ និងការងារដែលងាយបង្កគ្រោះថ្នាក់នៅក្នុងវិស័យកសិកម្ម (៣) បង្កើនជំនាញវិជ្ជាជីវៈ និងលើកកម្ពស់ការចូលរួមរបស់យុវជននៅក្នុងផលិតកម្មកសិកម្ម។

ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រខាងលើ ក៏ដូចជាធានាឱ្យបាននូវប្រសិទ្ធភាពនៃកិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកំណត់គោលដៅអាទិភាព៥ ចំណុចដូចខាងក្រោមៈ

- ទី១. ពង្រឹងយន្តការគាំទ្រ និងអនុវត្តការគាំពារ និងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម។
- ទី២. កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធពីកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម។
- ទី៣. លើកកម្ពស់ការយល់ដឹងពីកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារដល់មាតាបិតា អាណាព្យាបាល និងអ្នកថែរក្សាកុមារ។
- ទី៤. ពង្រឹងយន្តការតាមដាន និងវាយតម្លៃដែលមានការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់កម្រិត។
- ទី៥. កៀរគរធនធានពីគ្រប់មជ្ឈដ្ឋានសម្រាប់គាំទ្រដល់សកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម។

### ៣.៤.៤. កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី (២០១៨-២០២៧)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឋានៈជាក្រសួងបង្គោលសម្រាប់អនុវត្តអនុសញ្ញាសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម បានរៀបចំអនុវត្តកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ក្នុងគោលបំណងសំខាន់ដើម្បីរួមចំណែកទប់ស្កាត់ និងដោះស្រាយបញ្ហាធ្លាក់ចុះនៃគុណភាពដីសំដៅថែរក្សាធនធានធម្មជាតិ បង្កើនផលិតភាពដី កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងអភិវឌ្ឍប្រទេសជាតិ ព្រមទាំងចូលរួមអនុវត្តកាតព្វកិច្ចនៅក្នុងអនុសញ្ញាសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម។

អនុសញ្ញានេះបានកំណត់ថា កម្មវិធីសកម្មភាពជាតិស្ថិតនៅជាស្នូលរបស់អនុសញ្ញា និងបង្កើតបានជាក្របខ័ណ្ឌទស្សនទាន និងក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តនៅកម្រិតថ្នាក់ជាតិនិងតំបន់។ គោលបំណងនៃកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី គឺកំណត់អំពីកត្តានានា ដែលអាចឈានដល់ការកើតមានវហោស្ថានកម្ម និងវិធានការចាំបាច់ជាក់ស្តែងនានា ក្នុងការទប់ស្កាត់ ឬកាត់បន្ថយបញ្ហានេះ និងកាត់បន្ថយឥទ្ធិពលនៃគ្រោះធម្មជាតិ ដូចជា ភាពរាំងស្ងួត និងទឹកជំនន់។ អនុសញ្ញានេះបានបញ្ជាក់ថា ប្រទេសរងគ្រោះគួរបញ្ជ្រាប និងអនុវត្តកម្មវិធីសកម្មភាពជាតិ ដោយមានការចូលរួមពេញលេញរបស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានាដែលចាប់អារម្មណ៍។ ជាងនេះទៅទៀត កម្មវិធីសកម្មភាពជាតិគួរត្រូវបានបញ្ចូលគ្នាជាមួយនឹងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗ ទៀត។

កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនិងការធ្លាក់ចុះនៃគុណភាពដី មានចក្ខុវិស័យធ្វើការគ្រប់គ្រងដីដោយប្រសិទ្ធភាព និងចីរភាព សំដៅរក្សា និងបង្កើនផលិតភាពដី ឆ្លើយតបនឹងតម្រូវការក្នុងការអភិវឌ្ឍវិស័យកសិកម្ម ផលិតកម្មស្បៀង ការកែលម្អស្ថានភាពនៃជីវិតរស់នៅរបស់ប្រជាជន ព្រមទាំងក្នុងការរួមចំណែកកាត់បន្ថយ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីធ្វើឱ្យសម្រេចនូវចក្ខុវិស័យនេះ កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដីមានបេសកកម្មទប់ស្កាត់ការធ្លាក់ចុះនៃគុណភាពដី និងបង្កើនគុណភាពដី តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការពង្រឹងសមត្ថភាពស្ថាប័ន ការកៀរគរធនធាន និងកិច្ចសហការជាមួយប្រទេសក្នុងតំបន់ និងពិភពលោកក្នុងក្របខ័ណ្ឌនៃការអនុវត្តអនុសញ្ញាសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម ឬការធ្លាក់ចុះនៃគុណភាពដី(UNCCD) អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងអនុសញ្ញាសហប្រជាជាតិស្តីពីជីវចម្រុះ(UNCBD)។

កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី មានគោលបំណងរួមចំណែកលុបបំបាត់ភាពក្រីក្រ និងអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយនិរន្តរភាព តាមរយៈការគ្រប់គ្រង ប្រើប្រាស់ និងកែលម្អដី និងធនធានធម្មជាតិផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ព្រមទាំងកាត់បន្ថយ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែល្អប្រសើរឡើង។

គោលដៅយុទ្ធសាស្ត្រ ដើម្បីធ្វើឱ្យសម្រេចបាននូវគោលបំណងខាងលើ និងមានសង្គតិភាព ក៏ដូចជារួមចំណែកអនុវត្តយុទ្ធសាស្ត្រ១០ឆ្នាំ និងគោលដៅគ្មានកំណើនការធ្លាក់ចុះនៃគុណភាពដី របស់អនុសញ្ញាសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដីមានគោលដៅយុទ្ធសាស្ត្រចំនួន៥ដូចខាងក្រោម៖

១. ធ្វើឱ្យមានភាពងាយស្រួលដល់ការពង្រីកការអនុវត្តបច្ចេកទេសគ្រប់គ្រងដីធ្លី ជាពិសេសដីកសិកម្មប្រកបដោយប្រសិទ្ធភាព និងមានចីរភាពស្របទៅតាមស្ថានភាពជាក់ស្តែងរបស់ទីតាំងមូលដ្ឋាននីមួយៗ។
២. បង្កើតភាពងាយស្រួលដល់អ្នកពាក់ព័ន្ធ ក្នុងការចូលរួមស្តារទីជម្រាល និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើ។
៣. ផ្តល់ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ពាក់ព័ន្ធ សម្រាប់ធានាដល់ការគ្រប់គ្រង និងប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព និងចីរភាព។
៤. ពង្រឹងសមត្ថភាពធនធានមនុស្សក្នុងការរៀបចំផែនការ និងការអនុវត្តជាក់ស្តែងលើការគ្រប់គ្រងដី និងទីជម្រាលប្រកបដោយចីរភាព។
៥. បង្កើតនិងអនុវត្តយុទ្ធសាស្ត្រកៀរគរធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពអាទិភាពនានា។

គោលដៅយុទ្ធសាស្ត្រទាំង៥ខាងលើនេះ មានទំនាក់ទំនងគ្នាជាប្រព័ន្ធជាក់លាក់ ក្នុងការធ្វើឱ្យសម្រេចនូវគោលដៅរួម។ ក្នុងន័យនេះ ការសម្រេចបានគោលដៅយុទ្ធសាស្ត្រទី៣ ទី៤ និងទី៥ គឺជាកត្តាចាំបាច់ក្នុងការគាំទ្រដល់ការសម្រេចគោលដៅយុទ្ធសាស្ត្រទី១ និងទី២ ដែលនឹងឈានទៅធ្វើឱ្យសម្រេចបាននូវគោលបំណងកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី។

កម្មវិធីជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ត្រូវបានគ្រោងអនុវត្តនៅទីជម្រាលនៃតំបន់ទេសភាពមួយចំនួន ដែលមានបញ្ហាធ្លាក់ចុះនៃគុណភាពដី។ យុទ្ធសាស្ត្រចំនួន៥ត្រូវបានគ្រោងសម្រាប់អនុវត្តគឺ៖

ទី១. ការជំរុញអនុវត្តគ្រប់គ្រងដី និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
ទី២. ការស្តារគម្របព្រៃឈើដែលទាក់ទងនឹងទីជម្រាលដើម្បីគាំទ្រវិស័យកសិកម្ម។
ទី៣. ការគាំទ្រជាគោលនយោបាយក្នុងការបញ្ចូលការគ្រប់គ្រងដីដោយនិរន្តរភាព ក្នុងផែនការប្រើប្រាស់ដីកសិកម្ម និងកំណត់តំបន់ដាំដុះដំណាំកសិកម្ម។
ទី៤. ការអភិវឌ្ឍធនធានមនុស្សសម្រាប់គ្រប់គ្រងដីកសិកម្មដោយនិរន្តរភាព។

ទី៥.	ការគៀរគរធនធានថវិកា ដើម្បីគាំទ្រដល់សកម្មភាពអាទិភាពនានា។

ផែនការសកម្មភាពដែលត្រូវអនុវត្តសម្រាប់រយៈពេល៥ឆ្នាំខាងមុខគឺៈ

- រៀបចំផែនទី និងគោលការណ៍ណែនាំបច្ចេកទេសស្តីពីការកំណត់តំបន់ដាំដុះកសិកម្ម ផ្សព្វផ្សាយឱ្យមានការយល់ដឹងយ៉ាងទូលំទូលាយអំពីបច្ចេកទេស និងបទពិសោធន៍ល្អៗ ទាក់ទងនឹងការគ្រប់គ្រងដីដោយនិរន្តរភាព និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម
- រៀបចំនិងសម្របសម្រួលភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអ្នកធ្វើធុរកិច្ចកសិកម្ម ក្នុងការបញ្ចូលការគ្រប់គ្រងដីដោយចីរភាពទៅក្នុងការប្រតិបត្តិ ព្រមទាំងរៀបចំព័ត៌មានគោលអំពីសមត្ថភាព និងជីជាតិដី ក៏ដូចជាជម្រើសបច្ចេកវិទ្យា សមស្របសម្រាប់គ្រប់គ្រងដីដោយចីរភាព ដោយមិនចំណាយទុនខ្ពស់
- រៀបចំដំណើរការកសាងផែនការមូលដ្ឋាន ឱ្យមានការយល់ដឹងយ៉ាងទូលំទូលាយអំពីសារសំខាន់នៃការគ្រប់គ្រងទីជម្រាល អនុវត្តការដាំដុះស្តារគម្របព្រៃឈើ និងព្រៃលិចទឹកដែលចំណាយទុនតិច និងអភិក្រមកសិ-រុក្ខកម្ម រួមផ្សំនឹងការប្រើប្រាស់ពូជដំណាំមានគុណភាពខ្ពស់ អនុវត្តនៅទីជម្រាលដោយអ្នកពាក់ព័ន្ធព្រមទាំងរៀបចំ និងអនុវត្តកម្មវិធីគ្រប់គ្រងកាកសំណល់ជាគំរូ ដើម្បីគាំទ្រកិច្ចការពារប្រព័ន្ធផ្លូវទឹកនៅទីប្រជុំជន ដែលស្ថិតក្នុងតំបន់ទីជម្រាល ហើយអាចផ្គត់ផ្គង់ជីដល់កសិដ្ឋានក្បែរខាង
- រៀបចំគោលនយោបាយសម្រាប់តម្រង់ទិសការប្រើប្រាស់ដីកសិកម្ម គ្រប់គ្រងទីជម្រាល និងស្តង់ដារគុណភាព ពង្រឹងនិងអនុវត្តពិធីសារ ការវាយតម្លៃបរិស្ថាន ការកសាងផែនការ ការត្រួតពិនិត្យ និងគោលការណ៍ផ្នែកធុរកិច្ចកសិកម្ម
- ពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការក្នុងការបង្កើត និងអនុវត្តកម្មវិធីគ្រប់គ្រងដីប្រកបដោយចីរភាព រៀបចំនិងដាក់បញ្ចូលក្នុងកម្មវិធីអប់រំផ្លូវការនូវប្រធានបទសំខាន់ៗទាក់ទងនឹងការគ្រប់គ្រងដីដោយនិរន្តរភាព
- រៀបចំបង្កើតយុទ្ធសាស្ត្រ និងគម្រោងនានា ដើម្បីគៀរគរហិរញ្ញប្បទានពីប្រភពក្នុងប្រទេស ប្រភពក្រៅប្រទេស ឬហិរញ្ញប្បទានសហប្រតិបត្តិការ។

### ៣.៤.៥. ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ បានចែងយ៉ាងច្បាស់អំពីចក្ខុ-វិស័យរបស់រាជរដ្ឋាភិបាល គឺជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិ-ពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃសកលសមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រីកភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើប ដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។ ការសម្រេចបាននូវចក្ខុវិស័យនេះ នឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការទ្រទ្រង់និងលើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិ-យាប័ន្ន ការបង្កើតការងារជូនពលករកម្ពុជា ការបង្កើតតម្លៃបន្ថែមសម្រាប់សេដ្ឋកិច្ចជាតិ និងការបង្កើនប្រាក់ចំណូលសមស្របជូនប្រជាជនកម្ពុជា។

គោលបំណងនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ គឺផ្តល់នូវក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌសម្របសម្រួលការអនុវត្ត និងការរៀបចំយន្តការស្ថាប័នសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា។ កម្មវត្ថុសំខាន់នៃគោលនយោបាយនេះ គឺការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ

និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មឱ្យស្របតាមសក្តានុពល ឧត្តមភាពប្រកួតប្រជែង និងសភាពការណ៍វិវឌ្ឍនៃឧស្សាហកម្មកម្ពុជា។

ដើម្បីសម្រេចចក្ខុវិស័យ និងគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់យកគោលដៅចម្បងបីគឺៈ

ទី១. ការកែប្រែ និងពង្រីករចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ ដោយបង្កើនអនុបាតនៃវិស័យឧស្សាហកម្មក្នុង ផ.ស.ស ឱ្យបាន៣០%នៅឆ្នាំ២០២៥ ពី២៤,១%នៃផ.ស.ស នៅឆ្នាំ២០១៣។

ទី២. ការបង្កើន និងពិពិធកម្មមុខទំនិញនាំចេញ ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល (មិនមែនជាវាយនភណ្ឌ) ឱ្យបាន១៥% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥ ទន្ទឹមនឹងជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។

ទី៣. ការពង្រឹងយន្តការគ្រប់គ្រង និងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ដោយជំរុញការចុះបញ្ជីផ្លូវការនៃសហគ្រាសទាំងនោះ រួមទាំងសហគ្រាសធុនធំផងដែរ និងលើកកម្ពស់អភិបាលកិច្ច សាជីវកម្មតាមរយៈការកាន់បញ្ជិកាគណនេយ្យ និងតារាងតុល្យការ។ ជាគោលដៅនៅឆ្នាំ២០២៥ សហគ្រាសធុនតូច៨០% និងមធ្យម ៩៥% នឹងត្រូវបានចុះបញ្ជីជាផ្លូវការ ហើយសហគ្រាសធុនតូច៥០% និងមធ្យម៧០% នឹងមានបញ្ជិកាគណនេយ្យ និងតារាងតុល្យការត្រឹមត្រូវ។

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ បានបង្ហាញច្បាស់ពីអភិក្រមនៃការអនុវត្តគឺៈ

១. ធានានូវបរិយាកាសនិយ័តកម្មដែលមានលក្ខណៈអំណោយផល ផ្តល់នូវការគាំទ្រនិងការលើកទឹកចិត្តសមស្របសម្រាប់វិស័យអាទិភាព រួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់បម្រើឱ្យសកម្មភាពកសិ-ឧស្សាហកម្ម សំដៅបង្កើតឱ្យបានកាន់តែច្រើននូវសហគ្រាសកសិ-ឧស្សាហកម្ម ការកែច្នៃកសិផល តម្រង់ទិសការអភិវឌ្ឍតំបន់កសិ-ឧស្សាហកម្មដើម្បីធានានូវភាពប្រមូលផ្តុំ និងការតភ្ជាប់ទៅនឹងសួនឧស្សាហកម្ម និងកន្សោមឧស្សាហកម្ម។

២. តម្រង់ទិសលើការផ្លាស់ប្តូររចនាសម្ព័ន្ធសំខាន់ៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មពិសេសពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជំនាញ និងការអប់រំបច្ចេកទេស ការជំរុញនវានុវត្តន៍បច្ចេកវិទ្យា។

៣. សម្រួលប្រព័ន្ធផ្គត់ផ្គង់វត្ថុធាតុដើម ឬធាតុចូលប្រកបដោយគុណភាព ស្ថិរភាព និងថ្លៃទាប សម្រាប់ផលិតកម្មកសិ-ឧស្សាហកម្ម។

៤. ការគាំទ្របច្ចេកទេស ហិរញ្ញវត្ថុ និងការលើកទឹកចិត្តផ្សេងៗ ត្រូវអនុវត្តដោយផ្អែកលើសមិទ្ធកម្ម កម្មវត្ថុគោលនយោបាយច្បាស់លាស់ និងសកម្មភាពអនុវត្តជាក់ស្តែង ដូចជាការសម្រេចគោលដៅលើបរិមាណនាំចេញ ឬលទ្ធផលជាក់ស្តែងពីដំណើរការបង្កើតរោងចក្រឧស្សាហកម្មថ្មី។

៥. យកចិត្តទុកដាក់លើការការពារបរិស្ថាន ដើម្បីបញ្ចៀសការបំពុលបរិស្ថាន ដោយសារកាកសំណល់ឧស្សាហកម្ម និងសារធាតុគីមីផ្សេងៗ។

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តវិធានការគោលនយោបាយខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវអនុវត្តសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- កំណត់ និងសិក្សាវាយតម្លៃតំបន់ដាំដុះ និងកែច្នៃផលិតផលកសិកម្មសំខាន់ៗ (ស្រូវ ពោត ដំឡូងមី អំពៅ សណ្តែកសៀង ស្វាយចន្ទី ម្រេច ស្វាយ ចេក បន្លែ ផ្លែឈើ និងដំណាំដែលមានសក្តានុពលផ្សេងៗទៀត)
- សម្របសម្រួល គាំទ្រក្នុងការបង្កើត និងដំណើរការតំបន់កសិ-ឧស្សាហកម្ម សម្រាប់ប្រមូលផ្តុំផលិតកម្មកែច្នៃ វេចខ្ចប់សម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ

- ស្រាវជ្រាវ អភិវឌ្ឍ និងផ្សព្វផ្សាយពូជដំណាំដែលមានផលិតភាពខ្ពស់ ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងឆ្លើយតបទីផ្សារ ជាសក្តានុពលសម្រាប់ផលិតជាវត្ថុធាតុដើមបម្រើឱ្យវិស័យកសិ-ឧស្សាហកម្ម
- បង្កើតនិងជំរុញការអនុវត្តបច្ចេកវិទ្យាសមស្រប និងការប្រើប្រាស់ធាតុចូលប្រកបដោយគុណភាពក្នុងផលិតកម្មកសិកម្ម រួមទាំងការអនុវត្តកសិកម្មល្អ ការអនុវត្តល្អក្នុងវិស័យចិញ្ចឹមសត្វ ការអនុវត្តវារីវប្បកម្មល្អ ការអនុវត្តអនាម័យល្អក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្ម ដែលមានសក្តានុពលសម្រាប់ការកែច្នៃ និងនាំចេញ
- ពង្រីកនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្មឱ្យក្លាយជាសហគ្រាសសេដ្ឋកិច្ចជនបទសម្រាប់ការកសាងភាពជាដៃគូជាមួយផ្នែកឯកជន តាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យា
- ធ្វើទំនើបកម្មមន្ទីរពិសោធន៍វិភាគគុណភាព សុវត្ថិភាពធាតុចូល និងផលិតផលកសិកម្ម ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសមានការទទួលស្គាល់ជាសកលដើម្បីបម្រើឱ្យការនាំចេញ
- កសាងមន្ទីរពិសោធន៍បង្អែកអនាម័យនិងភូតគាមអនាម័យ (SPS Reference Laboratory) ដោយបំពាក់នូវឧបករណ៍និងបច្ចេកវិទ្យាទំនើបទាន់សម័យ ដើម្បីសម្រួលការត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ
- អភិវឌ្ឍស្វ័យប្រវត្តិកម្មប្រព័ន្ធវិញ្ញាបនកម្មភូតគាមអនាម័យដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងនាំចេញផលិតផលកសិកម្ម
- លើកកម្ពស់ការយល់ដឹងអំពីលិខិតបទដ្ឋាន ច្បាប់ និងនីតិវិធីស្នើសុំការត្រួតពិនិត្យ និងផ្តល់វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ
- ជំរុញការរៀបចំ និងអនុវត្តច្បាប់ស្តីពីផលិតកម្មតាមកិច្ចសន្យា ក្នុងគោលដៅពង្រឹងការភ្ជាប់ទំនាក់ទំនង និងភាពជាដៃគូរវាងគ្រួសារកសិករខ្នាតតូច ក្រុមកសិករ សហគមន៍កសិកម្ម ជាមួយក្រុមហ៊ុនវិនិយោគខ្នាតមធ្យមនិងធំ
- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់បរិក្ខារគាំទ្រការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យាដល់កសិករចិញ្ចឹមសត្វ សម្របសម្រួល និងគាំទ្រក្នុងការបង្កើត និងដំណើរការតំបន់ប្រមូលផ្តុំកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងផលិតចំណីសត្វ បសុឱសថកន្លែងកែច្នៃ វេចខ្ចប់សាច់ និងផលិតផលសត្វដែលមានលក្ខណៈទំនើប សម្រាប់លើកកម្ពស់លក្ខខណ្ឌអនាម័យ គុណភាព និងសុវត្ថិភាព ធានាដល់សុខភាពសាធារណៈ
- ចងក្រងនិងពង្រឹងសមត្ថភាពសហគមន៍អភិវឌ្ឍន៍ការចិញ្ចឹមសត្វ ចំណីសត្វ និងកែច្នៃផលិតផលសាច់
- ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍វិភាគរោគវិនិច្ឆ័យជំងឺសត្វ គុណភាពនិងសុវត្ថិភាពសាច់ និងផលិតផលសត្វ គុណភាពចំណីសត្វ និងបសុឱសថ អនុលោមតាមបទដ្ឋានដែលទទួលស្គាល់ជាសកល
- បង្កើតមន្ទីរពិសោធន៍អនាម័យសត្វតំបន់ (Regional SPS Laboratory) ដោយបំពាក់នូវឧបករណ៍ និងបច្ចេកវិទ្យាសមស្រប ដើម្បីសម្រួលដល់ការវិភាគរោគវិនិច្ឆ័យជំងឺសត្វ គុណភាព និងសុវត្ថិភាពសាច់ និងផលិតផលសត្វ
- ពង្រឹងសមត្ថភាពវិភាគលើគុណភាពសុវត្ថិភាពផលិតផលកសិកម្មក្នុងមន្ទីរពិសោធន៍ សិក្សាស្រាវជ្រាវអំពីនីតិវិធី និងវិធីសាស្ត្រទំនើប សម្រាប់វិភាគគុណភាពសុវត្ថិភាពផលិតផលកសិកម្ម និងស្បៀងអាហារ និងបណ្តុះបណ្តាលបច្ចេកទេសវិភាគគុណភាពសុវត្ថិភាពក្នុងមន្ទីរពិសោធន៍
- ពង្រឹងនិងពង្រីកការអនុវត្តការងារបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីបង្កើនសមត្ថភាពធនធានមនុស្សផ្នែកជំនាញកសិកម្ម និងកសិ-ឧស្សាហកម្ម។

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តវិធានការពាក់ព័ន្ធនឹងការកែលម្អបរិស្ថាននិយ័តកម្ម ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ នឹងត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

១. ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ។
២. ជំរុញរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្ម។
៣. ជំរុញការអនុវត្តច្បាប់ស្តីពីការការពារុក្ខជាតិ និងភូតគាមអនាម័យ។
៤. រៀបចំស្តង់ដារូបនីយកម្មដំណាំកសិកម្ម និងការវាយតម្លៃការទទួលស្គាល់អនុលោមភាព។
៥. រៀបចំគោលនយោបាយ និងឯកសារគតិយុត្ត ស្តីពីប្រតិបត្តិការ និងការគ្រប់គ្រងមន្ទីរពិសោធន៍កសិកម្មជាតិ។
៦. ជំរុញការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងលិខិតបទដ្ឋានក្រោមច្បាប់។
៧. រៀបចំកែសម្រួល ធ្វើវិសោធនកម្ម និងអនុវត្តច្បាប់ស្តីពីជលផល។
៨. សហការរៀបចំស្តង់ដាផល ផលិតផលជលផល ដែលមានសក្តានុពលនាំចេញ។
៩. សហការរៀបចំកែលម្អ និងធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋាន និងបច្ចេកទេសស្របទៅតាមសភាពការណ៍រីកចម្រើនរបស់ប្រទេស។
១០. រៀបចំនិងអនុវត្តច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវបន្តសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម បង្កើនការចរាចរតម្រូវការអនុវត្តវិធានអនាម័យសត្វ និងភូតគាមអនាម័យ ដើម្បីបើកច្រកនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិ ពង្រីកនិងពង្រឹងទំនាក់ទំនងរវាងគ្រឹះស្ថានបណ្តុះបណ្តាលជាមួយក្រុមហ៊ុន និងសហគ្រាសកសិ-ឧស្សាហកម្ម ដើម្បីបង្កើនសមត្ថ-ភាពជំនាញ និងឱកាសការងាររបស់និស្សិត ព្រមទាំងបង្កើតវេទិកាច្នៃប្រឌិតបង្ហាញស្នាដៃថ្មី និងគម្រោងកសិ-ធុរកិច្ច ដើម្បីបង្កើនទេពកោសល្យដែលមាន និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍។

ទន្ទឹងនឹងការចូលរួមអនុវត្តនូវក្របខណ្ឌគោលនយោបាយខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមានតួនាទីចូលរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម មានជាអាទិ៍៖ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា ២០១៦-២០២៥ និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៩-២០២៣ ជាដើម។

## ជំពូកទី៤ : ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣

### ៤.១. ការសម្របសម្រួលអនុវត្តផែនការយុទ្ធសាស្ត្រ

#### ៤.១.១. តួនាទីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម គឺជាការទទួលខុសត្រូវអនុវត្តតាមអង្គភាពជំនាញនៃអនុវិស័យនីមួយៗ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវភ្ជាប់ទំនាក់ទំនងជាមួយនឹងអន្តរ-វិស័យផ្សេងៗទៀត ដូចជាធនធានទឹក ផ្លូវថ្នល់ជនបទ សុខភាព អប់រំ ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម និងផ្នែកហិរញ្ញវត្ថុ ដើម្បីគាំទ្រមុខងារ និងការអនុវត្តផែនការយុទ្ធសាស្ត្រប្រកបដោយជោគជ័យ។ ជាមួយគ្នានេះ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនក៏មានតួនាទីសំខាន់ផងដែរក្នុងការគាំទ្រការងារអនុវត្តផែនការយុទ្ធសាស្ត្រនេះ ក្រោមក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពនៃកម្មវិធីធំៗទាំង៥ នៃផែនការយុទ្ធសាស្ត្រទាំងមូល តាមរយៈអង្គភាពជំនាញក្រោមឱវាទក្រសួង។ អង្គភាពក្រោមឱវាទរបស់ក្រសួងត្រូវរៀបចំសកម្មភាពលម្អិត និងផែនការថវិកាតាមឆ្នាំនីមួយៗ ព្រមទាំងចូលរួមកៀរគរថវិកាពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីធ្វើយ៉ាងណាឱ្យការអនុវត្តការងារបានរលូន និងសម្រេចតាមផែនការដែលគ្រោងទុក។ ចំពោះការគ្រោងថវិកាចំណាយប្រចាំឆ្នាំត្រូវតែធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់ស្របជាមួយថវិកាដែលមាន។

តួនាទីរបស់គណៈកម្មាធិការកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ដែលមាននាយកដ្ឋានផែនការ និងស្ថិតិ និងនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ជាសេនាធិការត្រូវសម្របសម្រួលការងារអនុវត្ត ជាពិសេសដោះស្រាយបញ្ហា ភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុវត្តផែនការសកម្មភាពរបស់អង្គភាពពាក់ព័ន្ធ សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ព្រមទាំងសម្របសម្រួលក្នុងការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។ ការសម្របសម្រួលការអនុវត្តសកម្មភាពផែនការយុទ្ធសាស្ត្ររួមមាន៖

- ពិនិត្យនិងធ្វើការកែទម្រង់បែបបទការងារក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះបានលឿនតាមផែនការកំណត់
- សម្របសម្រួលក្នុងការបែងចែកធនធានទៅតាមអនុវិស័យ ដែលបានអនុវត្តការងារល្អប្រសើរ និងមានអាទិភាពខ្ពស់
- រៀបចំការសិក្សាវាយតម្លៃ និងកែសម្រួលការងារអនុវត្តផែនការយុទ្ធសាស្ត្រឱ្យបានប្រសើរជាងមុន
- តាមដាននិងវាយតម្លៃការងារអនុវត្តផែនការសកម្មភាព។

#### ៤.១.២. តួនាទីអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីគាំទ្រថវិកា សម្របសម្រួលកិច្ចការវិនិយោគ និងហិរញ្ញប្បទានផ្សេងៗ ដើម្បីឱ្យការងារអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ផ.យ.អ.វ.ក) ២០១៩-២០២៣ ទទួលបានជោគជ័យតាមផែនការកំណត់។ ក្រសួងផែនការមានតួនាទីតាមដាន និងវាយតម្លៃស្ថានភាពអំពីវឌ្ឍនភាព ព្រមទាំងពិនិត្យលើរបាយការណ៍ប្រចាំឆ្នាំអំពីលទ្ធផលនៃការអនុវត្ត ផ.យ.អ.វ.ក។

អន្តរក្រសួងដែលពាក់ព័ន្ធត្រូវធ្វើយ៉ាងណាបង្កបរិយាកាសសម្របសម្រួល ដើម្បីឱ្យក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ អាចអនុវត្តការងារបានរលូន និងសម្រេចបានតាមផែនការដែលគ្រោងទុក។ កិច្ចការទាំងនេះរួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រកសិកម្ម ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់អគ្គីសនី ការផ្តល់ឥណ-ទានដែលមានការប្រាក់សមរម្យដល់សហគមន៍កសិកម្ម ការផ្តល់បច្ចេកទេសកែច្នៃផលិតផលកសិកម្ម ការពង្រីក

ទីផ្សារសម្រាប់កសិ-ពាណិជ្ជកម្មជាដើម។ល។ ដើម្បីជួយឱ្យការអភិវឌ្ឍវិស័យកសិកម្មមានសន្ទុះលឿនទៅមុខតាមការរំពឹងទុក។

### ៤.១.៣. តួនាទីដៃគូអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍវិស័យកសិកម្ម

ដៃគូអភិវឌ្ឍន៍ទាំងទ្វេភាគី និងពហុភាគី បានជួយគាំទ្រផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុដល់វិស័យកសិកម្មកម្ពុជា។ បច្ចុប្បន្ន ដោយសារកម្ពុជាមានកំណើនសេដ្ឋកិច្ចល្អប្រសើរ និងមានសមត្ថភាពហិរញ្ញវត្ថុដោយខ្លួនឯង តួនាទីហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍មានការថយចុះ ហើយផ្នែកមួយចំនួនធំរបស់ផែនការសកម្មភាពត្រូវបានរាជរដ្ឋាភិបាលប្រើប្រាស់ថវិកាជាតិដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាព។ ទោះជាយ៉ាងនេះក៏ដោយ ដៃគូអភិវឌ្ឍន៍ ទាំងទ្វេភាគី និងពហុភាគីនៅតែមានតួនាទីយ៉ាងសំខាន់ ជាពិសេសលើគម្រោងសកម្មភាព និងគំនិតផ្តួចផ្តើមថ្មីៗដែលគាំទ្រដល់វឌ្ឍនភាពនៃវិស័យកសិកម្ម ព្រមទាំងក្នុងការដឹកនាំធ្វើគម្រោងសាកល្បងផ្សេងៗពាក់ព័ន្ធក្នុងការធ្វើទំនើបកម្មកសិកម្ម។ ជាមួយគ្នានេះ ដៃគូអភិវឌ្ឍន៍ត្រូវជួយគាំទ្រសកម្មភាពរបស់កម្មវិធីដោយផ្តល់សេវា-កម្ម និងការគាំទ្រដល់ការអភិវឌ្ឍកសិកម្មនៅជនបទឱ្យបានកាន់តែទូលាយថែមទៀត។ បច្ចុប្បន្ន ដៃគូអភិវឌ្ឍន៍បានយល់អំពីស្ថានភាព និងអត្ថប្រយោជន៍នៃការប្រឹក្សាជាមួយរាជរដ្ឋាភិបាល ពិសេសជាមួយក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ក្នុងការគាំទ្រដល់កម្មវិធីនានាក្នុងផែនការយុទ្ធសាស្ត្រ ជាជាងធ្វើការអនុវត្តគម្រោងកម្មវិធីដោយជម្រើសជាឯកតោភាគី។ ក្នុងន័យនេះ ដៃគូអភិវឌ្ឍន៍ដែលផ្តល់ជំនួយហិរញ្ញវត្ថុ គួរដាក់បញ្ចូលនូវធនធានថវិកា និងប្រើប្រាស់ជាបណ្តើរៗនូវប្រព័ន្ធថវិការាជរដ្ឋាភិបាល។

### ៤.១.៤. តួនាទីវិស័យឯកជនក្នុងការអភិវឌ្ឍវិស័យកសិកម្ម

វិស័យឯកជនជាកម្លាំងចលករចម្បងក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ធុរកិច្ច។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ គឺជាឯកសារគោលនយោបាយដ៏សំខាន់ក្នុងការអភិវឌ្ឍ ដោយមានការចូលរួមពីវិស័យឯកជនជាចាំបាច់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសម្របសម្រួលការអនុវត្តគម្រោងវិនិយោគឯកជនក្នុងវិស័យកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់។ វិស័យឯកជនទាំងនោះរួមមាន៖ ផ្នែកផលិតកម្មដំណាំ ចិញ្ចឹមសត្វ វារីវប្បកម្ម ផ្នែកកែច្នៃ និងវេចខ្ចប់ផលិតផល ភ្នាក់ងារប្រមូលទិញ គ្រប់គ្រងទីផ្សារ និងលក់ធាតុចូលកសិកម្មជាដើម។ល។ តួនាទីចាំបាច់របស់វិស័យឯកជនក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ គឺផ្តោតជាសំខាន់លើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ផលិតកម្ម ការកែច្នៃ ការរៀបចំបង្កើតទីផ្សារបោះដុំ និងចែកចាយបន្លែផ្លែឈើដែលមានស្តង់ដារ និងអនាម័យខ្ពស់ អាហារ័ណ-នីហរ័ណ ព្រមទាំងការគាំទ្រលើសេវាកម្មហិរញ្ញវត្ថុ និងសេវាកម្មពាក់ព័ន្ធដទៃទៀត។

ជាមួយគ្នានេះ ក្រសួងនឹងបន្តអនុវត្តយន្តការសន្ទនាក្នុងភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ក្នុងកម្រិតគោលនយោបាយ និងបច្ចេកទេស ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីជំរុញការពិភាក្សា និងស្វែងរកដំណោះស្រាយបញ្ហាប្រឈម និងលើកទឹកចិត្តឱ្យវិស័យឯកជនវិនិយោគកាន់តែច្រើនឡើង ព្រមទាំងចូលរួមអភិវឌ្ឍមូលធនមនុស្ស និងនវានុវត្តន៍ក្នុងវិស័យកសិកម្ម។

### ៤.១.៥. តួនាទីសង្គមស៊ីវិល

សង្គមស៊ីវិលបានដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងមានបទពិសោធន៍លើការងារផ្សព្វផ្សាយកសិកម្ម និងសន្តិសុខស្បៀង ព្រមទាំងបានចូលរួមចំណែកក្នុងវឌ្ឍនភាពនៃការលូតលាស់សេដ្ឋកិច្ចនៅជនបទ។ ស្ថាប័ននេះរួមមានអង្គការក្រៅរដ្ឋាភិបាល សហភាព សហគមន៍ និងក្រុមកសិករ ដែលទាមទារឱ្យមានការ

សម្របសម្រួល ក្នុងការចូលរួមជួយគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រឱ្យមានប្រសិទ្ធភាព ពីព្រោះស្ថាប័នទាំងនេះបានអនុវត្តការងារទៅតាមជម្រើសនៃថវិការបស់ប្រទេសផ្តល់ជំនួយ។ ការចូលរួមគាំទ្រជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រុមកសិករ សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មនៅមានកម្រិតនៅឡើយ។ ដូច្នេះយុទ្ធសាស្ត្រនេះត្រូវការពង្រឹង និងសម្របសម្រួលជាមួយអង្គការសង្គមស៊ីវិល ដើម្បីរៀបចំកៀរគរ និងប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព ក្នុងការជួយអនុវត្តផែនការសកម្មភាពរបស់កម្មវិធី និងអនុកម្មវិធីនៅក្នុងកម្រិតសហគមន៍មូលដ្ឋាន។ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការអនុវត្ត អង្គការសង្គមស៊ីវិលត្រូវសហការជាមួយក្រសួង តាមរយៈការបង្កើតកិច្ចព្រមព្រៀងអនុវត្តគម្រោងជាចាំបាច់។

## ៤.២. ការរៀបចំកម្មវិធី និងថវិកា

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាវិធានការគោលនយោបាយមួយដ៏សំខាន់ និងបានកំណត់ទិសដៅច្បាស់លាស់ ក្នុងការផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូលនិងមជ្ឈការ ទៅជាប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើសមិទ្ធកម្មនិងវិមជ្ឈការ។ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផលឬសមិទ្ធកម្មនេះ គឺជាប្រព័ន្ធផ្សារភ្ជាប់ការវិភាជន៍ថវិកាទៅនឹងសកម្មភាព ដែលជាតម្រូវការជាក់ស្តែង និងក្នុងក្របខ័ណ្ឌកម្មវិធីច្បាស់លាស់ ឆ្លើយតបនឹងគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធានាថាថវិកាពិតជាដើរតួនាទីសំខាន់ និងជាឧបករណ៍បម្រើឱ្យគោលនយោបាយប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់គោលដៅ និងគោលបំណងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ដោយបានដាក់ចេញនូវកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពអាទិភាពសំខាន់ៗ សំដៅធ្វើការវិភាជន៍ថវិកាជាតិ និងថវិកាដែលបានមកពីដៃគូអភិវឌ្ឍន៍ឱ្យបានសមស្រប។ ការរៀបចំធនធានហិរញ្ញវត្ថុនេះគឺផ្អែកលើមូលដ្ឋានចំណាយរបស់ ផ.ក.យ.អ.វ.ក ២០១៩-២០២៣ ដែលមានប្រភពពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៍នានា។

កម្មវិធីនីមួយៗមានអនុកម្មវិធីមួយចំនួនដែលជាផ្នែកនៃកម្មវិធី។ អនុកម្មវិធីនីមួយៗនឹងត្រូវបានរៀបចំឡើងដើម្បីរួមចំណែកសម្រេចបានគោលបំណងកម្មវិធី។ អនុកម្មវិធីនឹងត្រូវបានវាយតម្លៃក្នុងមួយឆ្នាំម្តង និងអាចធ្វើការកែសម្រួលប្រសិនបើចាំបាច់។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គោលបំណង និងមធ្យោបាយដើម្បីសម្រេចបានរបស់អនុកម្មវិធីទាំងអស់នោះអាចត្រូវបានកែសម្រួលដោយយោងទៅលើលទ្ធផលការងារ និងធនធានដែលមាន។ សូចនាករយ៉ាងច្រើនចំនួន <u>បី</u> ត្រូវបានកំណត់សម្រាប់ការតាមដាន និងវាយតម្លៃប្រចាំឆ្នាំជាមូលដ្ឋាន។ អនុកម្មវិធីត្រូវសម្រេចឱ្យបាននូវកម្រិតនៃ "គោលបំណង" ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី។ ថវិកាគ្រោងចំណាយរបស់អនុកម្មវិធី គឺជាតម្លៃសរុបនៃចង្កោមសកម្មភាពដែលស្ថិតនៅក្រោមអនុកម្មវិធីនោះ។

អនុកម្មវិធីនីមួយៗអាចមានចង្កោមសកម្មភាពមួយចំនួន ដែលរួមចំណែកផ្ទាល់ដើម្បីសម្រេចនូវគោលបំណងអនុកម្មវិធី។ ចង្កោមសកម្មភាពជាកម្រិតការងារដែលត្រូវអនុវត្តឱ្យទទួលបានលទ្ធផលក្នុងឆ្នាំ។ សូចនាករយ៉ាងច្រើនចំនួន <u>បី</u> ត្រូវបានកំណត់សម្រាប់ការតាមដាន និងវាយតម្លៃប្រចាំឆ្នាំជាមូលដ្ឋាន។ ចង្កោមសកម្មភាពត្រូវសម្រេចឱ្យបាននូវកម្រិត "លទ្ធផលក្នុងឆ្នាំ" ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី។

ផ្អែកលើផែនការយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំកសាងគម្រោងលម្អិតដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ០៣ឆ្នាំរំកិល ស្របតាមការកំណត់របស់រាជរដ្ឋាភិបាលក្រោមការសម្របសម្រួលរបស់ក្រសួងផែនការ។ ក្នុងន័យនេះ ដៃគូអភិវឌ្ឍន៍នានាត្រូវពិនិត្យលើបញ្ជីគម្រោងក្នុងកម្មវិធី

វិនិយោគសាធារណៈ ដើម្បីរៀបចំកសាងគម្រោងអភិវឌ្ឍន៍ស្របទៅតាមគោលនយោបាយ និងសក្តានុពលរបស់ខ្លួនជាចាំបាច់។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ មានតម្រូវការថវិកាសរុបចំនួនប្រមាណជាង ៣ ៨៤២ ៥៨២,៣៥លានរៀល ក្នុងនោះថវិកាចរន្តមានចំនួនប្រមាណ ១ ៣៥៩ ៨២៩,៧៤លានរៀល និងថវិកាវិនិយោគមានចំនួន ៣ ៨៤២ ៥៨២,៣៥លានរៀល សម្រាប់ចំណាយរយៈពេល៥ឆ្នាំខាងមុខ។ ក្នុងថវិកាចរន្តសរុបនេះ គឺគ្រោងសម្រាប់ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ចចំនួន ១៧៩ ៦៩៦,៥១ លានរៀល គ្រោងសម្រាប់ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វចំនួន ៣៦៤ ៦៧១,៨០លានរៀល គ្រោងសម្រាប់ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្មចំនួន ៥៣ ១៧៨,៩២លានរៀល សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃចំនួន ១២៦ ៤៨៣,៧៤លានរៀល និងថវិកាចរន្តចំនួន ៦៣៥ ៧៩៨,៧៥លានរៀល គ្រោងសម្រាប់ការពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម។

**តារាងទី៦: ការប៉ាន់ស្មានតម្រូវការធនធានហិរញ្ញវត្ថុឆ្នាំ២០១៤-២០១៨**

| កម្មវិធី | ថវិកាចរន្ត | ថវិកាមូលធន | សរុប (លានរៀល) |
|---|---|---|---|
| កម្មវិធីទី១៖ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច | 179,696.51 | 732,343.53 | 912,040.05 |
| កម្មវិធីទី២៖ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ | 364,671.80 | 338,889.28 | 703,561.08 |
| កម្មវិធីទី៣៖ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម | 53,178.92 | 699,788.00 | 752,966.92 |
| កម្មវិធីទី៤ ៖ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ | 126,483.74 | 614,394.40 | 740,878.14 |
| កម្មវិធីទី៥: ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស | 635,798.75 | 97,337.40 | 733,136.15 |
| សរុបរួម | 1,359,829.74 | 2,482,752.61 | 3,842,582.35 |

## ជំពូកទី៥ : យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣

រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលជាច្រើន ក្នុងការពង្រឹងភាពជាដៃគូជាមួយគូអង្គអភិវឌ្ឍទាំងអស់តាមរយៈការដាក់ឱ្យអនុវត្ត និងកែលម្អជាបន្តបន្ទាប់នូវក្របខ័ណ្ឌគោលនយោបាយ យន្តការស្ថាប័ន និងលិខិតបទដ្ឋានចាំបាច់ជាច្រើន ពិសេសការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងភាពជាដៃគូឆ្នាំ២០១៤-២០១៨ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានសម្រេចជោគជ័យក្នុងការកៀរគរធនធានសម្រាប់ការអភិវឌ្ឍជាតិ ហើយចាត់ទុកហិរញ្ញប្បទានសហប្រតិបត្តិការនៅតែបន្តតួនាទីសំខាន់សម្រាប់អភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចកម្ពុជា។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏នឹងបន្តខិតខំក្នុងការទាក់ទាញជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា សម្រាប់ចូលរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ឱ្យទទួលបានជោគជ័យនាពេលខាងមុខ។ ជាមួយគ្នានេះ ក្រសួងនឹងបន្តអនុវត្ត និងដំណើរការយន្តការក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក សម្រាប់ជាមូលដ្ឋានកៀរគរធនធាន ទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ក្រសួងក៏ត្រូវបន្តអនុវត្តយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ដើម្បីទាញយកការវិនិយោគ

ថ្មីៗបន្ថែមទៀត បន្តដោះស្រាយកង្វល់ផ្សេងៗរបស់វិស័យឯកជន ព្រមទាំងលើកកម្ពស់សហគ្រិនភាព រួមទាំងសហគ្រាសកសិកម្មធុនតូចនិងមធ្យម ជាពិសេសក្នុងចំណោមកសិធុរកិច្ចជន និងអ្នកវិនិយោគផ្នែកកែច្នៃផលិតផលកសិកម្ម ដែលជាចំណែកមួយយ៉ាងសំខាន់ក្នុងការចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

## ជំពូកទី៦ : ការតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការអនុវត្តគម្រោងសកម្មភាព និងសូចនាករនានា សម្រាប់ផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធភាពសម្រេចបាន ដែលបានកំណត់យ៉ាងសមស្របនៅក្នុងការធ្វើផែនការ និងការរៀបចំគម្រោងសកម្មភាពនីមួយៗ។ ដូច្នេះ ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាឧបករណ៍ដ៏ស័ក្តិសិទ្ធិសម្រាប់ផ្ទៀងផ្ទាត់រាល់សូចនាករលទ្ធផល (Outcomes & Outputs) នៅពាក់កណ្តាលអាណត្តិ និងពេញអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងដើម្បីជាមូលដ្ឋានសម្រាប់វាយតម្លៃការអនុវត្តគោលនយោបាយតាមផ្នែក ក៏ដូចជាគោលនយោបាយថ្នាក់ជាតិ។

ទោះបីយ៉ាងណាក៏ដោយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នឹងត្រូវបានបង្ហាញ និងបញ្ជាក់នូវសូចនាករជាច្រើនសម្រាប់ធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្ត។ ដើម្បីធានាដល់ការអនុវត្តយ៉ាងពេញលេញនូវការតាមដាននិងវាយតម្លៃ នាយកដ្ឋានផែនការនិងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តសកម្មភាពតាមដាន និងវាយតម្លៃនេះ។ របាយការណ៍លទ្ធផលការងារសម្រាប់គម្រោងទាំងនោះនឹងត្រូវរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត និងការវាយតម្លៃក្រោយពេលអនុវត្ត។ បណ្តានាយកដ្ឋាន/អង្គភាពជំនាញនានាដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវរាយការណ៍ជូនក្រសួង (នាយកដ្ឋានផែនការនិងស្ថិតិ) ពីលទ្ធផលសម្រេចបានឱ្យបានទៀងទាត់ តាមរយៈការផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ។ របាយកាណ៍អនុវត្ត និងសមិទ្ធផលសម្រេចបានក្នុងការអនុវត្តនេះនឹងត្រូវរៀបចំបូកសរុបដោយនាយកដ្ឋានផែនការនិងស្ថិតិ ហើយត្រូវរាយការណ៍ជូនក្រសួងពិនិត្យ និងសម្រេច។ ផ្អែកលើរបាយការណ៍ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការបូកសរុប រួចរាយការណ៍ជូនទៅក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានរាយការណ៍ជូនរាជរដ្ឋាភិបាលកម្ពុជា។

នាយកដ្ឋានផែនការនិងស្ថិតិ គឺជាសេនាធិការសម្របសម្រួលការតាមដាននិងវាយតម្លៃ ប្រជុំរៀបចំកាលវិភាគពេលវេលាតាមដាន និងវាយតម្លៃនៃវឌ្ឍនភាព និងធ្វើបច្ចុប្បន្នភាពរបស់ផែនការយុទ្ធសាស្ត្រទាំងមូល។ ដើម្បីបញ្ជាក់អំពីវឌ្ឍនភាព ប្រសិទ្ធភាព និងសង្គតិភាពក្នុងការងារអនុវត្តយុទ្ធសាស្ត្រ នាយកដ្ឋានផែនការនិងស្ថិតិនឹងកំណត់ឱ្យគ្រប់អង្គភាពក្រោមឱវាទក្រសួង ដែលទទួលបន្ទុកអនុវត្តកម្មវិធីនីមួយៗ ត្រូវរៀបចំ និងសម្របសម្រួលឱ្យមានប្រសិទ្ធភាពនូវការតាមដាន និងវាយតម្លៃការងារអនុវត្តសកម្មភាពរបស់កម្មវិធី ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ។ នាយកដ្ឋានផែនការនិងស្ថិតិនឹងដឹកនាំការតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាទៀងទាត់។ ការកែតម្រូវនូវកំហុសឆ្គងក្នុងការអនុវត្តផែនការនឹងត្រូវបានអនុវត្ត និងសម្របសម្រួលកែតម្រូវ បន្ទាប់ពីបានលទ្ធផលមកពីការតាមដាន និងវាយតម្លៃ។

ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មក្នុងរយៈពេល៥ឆ្នាំ(២០១៩-២០២៣) ទាមទារឱ្យប្រើប្រាស់ស្តង់ដារគំរូសម្រាប់តាមដាន វាយតម្លៃ និងសិក្សាពីមេរៀននៃការអនុវត្តផែនការយុទ្ធសាស្ត្រ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព។ សៀវភៅ "***គោលការណ៍ណែនាំស្តីពីប្រព័ន្ធផែនការ តាមដាននិងវាយតម្លៃ***" ឆ្នាំ២០១៧ របស់ក្រសួងនឹងយកមកប្រើប្រាស់ជាស្តង់ដារនៅក្នុងការតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពក្នុង

ការអនុវត្តកម្មវិធីទាំង៥។ ការតាមដាននិងវាយតម្លៃនេះនឹងត្រូវធ្វើឡើងដោយគ្រប់អង្គភាពក្រោមចំណុះឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលទទួលបន្ទុកក្នុងការអនុវត្តសកម្មភាពរបស់កម្មវិធីទាំង៥។ អង្គភាពទទួលបន្ទុកអនុវត្តគម្រោងត្រូវរៀបចំផែនការលម្អិតសម្រាប់ការតាមដាន និងអនុវត្តកិច្ចការនេះជាប្រចាំ ដើម្បីតាមដាននូវការរីកចម្រើន និងវឌ្ឍនភាពនៃការងារអនុវត្តយុទ្ធសាស្ត្រ។ តារាងផែនការតាមដាន និងវាយតម្លៃមានរាយនូវសកម្មភាព និងសូចនាករដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រនេះនឹងយកមកប្រើប្រាស់ ហើយសកម្មភាព និងសូចនាករ ត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងឱ្យទាន់នូវវឌ្ឍនភាពនៃសេដ្ឋកិច្ច និងការរីកចម្រើនវិស័យកសិកម្ម។ គ្រប់អង្គភាពចំណុះក្រសួងដែលអនុវត្តផែនការយុទ្ធសាស្ត្រនេះនឹងធ្វើរបាយ-ការណ៍តាមកម្មវិធីនីមួយៗ ដែលអង្គភាពខ្លួនទទួលខុសត្រូវដោយទៀងទាត់ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំមកឲ្យនាយកដ្ឋានផែនការនិងស្ថិតិដើម្បីបូកសរុបលទ្ធផលអនុវត្តការងារ។

តារាងគ្រោងការនៃប្រព័ន្ធតាមដាន និងវាយតម្លៃ មានការប្រមូលផ្តុំសូចនាករមកពីបណ្តាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងផលិតកម្ម តម្លៃបន្ថែម ការគ្រប់គ្រងធនធានធម្មជាតិ សន្តិសុខស្បៀង ការអភិវឌ្ឍអង្គភាពជាដើម។ ក្នុងគោលដៅសម្របសម្រួលការប្រមូលរាល់ទិន្នន័យនៃធាតុចូលមកពីប្រភពផ្សេងៗគ្នា នាយកដ្ឋានផែនការនិងស្ថិតិនឹងធ្វើការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយ ហើយពិភាក្សាយ៉ាងល្អិតល្អន់ជាមួយផ្នែកពាក់ព័ន្ធមុននឹងចេញជារបាយការណ៍លទ្ធផលតាមដាននិងវាយតម្លៃ។ ការពង្រឹងទំនាក់ទំនងរវាងផែនការសកម្មភាព ថវិកា ការអនុវត្ត និងការតាមដាននិងវាយតម្លៃគឺជាផ្នែកសំខាន់មួយសម្រាប់ភាគីពាក់ព័ន្ធចូលរួមក្នុងវដ្តនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវក្នុងការប្រើប្រាស់ធនធាន។

**ក្រាហ្វិកទី៣៖ ប្រព័ន្ធផែនការថវិកា ការតាមដាន និងវាយតម្លៃ**




នាយកដ្ឋានផែនការរបស់អង្គភាពនៃអនុវិស័យនីមួយៗ ត្រូវទទួលខុសត្រូវក្នុងការពិនិត្យការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរបស់ខ្លួន ដោយត្រូវតាមដាន និងវាយតម្លៃផ្អែកលើតារាងគ្រោងការនៃប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ផែនការយុទ្ធសាស្ត្រនេះ ដោយប្រើប្រាស់សៀវភៅ “គោលការណ៍ណែនាំស្តីពីប្រព័ន្ធផែនការ តាមដាននិងវាយតម្លៃ” ឆ្នាំ២០១៧ របស់ក្រសួងជាមូលដ្ឋានគំរូ។ នាយកដ្ឋានផែនការនិងស្ថិតិ ត្រូវដឹកនាំ

ធ្វើសំណាកស្ទាបស្ទង់ និងរៀបចំតាមដាន និងវាយតម្លៃ ស្រង់លទ្ធផលដោយឯករាជ្យ ដើម្បីបញ្ជាក់អំពីសុពលភាព ទិន្នន័យ និងព័ត៌មាន និងបញ្ជាក់ផងដែរពីការសម្រេចបាននៅគោលដៅ និងគោលបំណងផែនការ យុទ្ធសាស្ត្រ។

ដ្យាក្រាមអំពីរចនាសម្ព័ន្ធ និងតួនាទីក្នុងការអនុវត្តការតាមដាន និងវាយតម្លៃសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មបង្ហាញដូចខាងក្រោម៖

## ជំពូកទី៧ : សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ បានរៀបចំឡើងដោយមានសង្គតិភាពទៅនឹងឯកសារយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងស្របជាមួយឯកសារគោលនយោបាយពាក់ព័ន្ធផ្សេងទៀតផងដែរ។ ដំណើរការរៀបចំយុទ្ធសាស្ត្រនេះគឺមានការពិគ្រោះយោបល់ជាមួយអង្គភាពជំនាញក្រោមឱវាទក្រសួង ក្រសួងស្ថាប័នពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងតំណាងវិស័យឯកជន។ ផែនការកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលបានរៀបចំកសាងមកនេះ នឹងអាចអនុវត្តទទួលបានជោគជ័យ គឺអាស្រ័យដោយការតាំងចិត្តពុះពារ រួមទាំងការជួយឧបត្ថម្ភគាំទ្រ ទាំងស្មារតី ធនធាន សម្ភារ និងថវិកាពីរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីអនុវត្តនូវគម្រោងផែនការយុទ្ធសាស្ត្រនេះដោយប្រសិទ្ធភាពខ្ពស់។ កត្តាប្រឈមដែលបានរៀបរាប់ក្នុងផែនការនេះ គឺជាកត្តាសំខាន់នឹងអាចកាត់បន្ថយបានតាមរយៈការតាំងចិត្ត និងការខិតខំជម្នះពីគ្រប់ផ្នែកពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិច្ចការជាច្រើនដែលនឹងត្រូវអនុវត្តក្នុងផែនការយុទ្ធសាស្ត្រនេះ និងត្រូវសម្រេចឱ្យបានលទ្ធផលជាក់ស្តែងនាពេលខាងមុខ ជាពិសេសដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយទាំងអស់ខាងលើ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងអនុវិស័យនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវតែខិតខំធ្វើយ៉ាងណាអនុវត្តការងារឱ្យបានសកម្ម និងខ្លាំងក្លានូវបណ្តាសកម្មភាពទាំងឡាយ ដូចដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដោយប្រែក្លាយផែនការសកម្មភាពដែលមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើន និងប្រើប្រាស់ធនធានក្នុងស្រុក និងកៀរគរធនធានពីបណ្តាដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានា ក៏ដូចជាការធ្វើសមាហរណកម្មឱ្យតួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រនេះ សម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ពិតជានឹងចូលរួមសហការអនុវត្តសកម្មភាពការងារ ពិសេសសហគមន៍អន្តរជាតិនឹងបន្តផ្តល់ជំនួយទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកជួយទ្រទ្រង់ដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ នេះ ឱ្យទទួលបានលទ្ធផលផ្លែផ្កាជាវិជ្ជមាន និងប្រកបដោយប្រសិទ្ធភាពតាមផែនការ និងការរំពឹងទុក។

## ឧបសម្ព័ន្ធ១៖ តារាងផែនការសកម្មភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣

| ឈ្មោះកម្មវិធី/អនុកម្មវិធី/ចង្កោមសកម្មភាព | សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| **កម្មវិធីទី១ : ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច** | **ផលិតផលដំណាំកសិកម្មសរុប** | **លានតោន** | **២៩,៩៣** | **៣១,៤៨** | **៣៣,១៤** | **៣៤,៩** | **៣៦,៧៧** |
| | **អនុបាត (%) នៃពិពិធកម្មដំណាំ** | **ភាគរយ** | **៦៣,៤៤** | **៦៤,៥៥** | **៦៥,៦៥** | **៦៦,៧៣** | **៦៧,៧៩** |
| | **ផលិតផលដំណាំកសិកម្មនាំចេញ** | **លានតោន** | **៥,៨៧** | **៦,២៩** | **៦,៧៣** | **៧,២** | **៧,៧** |
| **អនុកម្មវិធីទី១.១ ៖ ការអភិវឌ្ឍដំណាំស្រូវ** | **បរិមាណផលស្រូវ (៣%)** | **លានតោន** | **១១,១៨** | **១១,៥១** | **១១,៨៦** | **១២,២១** | **១២,៥៧** |
| ចង្កោមសកម្មភាពទី១ ៖ ការជំរុញផលិតកម្មដំណាំស្រូវ | ទិន្នផលស្រូវ (កំណើន ២,២%) | ត/ហ.ត | ៣,៤៥០ | ៣,៥៣៧ | ៣,៦១៨ | ៣,៦៩៩ | ៣,៧៨០ |
| ចង្កោមសកម្មភាពទី២ ៖ ការលើកកម្ពស់បច្ចេកទេសក្នុងនិងក្រោយពេលប្រមូលផលដំណាំស្រូវ | ភាគរយនៃការបន្ថយការបាត់បង់ក្នុង និងក្រោយពេលប្រមូលផល | % / ឆ្នាំ | ២ | ២ | ២ | ២ | ២ |
| | កំណើន (%) ផ្ទៃដីប្រមូលផលស្រូវដោយគ្រឿងយន្តកសិកម្ម | % | ៨៥ | ៨៨ | ៩១ | ៩៤ | ៩៧ |
| ចង្កោមសកម្មភាពទី៣ ៖ ការលើកកម្ពស់គុណភាព សុវត្ថិភាព និងកសិ-ធុរកិច្ចស្រូវ អង្ករ | បរិមាណអង្ករត្រូវបានបញ្ជាក់គុណភាពសម្រាប់នាំចេញ (៧%) | ពាន់តោន | ៦៦០ | ៧១០ | ៧៦០ | ៨១០ | ៨៧០ |
| **អនុកម្មវិធីទី១.២ ៖ ការអភិវឌ្ឍដំណាំសាកវប្បកម្ម** | **ភាគរយនៃការផ្គត់ផ្គង់បន្លែក្នុងស្រុក** | **%** | **៦៨** | **៧០** | **៧២** | **៧៤** | **៧៦** |
| | **បរិមាណផលឈើហូបផ្លែ** | **លានតោន** | **១,៤១៧** | **១,៤៧៤** | **១,៥០៤** | **១,៥៣៤** | **១,៥៦៥** |
| | **បរិមាណផលរុក្ខជាតិលម្អ** | **តោន** | **១៤៦** | **១៤៩** | **១៥២** | **១៥៦** | **១៦៣** |
| ចង្កោមសកម្មភាពទី១ ៖ ការជំរុញផលិតកម្មសាកវប្បកម្ម | ផ្ទៃដីដាំដុះបន្លែ | ពាន់ហ.ត | ៥៨ | ៥៩ | ៦០ | ៦២ | ៦៣ |
| | ផ្ទៃដីដាំដុះឈើហូបផ្លែ | ពាន់ហ.ត | ១១០ | ១១២ | ១១៥ | ១១៧ | ១១៩ |
| | ផ្ទៃដីដាំដុះរុក្ខជាតិលម្អ | ហ.ត | ៩១ | ៩៣ | ៩៤ | ៩៧ | ១០១ |
| ចង្កោមសកម្មភាពទី២ ៖ ការលើកកម្ពស់បច្ចេកទេសក្នុង និងក្រោយពេលប្រមូលផលដំណាំសាកវប្បកម្ម | ការបន្ថយការបាត់បង់បន្លែ | %/ឆ្នាំ | ២ | ២ | ២ | ២ | ២ |
| | ការបន្ថយការបាត់បង់ឈើហូបផ្លែ (ស្វាយ) | %/ឆ្នាំ | ២ | ២ | ២ | ២ | ២ |
| ចង្កោមសកម្មភាពទី៣ ៖ ការលើកកម្ពស់គុណភាព សុវត្ថិភាព និងកសិ-ធុរកិច្ចសាកវប្បកម្ម | បរិមាណផលិតផលបញ្ជាក់ការអនុវត្តកសិកម្មល្អ និងកសិកម្មសរីរាង្គ | តោន | ៥០ | ១០០ | ១៥០ | ២០០ | ២៥០ |

| ឈ្មោះកម្មវិធី/អនុកម្មវិធី/ចង្កោមសកម្មភាព | សូចនាករ | ឯកតា | គោលដៅ (Target) | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| | បរិមាណបន្លែត្រូវបានផលិត | ពាន់តោន | ៦៧១ | ៧០៥ | ៧៤០ | ៧៧៧ | ៨១៦ |
| **អនុកម្មវិធីទី១.៣ ៖ ការអភិវឌ្ឍដំណាំឧស្សាហកម្ម** | **បរិមាណផលដំណាំឧស្សាហកម្ម (កំណើន ១០%)** | **លានតោន** | **១៧,៤២៤** | **១៩,១៦៦** | **២១,០៨២** | **២៣,១៩០** | **២៥,៥០៩** |
| ចង្កោមសកម្មភាពទី១ ៖ ការជំរុញផលិតកម្មដំណាំឧស្សាហកម្ម | កំណើនផ្ទៃដីផលិតដំណាំឧស្សាហកម្មសំខាន់ៗ (ពោត ដំឡូងមី ស្វាយចន្ទី ចេក ម្រេច អំពៅ...) | លានហ.ត | ១,៥៧ | ១,៦០ | ១,៦៣ | ១,៦៧ | ១,៧០ |
